# ស្ថានទីជាទីគង់ចាំវស្សារបស់ព្រះដ៏មានព្រះភាគ

-វស្សាទី១ ទ្រង់គង់ក្នុងឥសិបតនមិគទាយវ័ន ក្រុង ពារា-ណសី

-វស្សាទី២ ទ្រង់គង់ក្នុង វេឡុវ័នវិហារ ក្រុងរាជគ្រឹះ

-វស្សាទី៣ ទ្រង់គង់ក្នុង វេឡុវ័នវិហារ ក្រុងរាជគ្រឹះ

-វស្សាទី៤ ទ្រង់គង់ក្នុង វេឡុវ័នវិហារ ក្រុងរាជគ្រឹះ

- វស្សាទី៥ ទ្រង់គង់ក្នុង កូដាគារសាលា ព្រៃមហាវ័ន ក្រុងវេសាលី

- វស្សាទី៦ ទ្រង់គង់ក្នុង មកុលបពត៌ ដែនមគធៈ ជាប់ក្រុងរាជគ្រឹះ

- វស្សាទី៧ ទ្រង់គង់ក្នុង តាវតឹង្សពិភព ទ្រង់ប្រោសពុទ្ធមាតា ហើយទ្រង់សំដែងព្រះអភិធម្ម ៧គម្ពីរ

- វស្សាទី៨ ទ្រង់គង់ក្នុង ភេសកឡាវ័ន ភគ្គជនបទ

- វស្សាទី៩ ទ្រង់គង់ក្នុង ឃោសិតារាម ក្រុងកោសម្ពី

- វស្សាទី១០ ទ្រង់គង់ក្នុង គោតមសាលា ព្រៃបាលិលេយ្យ

- វស្សាទី១១ ទ្រង់គង់ក្នុង ស្រុកព្រាហ្មណឈ្មោះឯកនាលា ដែនមគធៈ

- វស្សាទី១២ ទ្រង់គង់ក្រោមដើមស្តៅ ក្នុងស្រុកវេរញ្ជា

- វស្សាទី១៣ ទ្រង់គង់ក្នុង ចាលិកបពត៌ ជិតក្រុងចាលិកា

- វស្សាទី១៤ ទ្រង់គង់ក្នុង ព្រះជេតពនវិហារ ក្រុងសាវត្ថី

- វស្សាទី១៥ ទ្រង់គង់ក្នុង និគ្រោធារាម ក្រុងកបិលពស្ដុ

- វស្សាទី១៦ ទ្រង់គង់ក្នុង អគាឡវចេតិយ ក្រុងអាឡវី

- វស្សាទី១៧ ទ្រង់គង់ក្នុង វេឡុវ័នវិហារ ក្រុងរាជគ្រឹះ

-វស្សាទី១៨ ទ្រង់គង់ក្នុង ចាលិកបពត៌ ជាប់ក្រុងចាលិកា

- វស្សាទី១៩ទ្រង់គង់ក្នុង ចាលិកបពត៌ ជាប់ក្រុងចាលិកា

- វស្សាទី២០ទ្រង់គង់ក្នុង វេឡុវ័នវិហារ ក្រុងរាជគ្រឹះ

- វស្សាទី២១-៤៤ទ្រង់គង់នៅជាប្រចាំក្នុងក្រុងសាវត្ថី នាវត្ត ជេតពន និងមិគារមាតុប្រាសាទ ក្នុងឧទ្យានបុព្វារាម ( តែមិនប្រាកដថា វស្សាណាខ្លះទ្រង់នៅក្នុងជេតវ័នមហាវិហារ វស្សាណាខ្លះ ទ្រង់គង់នៅក្នុង មិគារមាតុប្រាសាទនោះទេ )

-វស្សាទី៤៥ ទ្រង់ចាំវស្សា ខាងចុងបំផុតនៃ ព្រះជន្មាយុ របស់ព្រះដ៏មានព្រះភាគ ក្នុងវេឡុវគាម ក្បែរក្រុងវេសាលី នាដែន

វដ្ដី កាលដែលចេញព្រះវស្សាហើយ ព្រះអង្គស្ដេចយាង ទៅប្រោ-សវេនេយ្យសត្វ តាមស្រុក និគមផ្សេងៗ តាមដងវិថី ចូលទៅកាន់ក្រុងកុសិនារា ក៏ទ្រង់បរិនិព្វាន ក្នុងក្រុងកុសិនារា នាចន្លោះដើមរាំងទាំងគូនោះឯង ។

សម្ដីមនុស្សនិងសម្រែងសត្វយំ

សំឡេងសត្វស្វាបទាំងឡាយដែលស្រែកយំតាមជួរព្រៃភ្នំឬតាមទីរមណីយដ្ឋានទាំងឡាយអាចជាអារម្មណ៍សប្បាយរីករាយឬសង្វេគដល់ជនអ្នកនៅទីនោះបានស្ដាប់ ប៉ុន្តែសំឡេងរបស់មនុ-ស្សដែលនិយាយកុហកញុះញង់ ជេរប្រទេចផ្ដាសាដោយឥតមានមេត្តា ជាអារម្មណ៍ធុញទ្រាន់បំផុតរបស់ពពួកជនដែលបានស្ដាប់ហើយ ។

- មនុស្សសត្វទាំងឡាយចូលចិត្តពាក្យសម្ដីពិត
- មនុស្សសត្វទាំងឡាយចូលចិត្តពាក្យសម្ដីមានប្រយោជន៍
- មនុស្សសត្វទាំងឡាយចូលចិត្តពាក្យនិយាយសមរម្យតាមកាល
- មនុស្សសត្វទាំងឡាយចូលចិត្តពាក្យសម្ដីផ្អែមពីរោះ
- មនុស្សសត្វទាំងឡាយចូលចិត្តពាក្យសម្ដីដែលប្រកបដោយមេត្តាតាំងពីសម័យបុរាណរហូតដល់សម័យបច្ចុប្បន្ននេះ ពាក្យ

ពិតមានប្រយោជន៍ នៅតែរក្សាតម្លៃខ្ពង់ខ្ពស់ជានិច្ច។

- មនុស្សល្អចូលចិត្តការពិត  មនុស្សអាក្រក់ខ្លាចការពិត

- ពាក្យពិតប្រកបដោយមេត្តា អាចដោះស្រាយគ្រប់បញ្ហាបាន

- ពាក្យពិតប្រកបដោយមេត្តា  ជាឱសថដ៏ស័ក្តិសិទ្ធិ

- ពាក្យពិតប្រកបដោយមេត្តា ជាទីស្រលាញ់នៃមនុស្សនិងទេវតា

- ពាក្យពិតប្រកបដោយមេត្តា ឮដល់ទីណាប្រយោជន៍ផ្សាយដល់ទីនោះ

- ពាក្យពិតប្រកបដោយមេត្តា  មានតម្លៃថ្លៃជាងមាសពេជ្រ

- ពាក្យពិតប្រកបដោយមេត្តា  អាចធ្វើឲ្យមនុស្សមានស្មារតីល្អមិនខ្លាចអ្នកដទៃ

- ពាក្យពិតប្រកបដោយមេត្តា  ធ្វើឲ្យញាតិមិត្តមិនបែកបាក់សាមគ្គី

-ពាក្យពិតប្រកបដោយមេត្តា  អាចនាំមនុស្សជាច្រើនឲ្យធ្វើល្អបាន

- ពាក្យពិតប្រកបដោយមេត្តា  ជាគុណធម៌ប្រចាំជីវិត

- ពាក្យពិតប្រកបដោយមេត្តា  មានក្លិនក្រអូបជាងផ្កាឈើនិងខ្លឹមចន្ទន៍ជាដើម គឺក្រអូបបញ្ច្រាសខ្យល់

- ពាក្យពិតប្រកបដោយមេត្តា  រក្សាតម្លៃខ្លួនរហូតមិនឲ្យថោកថយ

- ពាក្យពិតប្រកបដោយមេត្តា  ជារសជាតិផ្អែមឆ្ងាញ់នៃអ្នកស្តាប់

- ពាក្យពិតប្រកបដោយមេត្តា ជាទ្រព្យដ៏ប្រសើររបស់បណ្ឌិត

**សច្ចំ ហវេ សាធុតរំ រសានំ**

ពាក្យសច្ចមានរស លើសរសទាំងពួង

៙ 🕮 ៚

## ប្រៀបធៀបមនុស្សនិងឱសថ

ថ្នាំឱសថមានកិច្ចព្យាបាលរក្សាអ្នកជម្ងឺ ឲ្យបានសុខស្រួលឡើងវិញយ៉ាងណាមនុស្សល្អជាអ្នកមានសីលមានសម្ដីផ្អែមពីរោះពិតប្រាកដមានធម៌ក្នុងខ្លួន មនុស្សនោះអាចជា ឱសថដ៏ប្រសើរសម្រាប់ព្យាបាលរោគផ្លូវចិត្តរបស់ញាតិមិត្តឲ្យបានធូរស្រាលអស់នូវសេចក្ដីកង្វល់សេចក្ដីស្មុគស្មាញតាមផ្លូវចិត្តឲ្យបានជាស្រឡះសះស្បើយ។

- មនុស្សល្អជាឱសថដ៏ប្រសើរ
- មនុស្សអាក្រក់ជាមេរោគដ៏កំណាច
- ម្ដាយឪពុកល្អជាអ្នកមានសីលជាដើម ជាថ្នាំកែរោគកូនប្រុសស្រី
- ម្ដាយឪពុកទ្រុស្តសីល ជាថ្នាំពុលសម្រាប់កូនប្រុសស្រី
- កូនប្រុសស្រីល្អ ជាថ្នាំកែរោគរបស់ឪពុកម្ដាយ
- កូនប្រុសស្រីអាក្រក់ មានមារយាទថោកទាបជាថ្នាំពុលបំពុល

ម្ដាយឪពុកខ្លួនឯង

- ភរិយាល្អ គឺជាឱសថដ៏ប្រសើរ ព្យាបាលរោគផ្លូវចិត្តរបស់ស្វាមី
- ស្វាមីល្អ គឺជាឱសថដ៏ប្រសើរ ព្យាបាលរោគផ្លូវចិត្តរបស់ភរិយា
- ភរិយាមិនល្អ គឺជាថ្នាំពុល បំពុលចិត្តស្វាមី
- ស្វាមីមិនល្អ គឺជាថ្នាំពុល បំពុលចិត្តភរិយា
- ពុទ្ធសាវ័កល្អ គឺជាឱសថដ៏ប្រសើរធ្វើឲ្យ ព្រះពុទ្ធសាសនារុងរឿង
- ពុទ្ធសាវ័កមិនល្អ ជាថ្នាំបំពុលសាសនា ធ្វើឲ្យសាសនារោយរាយ
- មនុស្សល្អ ជាថ្នាំឱសថដ៏ប្រសើរ ធ្វើឲ្យសង្គមបានសន្តិភាព
- មនុស្សអាក្រក់ ជាថ្នាំបំពុលសង្គមឲ្យវឹកវរមិនឲ្យមានសន្តិភាព
- មនុស្សមានចំណេះដឹងល្អ ជាទីពឹងនៃជនជាច្រើន

**បញ្ញាជីវី ជីវិត មាហុសេដ្ឋំ**

ជីវិតប្រកបដោយបញ្ញា គឺជាជីវិតដ៏ប្រសើរ

៚ 📖 ៙

## ចង់ត្រជាក់កុំឱបភ្លើង

មនុស្សយើងម្នាក់ៗត្រូវការសភាពត្រជាក់ចិត្តចង់បាននូវ សេចក្ដីស្ងប់ចិត្ត ហើយគិតធ្វើយ៉ាងណា ឲ្យខ្លួនបានសប្បាយចិត្ត

ជារៀងរាល់ថ្ងៃ  បុគ្គលខ្លះគិតដូច្នេះហើយក៏ទៅដើរលេងតាមឆ្នេរ សមុទ្រខ្លះ  ព្រៃភ្នំខ្លះ  ទៅកាន់ប្រាសាទបុរាណខ្លះ  ទៅកាន់ឧទ្យាន ផ្កាតូច ធំខ្លះ ទៅកាន់ស្រុកឆ្ងាយជិតខ្លះ ទៅមើលល្បែងរបាំច្រៀង រាំខ្លះ  ស្តាប់តន្ត្រីខ្លះ  ជិះយានជំនិះតាមដងវិថីតូចធំខ្លះទៅកាន់ទី ផ្សារលក់ទំនិញខ្លះរហូតដល់  ហ៊ានបរិភោគទឹកស្រវឹង  ទៀតផង ប៉ុណ្ណោះ  ជាដើម  គឺដើម្បីឲ្យខ្លួនបានសប្បាយ បានត្រជាក់ចិត្តរួច ផុតអំពីគំនរភ្លើងគឺសេចក្តីទុក្ខសោក ប៉ុន្តែការដើរទេសចរណ៍ទាំងអស់ នេះមិនអាចបានធូរស្រាលអំពីសេចក្តីទុក្ខសោកបានឡើយ  ឬបើ បានធូរស្រាលខ្លះនោះក៏បានបន្តិចបន្តួចប៉ុណ្ណោះប្រៀបដូចជាថ្នាំ ស្ពឹកដែលគេចាក់ដើម្បីកុំឲ្យឈឺក្នុងរយៈពេលខ្លី គឺ១ម៉ោង២ម៉ោង ឬ  ១ថ្ងៃប៉ុណ្ណោះ  ដូច្នេះការដើរគ្រប់ទីកន្លែងមិនមែនជាដំណោះ ស្រាយធ្វើឲ្យធូរស្រាលបានត្រជាក់ចិត្តដូចជាការធ្វើទានរក្សាសីល ចំរើនមេត្តាចិត្តព្រោះការរក្សាសីលជាដើមទើបអាចរំលត់នូវសភា- ពក្តៅក្រហាយក្នុងចិត្តបាន  គប្បីជ្រាបថាសេចក្តីសុខមិនមែននៅ ឆ្ងាយអំពីក្នុងចិត្តរបស់ខ្លួនទេ  ហើយសេចក្តីទុក្ខ  ក៏នៅក្នុងចិត្តដែរ ដូច្នេះការត្រាច់ទៅកាន់ទីឆ្ងាយៗ  ក៏មានចិត្តរួមដំណើរទៅជាមួយ ដែរ  ដូច្នេះសេចក្តីទុក្ខក៏វាមាននៅក្នុង  ទីនោះបើមានបញ្ហានៅទី

បញ្ញានៅទីនោះ បញ្ញានោះឯងក៏រំលត់នូវសេចក្តីទុក្ខនោះបាន ។

- មិនត្រជាក់ទេ បើនៅតែឱបភ្លើង
- មិនត្រជាក់ទេ បើនៅតែប្រកាន់
- មិនត្រជាក់ទេ បើនៅតែជាប់ជំពាក់
- មិនត្រជាក់ទេ បើនៅតែខឹងក្រោធច្រើន
- មិនត្រជាក់ទេ បើនៅតែមានគំនិតខូច
- មិនត្រជាក់ទេ បើនៅតែមានគំនិតយល់ខុស
- មិនត្រជាក់ទេ បើនៅតែច្រណែនអ្នកដទៃ
- មិនត្រជាក់ទេ បើនៅតែទ្រុស្តសីល
- មិនត្រជាក់ទេ បើមិនមានបញ្ញា

**នត្ថិ សន្តិ បរំ សុខំ**

ពុំមានសេចក្តីសុខដទៃ ក្រៅអំពីសេចក្តីស្ងប់ឡើយ ។

៙ 🕮 ៚

## មានសម្បត្តិតែក្របុណ្យ

មនុស្សក្នុងលោក អ្នកដែលមានទ្រព្យសម្បត្តិច្រើនក៏មានច្រើននាក់ ដូចជាសេដ្ឋី គហបតី អ្នកមានដីស្រែចំការ រថយន្ត តូចធំ មាសប្រាក់ជាច្រើន និងអ្នកបម្រើប្រុសស្រីទៀតផង បុគ្គលនោះ

នៅតែមិនមានឱកាស  ដើម្បីបំពេញបុណ្យកុសលសំរាប់ជាទីពឹងរបស់ខ្លួនស្ថិតនៅក្នុងសភាពកំណាញ់រិះស្ងិតស្វាញរហូតអស់ជីវិតនេះហើយហៅថា មានសម្បត្តិតែក្របុណ្យ ។

ព្រះដ៏មានព្រះភាគជាម្ចាស់  ទ្រង់ត្រាស់ថា  ទ្រព្យសម្បត្តិជាសត្រូវសំរាប់ម្ចាស់ទ្រព្យអត់បញ្ញា ។

គួរពិចារណាឃើញនូវទោសនៃទ្រព្យសម្បត្តិដូចតទៅ

- ទ្រព្យសម្បត្តិ ជាថ្នាំពិស សំរាប់ម្ចាស់ទ្រព្យអត់បញ្ញា
- ទ្រព្យសម្បត្តិ ជាគំនរភ្លើងដ៏ធំ សំរាប់ម្ចាស់ទ្រព្យអត់បញ្ញា
- ទ្រព្យសម្បត្តិ គឺជាអ្នកពិឃាត សំរាប់ម្ចាស់ទ្រព្យអត់បញ្ញា
- ទ្រព្យសម្បត្តិ ជាថ្នាំញៀន សំរាប់ម្ចាស់ទ្រព្យអត់បញ្ញា
- ទ្រព្យសម្បត្តិ ជាចំណងដ៏មាំ សំរាប់ម្ចាស់ទ្រព្យអត់បញ្ញា
- ទ្រព្យសម្បត្តិ ជាជំងឺដ៏ធ្ងន់ សំរាប់ម្ចាស់ទ្រព្យអត់បញ្ញា
- ទ្រព្យសម្បត្តិ ជាអមនុស្សកាច សំរាប់ម្ចាស់ទ្រព្យអត់បញ្ញា
- ទ្រព្យសម្បត្តិ ជាចោរដ៏កាច សំរាប់ម្ចាស់ទ្រព្យអត់បញ្ញា
- ទ្រព្យសម្បត្តិ ជាដាវដ៏មុត សំរាប់ម្ចាស់ទ្រព្យអត់បញ្ញា
- ទ្រព្យសម្បត្តិ ជារាត្រីអន្ធការ សំរាប់ម្ចាស់ទ្រព្យអត់បញ្ញា

## សម្បត្តិ វិបត្តតោ

សម្បត្តិទាំងឡាយមិនអាចរួចផុតអំពីវិបត្តិបានឡើយ ។

សូមជ្រាបថា ការបានធ្វើទានគឺជាការធ្វើចិត្តឲ្យទូលាយរួចផុតអំពីចំណង ។

## មានមេត្តាគឺមានសុជីវធម៌

មេត្តាចិត្ត មាននៅក្នុងសន្តាននៃបុគ្គលណា ធ្វើឲ្យបុគ្គលនោះចេះចែករំលែកនូវសេចក្តីសុខដល់ជនទាំងឡាយទាំងពួងចេះមានសុជីវធម៌ក្នុងការរស់នៅ ចេះគោរពកោតក្រែងដល់ជនដទៃចេះដឹងទោសកំហុសរបស់ខ្លួន ។

☞ សូមមេត្តា គឺជាការសំណូមពរដូចតទៅ

- សូមមេត្តា គោរពគ្នាទៅវិញទៅមកផង
- សូមមេត្តា កុំបង្ខំគេធ្វើឲ្យគេកើតទុក្ខ
- សូមមេត្តា កុំបើកបរយានយន្តឲ្យលឿនហួសទំនងពេក
- សូមមេត្តាកុំប្រើសម្លេងទូរស័ព្ទឬនិយាយឮពេកនាំឲ្យរំខានដល់អ្នកដទៃ

- សូមមេត្តាកុំបើកសម្លេងម៉ាញ៉េទូរទស្សន៍ជាដើមឮពេក នាំឲ្យរំខានដល់អ្នកដទៃ

- សូមមេត្តា លាងដៃឲ្យស្អាតជាមុនសិនចាំបរិភោគអាហារ
- សូមមេត្តា កុំជដែកគ្នាច្រើនពេក ពេលបរិភោគអាហារ
- សូមមេត្តា ចេះដោះទ្រនាប់ជើងក្នុងទីកន្លែងដែលគួរដោះ ដូចជាឡើងលើទីលានព្រះចេតិយ៍ ព្រះពោធិព្រឹក្ស ព្រះវិហារជាដើម

- សូមមេត្តា ចេះដោះមួកពេលចូលក្នុងវត្តជាដើមផង
- សូមមេត្តា កុំខាកស្ដោះដាក់លើទីកន្លែងដែលស្អាតធ្វើឲ្យគេខ្ពើមរអើម

- សូមមេត្តា កុំប្រើគ្រឿងសាស្ត្រាវុធផ្សេងៗក្នុងការដោះស្រាយបញ្ហាដែលប្រកបដោយសេចក្ដីក្រេវក្រោធ

- សូមមេត្តា ដឹងគុណចំពោះអ្នកមានគុណផង
- សូមមេត្តា កុំធ្វើឲ្យអ្នកមានគុណកើតទុក្ខ

- សូមមេត្តា កុំចេះតែតិះដៀលមនុស្សល្អ
- សូមមេត្តា កុំប្រណែនគេ ព្រោះវាគ្មានប្រយោជន៍
- សូមមេត្តា ចេះមើលកំហុសរបស់ខ្លួនឯងផង
- សូមមេត្តា គិតឃើញអំពើល្អរបស់អ្នកដទៃផង
- សូមមេត្តា ចេះគោរពពេលវេលាឲ្យបានទៀងទាត់ផង
- សូមមេត្តា ចេះសម្អាតទឹកន្ទៀងរូមផង
- សូមមេត្តា ចេះរក្សាសម្បត្តិជាតិផង
- សូមមេត្តា ចេះទទួលរាក់ទាក់ភ្ញៀវដែលមកដល់ផ្ទះផង
- សូមមេត្តា ចេះដាក់បាត្រព្រះសង្ឃនៅមុខផ្ទះនៃខ្លួនផង
- សូមមេត្តា កុំសម្លាប់សត្វព្រោះនាំឲ្យខ្លួនមានអាយុខ្លី
- សូមមេត្តា កុំលួចទ្រព្យគេព្រោះនាំឲ្យខ្លួនក្រីក្រជាដើម
- សូមមេត្តាកុំប្រព្រឹត្តខុសក្នុងកាមព្រោះនាំឲ្យខ្លួនមានឈ្មោះ

មិនល្អ មិនមានសេចក្តីសុខក្នុងគ្រួសារ

- សូមមេត្តា កុំនិយាយកុហកគេ នាំឲ្យគេស្អប់ខ្លួន
- សូមមេត្តា កុំផឹកទឹកស្រវឹងព្រោះនាំឲ្យខ្លួនវង្វេងអស់ស្មារតី
- សូមមេត្តា កុំសេពគ្រឿងញៀនព្រោះវានាំឲ្យខូចខ្លួន

- សូមមេត្តា កុំលេងល្បែងភ្នាល់ព្រោះនាំឲ្យខ្លួនក្តៅក្រហាយ
- សូមមេត្តា កុំសេពគប់មិត្តអាក្រក់វានាំឲ្យខ្លួនអាក្រក់ដែរ
- សូមមេត្តា កុំដើរលេងយប់ជ្រៅពេក ព្រោះនាំឲ្យគេចោទប្រកាន់ក្នុងរឿងមិនល្អ
- សូមមេត្តា កុំខ្ចីប្រាក់គេច្រើនពេក ប្រសិនបើមិនមានអ្វីសំរាប់សងគេទេ ព្រោះនាំឲ្យខ្លួនកើតទុក្ខ
- សូមមេត្តា ចេះគោរពពាក្យសន្យារបស់ខ្លួនផង
- សូមមេត្តា កុំស្រឡាញ់លុយ ជាងស្រលាញ់ញាតិមិត្ត
- សូមមេត្តា កុំស្រលាញ់លុយ ជាងស្រឡាញ់សេចក្តីល្អ
- សូមមេត្តា កុំធ្វើជាមនុស្សចេះតែរករឿងគេច្រើនពេក
- សូមមេត្តា កុំគិតថាមានតែខ្លួនទេដែលចេះដឹងនោះ
- សូមមេត្តា កុំធ្វើជាមនុស្សចង់តែឈ្នះគេឲ្យសោះ
- សូមមេត្តា លះបង់នូវអំនួតរបស់ខ្លួនចេញផង
- សូមមេត្តា ចេះធ្វើបុណ្យឧទ្ទិសកុសលដល់បុព្វការីជនផង
- សូមមេត្តា ធ្វើបុណ្យដោយគោរពផង

- សូមមេត្តា គិតថាមនុស្សយើងមានអាយុខ្លីណាស់មិនគួរធ្វើអំពើបាបឡើយ
- សូមមេត្តា  គិតថាមនុស្សអាក្រក់ដែលជួបយើងហើយជា

មេរៀនខន្តីរបស់យើង

- សូមមេត្តា ធ្វើជាម្តាយឪពុកល្អរបស់កូនប្រុសស្រី
- សូមមេត្តា ធ្វើជាកូនប្រុសស្រីល្អរបស់ម្តាយឪពុក
- សូមមេត្តា ធ្វើស្វាមីល្អរបស់ភរិយា
- សូមមេត្តា ធ្វើជាភរិយាល្អរបស់ស្វាមី
- សូមមេត្តា ធ្វើជាគ្រូល្អរបស់សិស្ស
- សូមមេត្តា ធ្វើជាសិស្សល្អរបស់គ្រូ
- សូមមេត្តា ធ្វើជាមិត្តល្អរបស់មិត្ត
- សូមមេត្តា ធ្វើជាពុទ្ធបរិស័ទល្អរបស់ព្រះពុទ្ធជាម្ចាស់
- សូមមេត្តា ធ្វើជាមនុស្សល្អសម្រាប់សង្គម
- សូមមេត្តា អានសៀវភៅធម៌ឲ្យបានច្រើនផង
- សូមមេត្តា ឃើញនូវលោកធម៌ ថាជារបស់មិនទៀង
- សូមមេត្តា លះបង់នូវឧបាទានដើម្បីរួចផុតចាកទុក្ខ ។

- *សូមមេត្តា សូមមេត្តា សូមមេត្តាផងណា !!!*

## *ការប្រណែនអ្នកដទៃ គឺជាការសម្លាប់ខ្លួនឯង*

*ហេតុអ្វីបានជាសត្វលោកយើង ឃើញគេមានសេចក្ដីសុខ មានយសជាដើមហើយក៏ប្រណែននឹងអ្នកដទៃនោះៗ មកអំពីក្នុងចិត្តមិនមានមេត្តាគឺសេចក្ដីរាប់អាន មិនមានមុទិតាគឺសេចក្ដីត្រេកអរតាមនៅពេលដែលអ្នកដទៃមានសេចក្ដីសុខជាដើម គួរពិចារណាតាមព្រះពុទ្ធដីកាថា* ***អ្នកណាៗ ក៏ធ្លាប់ជាមាតាបិតា ជាញាតិរបស់ខ្លួនដែរក្នុងសង្សារវដ្តកន្ទងមកអស់កាលដ៏យូរអង្វែងរាប់ជាតិប្រមាណមិនបាន*** *ដូច្នេះហើយ បើយើងប្រណែនស្អប់ខ្ពើមនឹងអ្នកដទៃ ហាក់ដូចជាស្អប់ប្រណែននិងមាតាបិតាបង្កើត បងប្អូនបង្កើតរបស់ខ្លួនដូច្នោះ សូមមេត្តាពិចារណានូវទោស កំហុសនៃសេចក្ដីប្រណែនមានច្រើនណាស់ ដូចជា*

- *សេចក្ដីប្រណែន អាចនាំឲ្យបែកបាក់ញាតិមិត្ត*
- *សេចក្ដីប្រណែន អាចធ្វើឲ្យខ្លួនសាងកម្មពៀរវេរាដ៏ច្រើន*
- *សេចក្ដីប្រណែន អាចធ្វើឲ្យខ្លួនវិកលចរិត (ឆ្កួត)*
- *សេចក្ដីប្រណែន អាចធ្វើឲ្យខ្លួនអស់សតិបញ្ញា*

- សេចក្តីប្រណែន អាចធ្វើឲ្យខ្លួនចេះរមិលគុណអ្នកដទៃ
- សេចក្តីប្រណែន អាចធ្វើឲ្យខ្លួនចេះនិយាយញុះញង់
- សេចក្តីប្រណែន អាចធ្វើឲ្យខ្លួនហ៊ានសម្លាប់គ្នានិងសម្លាប់

ខ្លួនឯងបាន

- សេចក្តីប្រណែន អាចធ្វើឲ្យខ្លួនស្អប់មនុស្សល្អ
- សេចក្តីប្រណែន អាចធ្វើឲ្យខ្លួនអស់ញាតិមិត្ត
- សេចក្តីប្រណែន អាចធ្វើឲ្យខ្លួនអស់កិត្តិយស
- សេចក្តីប្រណែន មិនអាចធ្វើឲ្យខ្លួនញញឹមបានទេ
- សេចក្តីប្រណែន អាចធ្វើឲ្យខ្លួនទៅកាន់អបាយភូមិ
- សេចក្តីប្រណែន អាចធ្វើឲ្យខ្លួនកើតក្នុងត្រកូលថោកទាប
- សេចក្តីប្រណែន អ្នកដទៃជាចំនុចខ្សោយរបស់ខ្លួន
- សេចក្តីប្រណែន គឺជា អកុសលប្រចាំជីវិត
- សេចក្តីប្រណែន ធ្វើឲ្យវិនាសចាកសីលគុណជាដើម
- សេចក្តីប្រណែន មិនអាចឃើញសច្ចធម៌បាន
- សេចក្តីប្រណែន អាចធ្វើឲ្យខ្លួនវិនាសដូចភិក្ខុទេវទត្ត

មុទិតាជាធម៌សម្លាប់សេចក្តីប្រណែនបាន

## ក្នុងខ្លួនគ្មានមេត្តា ដូចស្រុកគ្មានភ្លៀង

ស្រុក ឬ ជនបទមួយដែលគ្មានទឹកភ្លៀងស្រុកនោះក៏ ហួតហែងក្រៀមស្រពោនមិនមានសម្រស់ស្រស់បំព្រងគួរជាទីពិចពិលរមិលមើលឡើយ មនុស្សសត្វទាំងឡាយ នៅក្នុងស្រុកនោះ ក៏ភៀសខ្លួនចេញទៅស្រុកដទៃដែលមានភ្លៀងធ្លាក់ ដើម្បីចិញ្ចឹមជីវិតរបស់ខ្លួនបន្តទៀត នេះជាសេចក្តីប្រៀបធៀបឲ្យឃើញថា បើក្នុងខ្លួនយើងគ្មានចិត្តមេត្តាដល់សត្វទាំងឡាយទេ សត្វទាំងឡាយមិនអាចនៅជិតខ្លួនឬនៅជាមួយខ្លួនបានទេ ពួកគេទាំងអស់នឹងទៅឲ្យឆ្ងាយអំពីខ្លួនយើងព្រោះយើងជាមនុស្សក្តៅហួតហែងគ្មានមេត្តា។

ដូច្នេះមេត្តាតាមផ្លូវកាយវាចាចិត្តរបស់យើង ដូចជាទឹកដ៏ត្រជាក់សម្រាប់ស្រោចស្រពលើខ្លួនឯង និងអ្នកដទៃ ឲ្យបានសេចក្តីសុខ ឲ្យបាននូវប្រយោជន៍គ្រប់បែបយ៉ាង អំពីខ្លួនដែលជាអ្នកមានមេត្តា ។

- អ្នកមានមេត្តាចិត្ត គឺមានសេចក្តីសុខគ្រប់ឥរិយាបថទាំង៤
- អ្នកមានមេត្តាចិត្ត ដូចជាស្រុកដែលមិនខ្វះដោយទឹក
- អ្នកមានមេត្តាចិត្ត ត្រជាក់ដូចជាកូននៅជិតម្តាយ

- អ្នកមានមេត្តាចិត្ត ដូចត្រីដែលនៅក្នុងទឹកត្រជាក់ល្អ
- អ្នកមានមេត្តាចិត្ត ក្រអូបដូចជាក្លិនផ្កាឈូកជាដើម
- អ្នកមានមេត្តាចិត្ត ប្រសើរជាងមាសប្រាក់ទ្រព្យសម្បត្តិ
- អ្នកមានមេត្តាចិត្ត ដូចព្រះរាជាទ្រង់គ្រឿងដ៏ល្អអស្ចារ្យ
- អ្នកមានមេត្តាចិត្ត ដូចជានាវាដ៏ធំសម្រាប់ចម្លងសត្វ
- អ្នកមានមេត្តាចិត្ត ដូចស្រុកគ្មានចោរ ឬសត្រូវបៀតបៀន
- អ្នកមានមេត្តាចិត្ត អាចគេចរួចផុតអំពីគ្រោះថ្នាក់ផ្សេងៗ
- អ្នកមានមេត្តាចិត្ត គឺជាអ្នកមានសីលសមាធិជាដើម
- អ្នកមានមេត្តាចិត្ត គឺនៅជិតស្ពានសួគ៌និងព្រះនិព្វាន

ការចម្រើនមេត្តាចិត្ត  គឺជាការលះបង់នូវសេចក្តីក្រោធឲ្យបានរឿយៗ ។

កោធំ ឃត្វា សុខំ សេតិ

សម្លាប់សេចក្តីក្រោធបានទើបដេកជាសុខ ។

មេត្តម្ពុនា សទោសោ  ច បរទោសោ ច សម្មតិ

មេត្តាសេកេន សព្វេសុ  សព្វតោគ្គឹ និវារសេ

សេចក្តីក្រោធរបស់ខ្លួននិងរបស់អ្នកដទៃ រមែង

ស្ងប់ដោយទឹកគឺមេត្តា បុគ្គលគប្បីហាមភ្លើង

គឺសេចក្ដីក្រោធ ក្នុងទីទាំងពួង ដោយការស្រោច

ស្រពទឹកគឺមេត្តា ក្នុងសព្វសត្វ (ទាំងអស់) ។

មេត្តាគឺសេចក្ដីរាប់អានបានដល់អទោសចេតសិកមានស-
ភាពមិនប្រទូស្តរាយក្នុងអារម្មណ៍ មិនមានសេចក្ដីក្រោធ មិនមាន
សេចក្ដីបៀតបៀន ជាឫសគល់នៃកុសលធម៌ ។

## លក្ខណាទិចតុក: របស់អទោស ឬមេត្តា

- **អចណ្ឌិកលក្ខណោ** មានការមិនប្រទូស្តរាយ ជាលក្ខណ:
- **អាឃាតវិនយរសោ** មានការកំចាត់បង់នូវអាឃាត

(គឺសេចក្ដីក្រោធ) ជាកិច្ច

- **សោមភាវបច្ចុបដ្ឋានោ** មានសភាពត្រជាក់ថ្ងូរផង់ជាផល ឬ

ជារស

- **យោនិសោមនសិការបទដ្ឋានោ** មានការធ្វើទុកក្នុងចិត្ត

ដោយឧបាយត្រូវទំនងជាហេតុជិត ឬជាគ្រឿងទ្រ

## មេត្តាពោលដោយអត្ថ

ធម្មជាតិណា រមែងស្រលាញ់ សំដៅសេចក្តីថា មានក្តីអា-ល័យ (រាប់អាន) ហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា មេត្តា (ប្រែថា ធម្មជាតិជាទីស្រលាញ់) ន័យម្យ៉ាងទៀតថា ធម្មជាតិនោះ មាននៅក្នុងមិត្ត ឬថា រមែងប្រព្រឹត្តទៅដល់មិត្តហេតុនោះធម្មជាតិ នោះទើបឈ្មោះថា មេត្តា ប្រែថា ធម្មជាតិដែលមាននៅក្នុងមិត្ត ។

## មេត្តាពោលដោយលក្ខណៈ ជាដើម

មេត្តា មានការប្រព្រឹត្តទៅដោយអាការ (គិត) អនុគ្រោះ (ដល់សត្វទាំងឡាយ)ជាលក្ខណ(គឺមានការញុំាងអាការអនុគ្រោះ ឲ្យប្រព្រឹត្តទៅជាលក្ខណៈ)

មានការនាំយកប្រយោជន៍ជាទីអនុគ្រោះចូលទៅឲ្យជារស (គឺជាកិច្ច) មានការនាំសេចក្តីអាឃាត (ព្យាបាទ) ចេញទៅបានជា គ្រឿងប្រាកដ (ផល) មានការសម្លឹងឃើញសេចក្តីទុក្ខនៃសត្វទាំង ឡាយជាទីគួរចំរើនចិត្តជាហេតុជិត សេចក្តីរម្ងាប់ទៅនៃព្យាបាទ (ដោយអំណាចវិក្ខម្ភនបហាន) ជាសម្បត្តិ (គឺសេចក្តីត្រឹមត្រូវនៃ មេត្តានោះ) សេចក្តីកើតឡើងនៃស្នេហា (គឺក្លាយជាសេចក្តីស្រ-លាញ់ដោយតណ្ហាទៅវិញ) ជាវិបត្តិនៃមេត្តានោះ ។

## មេត្តាពោលដោយប្រយោជន៍

ក៏ឯវិបស្សនាសុខ (សេចក្តីសុខក្នុងវិបស្សនាក្តី) ភពសម្បត្តិក្តី ជាប្រយោជន៍ទូទៅ ការកម្មាត់បដិបក្ខធម៌ មានព្យាបាទជាដើម បានជាប្រយោជន៍ចំពោះសភាព នៃព្រហ្មវិហារធម៌ទាំងនោះ ប្រាកដណាស់ ក្នុងព្រហ្មវិហារ៤នោះ មេត្តាមានការកម្មាត់ព្យាបា-ទបានជាប្រយោជន៍ សមដូចព្រះសារីបុត្រពោលទុកថាម្នាល អាវុសោ វត្ថុដែលជាផ្លូវចេញទៅនៃព្យាបាទ ក៏គឺមេត្តាចេតោវិមុត្តិ។

## សត្រូវជិតនិង ឆ្ងាយរបស់មេត្តា

រាគៈជាសត្រូវជិតរបស់មេត្តាព្រហ្មវិហារ ព្រោះសភាព នៃមេត្តាជាមួយរាគ មានចំណែកស្មើគ្នាដោយសម្ទីងមើលតែចំពោះចំណែកនៃសេចក្តីល្អ ដូចសត្រូវរបស់មនុស្សដែលតាំងមូលដ្ឋាននៅជិត មូលដ្ឋាននោះរមែងបានចេញចូល ដោយងាយព្រោះហេតុនោះ មេត្តាគឺព្រះយោគាវចរ ត្រូវតែថែរក្សាឲ្យល្អ (ឲ្យឆ្ងាយ) គឺឲ្យឆ្ងាយអំពីរាគ ចំណែកព្យាបាទជាសត្រូវឆ្ងាយ ( របស់មេត្តា ) ព្រោះមេត្តាជាមួយនឹងព្យាបាទមាន (សភាព)ជាចំណែករបស់ខ្លួនដែលមិនស្មើគ្នា ដូចសត្រូវរបស់មនុស្សដែលតាំងមូលដ្ឋាននៅក្នុងព្រៃភ្នំជាដើម ព្រោះដូច្នោះ ព្រះយោគាវចរ ទើបមិនត្រូវខ្លាចអំពីសំណាក់នៃព្យាបាទនោះ ហើយចំរើនមេត្តាទៅចុះ ។

ក្នុងសេចក្តីថា បុគ្គលចំរើនមេត្តាផងធ្វើអាការក្រោធឲ្យប្រ-ព្រឹត្តទៅផង នោះជាអឋាន (គឺប្រព្រឹត្តទៅមិនបានឡើយ) ។

ខាងដើម កណ្តាល ទីបំផុត អារម្មណ៍និងការពង្រីកផ្សាយអារម្មណ៍នៃព្រហ្មវិហារ

ក្នុងន័យម្យ៉ាងថា ព្រហ្មវិហារទាំង៤នោះ មានក្នុងកត្តុកាមឆន្ទ (ឆន្ទគឺសេចក្តីប្រាថ្នានិងធ្វើ) ជាខាងដើម មានការបន្ទោបង់ (គឺលះបង់ ) ជាកណ្តាល មានអប្បមានា ជាទីបំផុត ដោយអំណាចបញ្ញត្តិធម៌ ចាត់ថា មានឯកសត្វជាអារម្មណ៍ ឬថា (ដោយសម្បត្តិធម៌) មានអនេកសត្វជាអារម្មណ៍ កាលបើដល់ឧបចារ ឬអប្បនាហើយ ការពង្រីកអារម្មណ៍ទើបមាន ។

ក្នុងការពង្រីកអារម្មណ៍នោះ បណ្ឌិតគប្បីជ្រាបលំដាប់នៃការពង្រីកផ្សាយ (មេត្តាដូចតទៅ)នេះ ឧបមាដូចជាអ្នកស្រែដែលច្លាត កំណត់ទី(ទំហំគោលដៅ)ដែលត្រូវភ្ជួរហើយទើបភ្ជួរទៅយ៉ាងណា ព្រះយោគាវចរក៏យ៉ាងនោះ មុនដំបូងគប្បីកំណត់យកផ្ទះមួយខ្នង (ទីលំនៅរបស់ជនមួយគ្រួសារ) ហើយចំរើនមេត្តាទៅក្នុងសត្វទាំងឡាយក្នុងផ្ទះនោះ ដោយន័យថា សូមសត្វទាំងឡាយក្នុងផ្ទះនេះ ចូរជាអ្នកមិនមានពៀរចុះ ជាដើម ធ្វើចិត្តឲ្យទន់ គួរដល់

ក្នុងការភាវនាចំពោះផ្ទះមួយខ្នងនោះ ហើយទើបកំណត់ពីរខ្នង បន្ទាប់ពីនោះ ទើបកំណត់ ៣-៤-៥-៦-៧-៨-៩-១០ ខ្នងហើយ ផ្សាយទៅផ្លូវមួយខ្សែ ពាក់កណ្ដាលស្រុក ស្រុកមួយ រាជាណាចក្រមួយប្រទេសមួយ ជនបទមួយ ទិសមួយ ដោយន័យដូច្នេះ ចូរធ្វើទាំងចក្រវាឡមួយ ឬថានឹងគប្បី ចំរើនមេត្តាទៅក្នុងសត្វទាំងទាំងឡាយនោះៗ ក្រៃលែងជាងនោះទៅទៀតក៏បាន ព្រហ្មវិហារដទៃទៀត មានករុណាព្រហ្មវិហារជាដើម ក៏គប្បីចំរើនដោយន័យដូចគ្នានោះ ឯង នេះជាលំដាប់នៃការ ពង្រីកអារម្មណ៍ក្នុងព្រហ្មវិហារ ភាវនានោះ ។

## នីវរណធម៌៥

បញ្ចមេ ភិក្ខវេ នីវរណា អន្ធករណា
អចក្ខុករណា អញ្ញាណា បញ្ញានិរោធិយា
វិឃាតបក្ខិយា អនិព្វានសំវត្តនិវត្តនិកា ។

ម្នាលភិក្ខុទាំងឡាយ ក្នុងនីវរណ៥ប្រការនេះ ជាធម្មជាតិធ្វើឲ្យខ្វាក់ ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យដឹង ជាហេតុរលត់ទៅនៃបញ្ញា ជាបក្សពួកនៃសេចក្ដីចង្អៀតចង្អល់ មិនមែនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។

នីវរណធម៌៥គឺ កាមច្ឆន្ទនីវរណៈ ព្យាបាទនីវរណៈថីនមិទ្ធនីវរណៈឧទ្ធច្ចកុក្កុច្ចនីវរណៈវិចិកិច្ឆានីវរណៈជាធម្មជាតិធ្វើឲ្យខ្វាក់ ធ្វើមិនឲ្យមានចក្ខុ ធ្វើមិនឲ្យដឹង ជាហេតុរលត់ទៅនៃបញ្ញា ជាបក្សពួកនៃសេចក្ដីចង្អៀតចង្អល់ មិនមែនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន។

សេចក្ដីប្រៀបធៀបនៃនីវរណៈ

១ កាមឆន្ទនីវរណ ប្រៀបដូចជាភាជន៍ដាក់ទឹក ដែលលាយពណ៌ផ្សេងៗ (មិនអាចឆ្លុះមើលមុខជាដើមបាន)

២ ព្យាបាទនីវរណ ប្រៀបដូចជាភាជន៍ដាក់ទឹកដែលកំពុងតែពុះកញ្ជ្រោល

៣ ថីនមិទ្ធនីវរណ ប្រៀបដូចជាភាជន៍ដាក់ទឹកដែលពេញទៅដោយសារាយ និងចក

៤ ឧទ្ធច្ចកុក្កុច្ចនីវរណ ប្រៀបដូចជាភាជន៍ដាក់ទឹកដែលត្រូវខ្យល់ធ្វើឲ្យញ័ររំជួយ

៥ វិចិកិច្ឆានីវរណ ប្រៀបដូចជាភាជន៍ដាក់ទឹកដែលល្អក់ មិនអាចឆ្លុះមើលមុខរបស់ខ្លួនបាន។

សេចក្ដីប្រៀបធៀបម្យ៉ាងទៀត

- **កាមច្ឆន្ទនីវរណៈ** ប្រៀបដូចជាបុរស ជំពាក់បំណុលគេ

- **ព្យាបាទនីវរណៈ** ប្រៀបដូចជាបុរស មានជម្ងឺក្តៅក្រហាយក្នុងខ្លួន

- **ថីនមិទ្ធនីវរណៈ** ប្រៀបដូចជាបុរសជាប់គុកមិនមានសេរីភាព

- **ឧទ្ធច្ចកុក្កុច្ចនីវរណៈ** ប្រៀបដូចជាបុរស អ្នកបម្រើគេ គឺមានសេចក្តីក្តៅក្រហាយជាច្រើនក្នុងខ្លួន

- **វិចិកិច្ឆានីវរណៈ** ប្រៀបដូចជាបុរសដើរផ្លូវឆ្ងាយហើយបានជួបផ្លូវបែក ជាពីររាវែកចិត្តមិនប្រាកដថាដើរទៅផ្លូវណាមួយ

## អានិសង្សមេត្តា១១យ៉ាង

១ **សុខំ សុបតិ** ដេកលក់ជាសុខ

២ **សុខំ បដិពុជ្ឈតិ** ភ្ញាក់ឡើងជាសុខ

៣ **ន បាបកំ សុបិនំ បស្សតិ** មិនយល់សប្តិអាក្រក់

៤ **មនុស្សានំ បិយោ ហោតិ** ជាទីស្រឡាញ់របស់ពួក

មនុស្ស

៥ **អមនុស្សានំ បិយោ ហោតិ** ជាទីស្រឡាញ់របស់ពួកអមនុស្ស

៦ **ទេវតា រក្ខន្តិ** ពួកទេវតាតែងរក្សា

៧ **នស្ស អគ្គិ វា វិសំ វា កមតិ** ភ្លើងក្ដី ថ្នាំពិសក្ដី គ្រឿងសស្ត្រាវុធក្ដី មិនអាចមកជិតកាយ ធ្វើនូវអន្តរាយឡើយ

៨ **តុវដំ ចិត្តំ សមាធិយតិ** ចិត្តរមែងតាំងមាំដោយឆាប់

៩ **មុខវណ្ណោ វិប្បសីទតិ** សម្បុរមុខស្រស់ថ្លា

១០ **អសម្មូឡ្ហោ កាលំ ករោតិ** ជាអ្នកមិនវង្វេងក្នុងពេលធ្វើកាលកិរិយា

១១ **ឧត្តរឹ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ** កាលមិនទាន់ត្រាស់ដឹងនូវគុណធម៌ជាន់ខ្ពស់គឺលោកុត្តរធម៌ទេ រមែងចូលទៅកាន់ព្រហ្មលោក ។

ម្នាលភិក្ខុទាំងឡាយ **មេត្តាចេតោវិមុត្តិ** ដែលបុគ្គលបានសេពគប់ បានចម្រើន បានធ្វើឲ្យច្រើន បានធ្វើឲ្យដូចជាយានបានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំទុកបានប្រារព្ធល្អហើយ អានិសង្សទាំង១១ប្រការនេះ រមែងកើតប្រាកដ ។

## *អធិប្បាយអានិសង្សមេត្តា១១យ៉ាង*

*ព្រះយោគាវចរនេះកាលចម្រើនមេត្តាចេតោវិមុត្តិ តាមផ្លូវអប្បនានោះក្នុងផ្លូវណាមួយ ដូចបានពោលហើយដូច្នេះ ( លោកសម្តែងសមាធិខាងដើមដោយមិនបានយកមកដាក់ក្នុងសៀវភៅនេះទេ ) រមែងបានអានិសង្ស១១ប្រការ ដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកដោយន័យថា អ្នកចំរើនមេត្តាចេតោវិមុត្តិ រមែងដេកលក់ដោយសុខដូច្នេះជាអាទិ៍ ។*

*-ក្នុងអានិសង្ស១១នោះ សេចក្តីថាដេកលក់ជាសុខ មានអធិប្បាយថា ជនទាំងឡាយដែលដេកលក់នោះ ( ដែលមិនបានមេត្តាចេតោវិមុត្តិ ) រមែងប្រែប្រួលកាយទៅវិញទៅមកមុនសិនហើយ ( ទើបដេកលក់ទៀត ) មើលទៅជាទុក្ខយ៉ាងណា លោកអ្នកបានមេត្តាចេតោវិមុត្តិមិនលង់លក់ដូច្នោះទេ រមែងលក់ដោយសប្បាយសូម្បីលក់ស៊ប់ហើយក៏ដូចជាការចូលសមាបត្តិ (អ៊ីចឹង) ។*

*-សេចក្តីថា ភ្ញាក់ឡើងជាសុខ មានអធិប្បាយថា ជនទាំងឡាយដទៃកាលដែលភ្ញាក់ឡើងហើយក៏ធ្វើសំឡេងថ្ងូរ ( ថ្ងូរស្ងាប ) ពត់ខ្លួនផ្អៀងផ្អងចុះឡើងទៅមក មើលទៅជាទុក្ខយ៉ាងណាលោកអ្នកបានមេត្តាចេតោវិមុត្តិ មិនភ្ញាក់ឡើងយ៉ាងនោះទេ គឺរមែងភ្ញាក់*

ឡើងដោយសប្បាយ គឺមិនមានវិការ (អាការខុសផ្សែក) ដូចផ្កាបុទុមរីកហើយដូច្នោះ

-សេចក្តីថា មិនយល់សុបិនអាក្រក់ អធិប្បាយថាលោកអ្នកបានមេត្តាចេតោវិមុត្តិនោះ សូម្បីសុបិនឃើញ ក៏សុបិនតែនិមិត្តដែលល្អ ដូចជាថ្វាយបង្គំព្រះចេតិយ ដូចជាកំពុងធ្វើការបូជា និងដូចជាកំពុងស្តាប់ព្រះធម៌ ចំណែកជនទាំងឡាយដទៃ (សុបិន) ឃើញខ្លួនឯងដូចជាចោរលោមព័ទ្ធ (ចាប់ចង) ដូចជាត្រូវហ្វូងសត្វសាហាវធ្វើអន្តរាយឲ្យ និងដូចជាកំពុងធ្លាក់ (អន្ទង់ជាដើម) យ៉ាងណា លោកអ្នកបានមេត្តាចេតោវិមុត្តិមិនសុបិនឃើញសេចក្តីអន្តរាយយ៉ាងនោះទេ

-សេចក្តីថា ជាទីស្រឡាញ់របស់មនុស្សទាំងឡាយ គឺថាជាទីស្រឡាញ់ពេញចិត្តរបស់មនុស្សទាំងឡាយ ប្រៀបដូចជាគ្រឿងអលង្ការ គុជដែលពាក់ត្រង់ដើមទ្រូង និងប្រៀបដូចជាភួងផ្កាឈើដែលប្រដាប់ទុកហើយលើសីសៈដូច្នោះ ។

-សេចក្តីថា ជាទីស្រឡាញ់របស់អមនុស្សទាំងឡាយ គឺថាអ្នកចំរើនមេត្តាចេតោវិមុត្តិនោះ ជាទីស្រឡាញ់របស់មនុស្សទាំងឡាយយ៉ាងណា ក៏រមែងជាទីស្រឡាញ់របស់អមនុស្សទាំងឡាយ

ដូច្នោះដែរ ដូចមានព្រះវិសាខត្ថេរ ( ជាសាធកដូច្នេះថា )

## រឿងព្រះវិសាខត្ថេរ

បានឮថាព្រះវិសាខត្ថេរនោះ ( កាលនៅជាគ្រហស្ថ ) ជាកុដុម្ពីនៅក្នុងក្រុងបាដលិបុត្រ លោកនៅក្នុងក្រុងនោះឯងបានដឹងដំណឹងថា តម្ពបណ្ណិទ្វីប (គឺកោះលង្កា) ប្រដាប់ពេញទៅដោយជួរព្រះចេតិយ រុងរឿងដោយកាសាវភស្ត ក្នុងទ្វីបនោះអ្នកណាៗអាចនឹងអង្គុយឬដេកបានក្នុងទីគ្រប់នៃទីដែលខ្លួនប្រាថ្នា សប្បាយទាំងពួងគឺឧតុសប្បាយ សេនាសនសប្បាយ បុគ្គលសប្បាយ ធម្មសវនសប្បាយប្រព្រឹត្តទៅបានយ៉ាងស្រួលក្នុងទ្វីបនោះដូច្នេះលោកទើបប្រគល់នូវគំនរនៃភោគទ្រព្យរបស់ខ្លួនឲ្យដល់បុត្រ និងភរិយា មានប្រាក់កហាបណៈដែលចងទុកនឹងជាយសំពត់ប៉ុណ្ណោះចេញអំពីផ្ទះទៅចាំទូកនៅមាត់សមុទ្រ ហូតដល់ទៅមួយខែ ព្រោះភាពជាអ្នកឆ្លាតក្នុងពាក្យសំដី លោកទិញរបស់ (របស់មានតម្លៃអាចទិញលក់ដូរញជាជំនួញបាន) ពីកន្លែងច្រកនេះ ទៅលក់នៅច្រកនោះ ដោយកាលក្នុងកាលជាចន្លោះ ( នៃការចាំទូក ) មួយខែនោះឯង (លោក)អាចប្រមូលទ្រព្យបានដល់ទៅមួយពាន់កហាបណៈដោយការទិញដូរ ដែលប្រពៃតាមធម៌ លោកមកដល់មហាវិហារ ( ក្នុង

កោះលង្កា ) ដោយលំដាប់ ហើយសូមបព្វជ្ជា កាលដែលភិក្ខុទាំង-ឡាយ នាំលោកទៅកាន់សីមាដើម្បីឲ្យបព្វជ្ជា លោកធ្វើថង់ប្រាក់មួយពាន់កហាបណៈនោះ ឲ្យធ្លាក់ចុះលើដីតាមប្រហោងជាយសំ-ពត់ ភិក្ខុទាំងឡាយ ( ឃើញហើយ ) សួរថា នោះជាអ្វី ? ( លោក ) ក៏ប្រាប់ថា លោកម្ចាស់កហាបណៈមួយពាន់ ភិក្ខុទាំងឡាយតឿនប្រាប់ថា នែឧបាសកបន្ទាប់ពីបានបព្វជ្ជាហើយទៅ លោកនឹងចាត់ចែងប្រើប្រាស់មិនបានទេ លោកចូរចាត់ចែងប្រើប្រាស់ឥឡូវនេះឯងចុះលោកទើបប្រកាសថា ណ្ហើយបើដូច្នោះមនុស្សទាំងឡាយមកកាន់ស្ថានទីជាទីដែលនាយវិសាខបព្វជ្ជា កុំមានដៃទទេត្រឡប់ទៅវិញឡើយហើយស្រាយ(មាត់ថង់)បាចពង្រាយ (កហាបណៈ) ក្នុងរង្វង់សីមាហើយ ទើបបព្វជ្ជាឧបសម្បទា (លោកនៅក្នុងឧបសម្បទភាវ ) មានវស្សាគម្រប់ប្រាំហើយ (រៀន)ធ្វើមាតិកា២មា-តិកាឲ្យស្ទាត់ជំនាញហើយ បវារណា (ចេញវស្សា)ហើយរៀនយកកម្មដ្ឋាន ដែលជាទីសប្បាយដល់ខ្លួន ហើយទៅនៅបំពេញវត្ត ជានិច្ចកាល ក្នុងវិហារមួយៗ (លោកគង់នៅអស់ ) រយៈពេល ៤ៗខែ (យ៉ាងនេះដូច្នេះឯង ) ។

ព្រះវិសាខៈ(នោះត្រាច់ទៅបំពេញវត្ត)

ប្រព្រឹត្តយ៉ាងនោះហើយ (ថ្ងៃមួយ)
លោកឈរនៅកណ្ដាលព្រៃ(ពិចារណា)
មើលគុណធម៌របស់ខ្លួន និងបន្ទឹសំឡេង
(ឲ្យប្រាកដទុក) ទើបបានពោលសេចក្ដីនេះថា
ខ្ញុំម្ចាស់ឧបសម្បទាមកអស់កាលប៉ុណ្ណា (នឹង)
មកក្នុងទីនេះដោយកាលប្រមាណប៉ុណ្ណា
ក្នុងចន្លោះនៃកាលប្រមាណប៉ុណ្ណោះនេះ
(សេចក្ដីខុសឆ្គង) របស់ខ្ញុំម្ចាស់មិនមានឡើយ

ឱ! ជាលាភពិតណាស់ លោកអ្នកនិរទុក្ខទាំងឡាយ ។ លោកកំពុងដើរទៅ ចិត្តលបពត៌វិហារ ដល់ផ្លូវបែកជាពីរក៏ឈប់ស្ងៀមនៅហើយគិតថា ផ្លូវនេះ ឬផ្លូវនេះហ្ន៎ ពេលនោះទេវតាអ្នកនៅនឹងភ្នំនោះឈរបង្ហាញលោកថា លោកម្ចាស់ផ្លូវនោះ លោកស្នាក់នៅចិត្តលបពត៌៤ខែហើយគិតថានឹងទៅក្នុងពេលព្រឹក ព្រហាមហើយ (ចូល)ចាំវត្ត ទេវតាអ្នកនៅនឹងដើមមណិលៈខាងដើមនៃផ្លូវដែលចង្រ្កម មកអង្គុយស្រែកយំនៅនឹងកាំជណ្ដើរព្រះថេរៈ សួរថាអ្នកណានោះ ? (ឆ្លើយថា) ខ្ញុំម្ចាស់ឈ្មោះមណិលិយាលោកម្ចាស់(ព្រះថេរៈសួរថា) យំធ្វើអ្វី ?(ឆ្លើយថា) ទាក់ទងនឹងការទៅរបស់

លោកម្ចាស់ (ព្រះថេរៈសួរថា) កាលបើអាត្មានៅទីនេះមានគុណអ្វីដល់លោកទាំងឡាយ (ឆ្លើយថា) បពិត្រលោកម្ចាស់ កាលលោកម្ចាស់នៅទីនេះ ពួកអមនុស្សទាំងឡាយ មានមេត្តាដល់គ្នានិងគ្នា កាលបើលោកម្ចាស់ចេញទៅហើយគេទាំងឡាយក៏បង្កការឈ្លោះទាស់ទែងគ្នា និយាយពាក្យអាក្រក់ដល់គ្នានិងគ្នា ។

ព្រះថេរៈ ទើបមានថេរដីកាថា ប្រសិនបើអាត្មានៅទីនេះសេចក្តីនៅជាសុខ (សេចក្តីសប្បាយកើត) មានដល់អ្នកទាំងឡាយក៏រាប់ថាជាការល្អហើយ ដោយនៅនឹងចិត្តលបពត៌តទៅទៀត៤ខែ ហើយញ៉ាំងគមនចិត្ត ( ការគិតនិងប្រព្រឹត្តទៅ ) ឲ្យកើតឡើងដូចដើមទៀត ឯខាងទេវតាក៏ (មក) ស្រែកយំដូច្នោះទៀតដោយឧបាយនោះ ព្រះថេរៈនៅទីនោះរហូតបរិនិព្វានទៅក្នុងទីនោះឯងភិក្ខុអ្នកមានមេត្តា ជាវិហារធម៌រមែងជាទីស្រលាញ់របស់អមនុស្សទាំងឡាយដូច្នេះ ។

ក្នុងសេចក្តីថាទេវតារក្សា គឺទេវតាទាំងឡាយរមែងរក្សា ( អ្នកមានមេត្តាជាវិហារធម៌ ) ដូចមាតាបិតាទាំងឡាយ រក្សាបុត្រដូច្នោះ។

ក្នុងសេចក្តីថា ភ្លើងក្តី ពិសក្តី សស្ត្រាក្តីមិនអាចចូលទៅរំខាន

បៀតបៀន អធិប្បាយថា ភ្លើងក៏មិនរំខានគឺមិនចូលទៅក្នុងរាងកាយរបស់អ្នកមានមេត្តាជាវិហារធម៌ដូចភ្លើងមិនចូលទៅ ( បៀតបៀន) ក្នុងរាងកាយរបស់ឧត្តរាឧបាសិកាដូច្នោះ ពិសក៏មិនរំខានគឺមិនចូល ទៅក្នុងរាងកាយរបស់អ្នកមានមេត្តាជាវិហារធម៌ ដូចពិសមិនចូលទៅក្នុងរាងកាយរបស់ព្រះចុឡសិវត្ថេរៈ អ្នកសូត្រ សំ-យុត្តនិកាយ ដូច្នោះ សស្ត្រា ក៏មិនរំខាន គឺមិនចូលទៅក្នុង រាងកាយរបស់អ្នកមានមេត្តាជាវិហារធម៌ ដូចសស្ត្រាមិនចូលទៅ ក្នុងរាងកាយរបស់សង្កិច្ចសាមណេរដូច្នោះ មានអធិប្បាយថា ភ្លើងក្តី ពិសក្តី សស្ត្រាក្តី រមែងមិនធ្វើរាងកាយរបស់លោកអ្នកមានមេត្តាជាវិហារធម៌នោះឲ្យកម្រើកបាន ក្នុងន័យនេះបណ្ឌិតទាំងឡាយពោលរឿងទឹកដោះនៃមេគោ ( ជានិទស្សនៈ ) ខ្លះក៏បាន ។

មានរឿងដំណាលថា មានមេគោមួយ ឈរបញ្ចេញកសីរ-ធារា (សម្រក់ទឹកដោះ) ឲ្យដល់កូនគោ ព្រានម្នាក់គិតនឹងចាក់មេ-គោនោះ ទើបកាន់លំពែងដងវែង បោះភ្លោះទៅ (ទៅ)ដល់ខ្លួនរប-ស់មេគោនោះ (លំពែងនោះក៏ស្រាប់តែ) អណ្តែតទៅដូចជាស្លឹកត្នោត (មិនចូល) (ទាំងនេះ) ដោយកម្លាំងនៃឧបចារសមាធិក៏មិនមែន ដោយកម្លាំងនៃអប្បនាសមាធិក៏មិនមែនឡើយ (តែ) ដោយ

សេចក្ដីដែលមេគោនោះ មានចិត្តស្រលាញ់អាណិតជាកម្លាំងក្នុងកូនគោប៉ុណ្ណោះ មេត្តាមានអានុភាពច្រើនដូច្នេះឯង ។

- ក្នុងន័យថា ចិត្តតាំងមាំរហ័ស គឺចិត្តរបស់ អ្នកមានមេត្តាជាវិហារធម៌ រមែងជាសមាធិបានរហ័សតែម្ដងការយឺតយូរនៃសមាធិចិត្តនោះមិនមានទេ ។

-សេចក្ដីថា ពណ៌សម្បុរស្រស់ថ្លាផូរផង់ស្អាត ប្រការមួយនោះគឺ មុខរបស់អ្នកមានមេត្តាជាវិហារធម៌នោះ រមែងមានពណ៌ស្រស់ថ្លាផូរផង់ដូច (ជាងស្ទឹក)ត្នោតទុំដែលទើបតែជ្រុះចាកអំពីជួរដូច្នោះ ។

-សេចក្ដីថា មិនវង្វេងទៀបនឹងធ្វើកាលកិរិយា មានន័យថាដែលឈ្មោះថាសម្មោហមរណៈ(សេចក្ដីវង្វេងទៀបនឹងស្លាប់)របស់អ្នកមានមេត្តា ជាវិហារធម៌រមែងមិនមាន លោកជាអ្នកមិនវង្វេងឡើយទៀបនឹងធ្វើកាលកិរិយានោះ គឺដូចជាដេកលក់ទៅដូច្នោះ។

សេចក្ដីថា កាលនៅមិនទាន់បន្ទុះគុណធម៌ដែលក្រៃលែងជាងនោះ មានន័យថា ប្រការមួយ(នោះគឺ) អ្នកមានមេត្តាជាវិហារធម៌នោះកាលមិនអាចបន្ទុះព្រះអរហត្ត ដែលជាគុណដ៏ក្រៃលែងជាងមេត្តាសមាបត្តិ ឃ្លាតចាកភពនេះហើយ រមែងចូលទៅដល់

ព្រហ្មលោក(គឺចូលទៅកាន់ព្រហ្មលោក)ដូចជាការដេកលក់ហើយ ភ្ញាក់ឡើងវិញដូច្នោះ ។

## អដ្ឋកថាមតកភត្តជាតក

ព្រះសាស្ដាព្រះអង្គគង់ប្រថាប់នៅនឹងព្រះវិហារជេតវ័នទ្រង់ប្រារព្ធមតកភត្ត ទើបត្រាស់ព្រះធម្មទេសនានេះ មានពាក្យផ្ដើមថា ក្នុងកាលនោះមនុស្សទាំងឡាយសម្លាប់ពពែជាដើមយ៉ាងច្រើនឲ្យមតកភត្ត ឧទ្ទិសដល់ញាតិទាំងឡាយ ដែលស្លាប់ទៅហើយ ភិក្ខុទាំងឡាយឃើញមនុស្សទាំងនោះធ្វើយ៉ាងនោះទើបក្រាបទូលសួរព្រះសាស្ដាថាបពិត្រព្រះអង្គដ៏ចម្រើនពេលនេះមនុស្សទាំងឡាយធ្វើសត្វមានជីវិតយ៉ាងច្រើន ឲ្យដល់ការអស់ទៅនៃជីវិត ហើយឲ្យឈ្មោះថា មតកភត្ត សេចក្ដីចម្រើននៃការឲ្យមតកភត្តនេះមានពិតឬព្រះអង្គ? ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយឈ្មោះថាសេចក្ដីចម្រើនយ៉ាងណាៗ ចំពោះបាណាតិបាត សូម្បីដែលធ្វើដោយគិតថាពួកយើងនឹងឲ្យមតកភត្តដូច្នេះ រមែងមិនអាចសូម្បីក្នុងកាលមុន បណ្ឌិតទាំងឡាយអង្គុយនៅ ឰដ៏អាកាសសំដែងធម៌

ពោលទោសក្នុងការធ្វើបាណាតិបាតនេះឲ្យជនទាំងឡាយអ្នកនៅក្នុងជម្ពូទ្វីបទាំងអស់លះនូវកម្មនោះ តែពេលនេះ កម្មនោះត្រឡប់ប្រាកដឡើងទៀត ព្រោះសត្វទាំងឡាយពួកនោះជា អ្នកនៅក្នុងសង្វេបនៃភព ហើយទ្រង់នាំអតីតនិទានមកដូចតទៅនេះ ។

ក្នុងអតីតកាលកាលព្រះចៅព្រហ្មទត្តគ្រងរាជសម្បត្តិក្នុង **នគរពារាណសី** មានអាចារ្យទិសាបាមោក្ខ អ្នកសម្រេចត្រៃវេទម្នាក់ គិតថានឹងឲ្យមតកកត្ត ទើបឲ្យចាប់ពពែមួយក្បាល ពោលនឹងអន្តេវាសិកទាំងឡាយថាអ្នកទាំងឡាយចូរនាំពពែនេះទៅកាន់ស្ទឹង យកកម្រងផ្កាឈើពាក់កយកម្សៅមកប្រដាប់តាក់តែងហើយនាំមក អន្តេវាសិកទាំងឡាយទទួលពាក្យហើយនាំពពែនោះទៅកាន់ស្ទឹងឲ្យងូតទឹកប្រដាប់តាក់តែងហើយឲ្យឈរនៅនឹងកន្ទែងមាត់ស្ទឹង ពពែនោះចេះពិចារណាឃើញកម្មចាស់របស់ខ្លួនក៏កើតសេចក្ដីសោមនស្សថា យើងនឹងផុតចាកទុក្ខបែបនេះទៀតហើយក្នុងថ្ងៃនេះទើបកើតឡើងនូវសំណើចលាន់ឮហាក់ដូចជាគោះវាយឆ្នាំងដី ត្រឡប់គិតថា ព្រាហ្មណ៍នេះសម្លាប់យើងហើយនឹងបានសេចក្ដីទុក្ខដែលយើងធ្លាប់បានហើយ កើតសេចក្ដីករុណាដល់ព្រាហ្មណ៍ ទើបស្រែកយំដោយសំឡេងដ៏ខ្លាំង លំដាប់នោះបុរស

មាណពទាំងនោះទើបសួរពពែនោះថា ម្នាលពពែសំលាញ់ អ្នកសើច និងយំ សំឡេងខ្លាំង ព្រោះហេតុអ្វី អ្នកទើបសើច? និងព្រោះហេតុអ្វីទើបអ្នកយំ ?ពពែពោលថាលោកទាំងឡាយគប្បីសួរហេតុនេះនឹងខ្ញុំក្នុងសំណាក់អាចារ្យរបស់លោកចុះ ។ មាណពទាំងនោះទើបនាំពពែនោះទៅហើយ ប្រាប់ហេតុនេះដល់អាចារ្យ អាចារ្យបានស្តាប់ពាក្យមាណពទាំងអស់នោះហើយ សួរពពែនោះថា ម្នាលពពែព្រោះហេតុអ្វីទើបអ្នកសើច ព្រោះហេតុអ្វីទើបអ្នកយំ ? ពពែរលឹកឃើញកម្មដែលខ្លួនធ្វើដោយញាណ ជាគ្រឿងរលឹកជាតិបានពោលដល់ព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ កាលមុនយើងជាព្រាហ្មណ៍អ្នកស្វាធ្យាយមន្តដូចជាលោកនោះដែរ គិតថានឹងឲ្យមតកភត្តទើបបានសម្លាប់ពពែមួយក្បាលហើយឲ្យមតកភត្តព្រោះយើងសម្លាប់សត្វ ពពែមួយនោះ យើងទើបដល់នូវការកាត់សីសៈក្នុង៤៩៩អត្តភាព នេះជាអត្តភាពទី៥០០របស់យើងដែលស្ថិតនៅក្នុងទីបំផុតយើងកើតសេចក្តី សោមនស្សថាថ្ងៃនេះ យើងនឹងផុតចាកទុក្ខនោះទៀតហើយ ដោយហេតុទើបនេះយើងសើចតែកាលដែលយើងស្រែកយំ បានជាយំព្រោះសេចក្តីករុណាអាណិតដល់លោក ដោយគិតថាកាលពីខាងដើមយើងសម្លាប់ពពែមួយក្បាល

ក៏ដល់នូវសេចក្តីទុក្ខគឺការដែលត្រូវកាត់សីស (ក្បាល) ដល់ទៅ ៥០០ជាតិ នឹងផុតចាកទុក្ខនោះក្នុងថ្ងៃនេះ ចំណែកព្រាហ្មណ៍ឯង សម្លាប់យើងហើយនឹងបានទទួលទុក្ខគឺការត្រូវកាត់សីសៈដល់ទៅ ៥០០ជាតិដូចយើង ។

ព្រាហ្មណ៍ពោលថា ម្នាលពពែអ្នកកុំខ្លាចឡើយ យើងមិនសម្លាប់អ្នកទេ ។ ពពែពោលថាព្រាហ្មណ៍លោកនិយាយអ្វីកាលបើលោកសម្លាប់ ឬមិនសម្លាប់ក្តី ថ្ងៃនេះ យើងមិនអាចផុតអំពីសេចក្តីស្លាប់ទៅបានឡើយ ។ ព្រាហ្មណ៍ពោលថា ម្នាលពពែយើងនឹងធ្វើនូវការរក្សាអ្នក ដើរទៅជាមួយអ្នកប៉ុណ្ណោះ ។ ពពែពោលថា ព្រាហ្មណ៍ ការរក្សារបស់លោកមានប្រមាណតិចតួច ណាស់ចំណែកឯបាបកម្ម ដែលយើងធ្វើមានកម្លាំងច្រើន ។ ព្រាហ្មណ៍ឲ្យលែងពពែហើយពោលថា យើងមិនឲ្យនរណាៗសម្លាប់ពពែនេះឡើយ ទើបនាំពួកអន្តេវាសិកត្រាច់ ទៅជាមួយពពែនោះឯងល្មមតែគេដោះលែងតែប៉ុណ្ណោះក៏អើតកផ្តើមបរិភោគស្លឹកឈើ ដែលអាស្រ័យក្រោយផ្ទាំងថ្មមួយកន្លែង ភ្លាមមួយរំពេចនោះឯង រន្ទះក៏បាញ់ ចំត្រង់កន្លែងខាងក្រោយ នៃថ្មនោះជម្រៀកថ្ម ដែលបែកជ្រៀកមួយជម្រៀកដាច់ធ្លាក់ចំត្រង់កនៃពពែដែលអើតក ហើយ

*កាត់សីសៈដាច់ទៅ មហាជនប្រជុំគ្នាក្នុងកាលនោះ ព្រះពោធិសត្វកើតជារុក្ខទេវតានៅទីនោះ ព្រះពោធិសត្វកាលមហាជនឃើញហើយនោះឯង អង្គុយតាំងសមាធិឰដ៏អាកាសដោយទេវានុភាព ពោលថាសត្វទាំងនោះដឹងផលរបស់បាបយ៉ាងនេះហើយឈ្មោះថាបាណាតិបាតគឺមិនគប្បីធ្វើកាលដែលសំដែងធម៌ដោយសំឡេងយ៉ាងពីរោះ ទើបពោលគាថានេះថា*

*ឯវញ្ចេ សត្តា ជានេយ្យុំ*
*ទុក្ខា យំ ជាតិសម្ភវោ ន*
*បាណោ បាណិនំ ហញ្ញេ*
*បាណឃាតី ហិ សោចតីតិ ។*

*បើពួកសត្វគប្បីដឹងយ៉ាងនេះថា*
*ការកើតនៃជាតិនេះរមែងនាំមក*
*នូវទុក្ខ សត្វមិនត្រូវសម្លាប់សត្វ*
*ព្រោះថាបុគ្គលអ្នកសម្លាប់សត្វ*
*រមែងសោយសោក ។*

*បណ្ដាបទទាំងនោះ បទថា ឯវញ្ចេ សត្តា ជានេយ្យុំ សេចក្ដីថា សត្វទាំងនេះគប្បីដឹងយ៉ាងនេះ។ គប្បីដឹងដូចម្ដេច?គប្បីដឹងថា*

ជាតិភពនេះជាទុក្ខ អធិប្បាយថាប្រសិនបើគប្បីដឹងថាការកើតក្នុងភព ពោលគឺសេចក្ដីចំរើនរបស់អ្នកកើតដោយលំដាប់នេះឈ្មោះថាជាទុក្ខ ព្រោះជាវត្ថុជាទីតាំងនៃទុក្ខទាំងឡាយមាន ជរា ព្យាធិ មរណៈ ការជួបប្រសព្វនឹងវត្ថុដែលមិនជាទីស្រឡាញ់ សេចក្ដីព្រាត់ប្រាសចាកវត្ថុជាទីស្រឡាញ់ និងការដែលត្រូវកាត់ដៃកាត់ជើងជាដើម ។ បទថា **ន បាណោ បាណិនំ ហញ្ញេ**សេចក្ដីថា សត្វណាៗដឹងហើយថាជាតិភពឈ្មោះថាជាទុក្ខព្រោះជាទីតាំងនៃទុក្ខ ថាអ្នកធ្វើសត្វដទៃឲ្យចំរើន រមែងបានសេចក្ដី ចំរើនក្នុង ជាតិភព កាលបើបៀតបៀនសត្វដទៃរមែងបានទទួលការបៀតបៀនដូច្នេះ ទើបមិនគួរសម្លាប់សត្វដទៃឡើយអធិប្បាយថាសត្វមិនគួរសម្លាប់សត្វដទៃព្រោះហេតុអ្វី? ព្រោះអ្នកមានប្រក្រតីសម្លាប់សត្វរមែងសោកសៅ អធិប្បាយថាព្រោះបុគ្គលអ្នកមានប្រក្រតីសម្លាប់សត្វដោយការចូលទៅកាត់ផ្ដាច់ជីវិតិន្ទ្រីយ៍របស់សត្វដទៃដោយ ប្រយោគណាមួយបណ្ដាប្រយោគទាំង៦ មានសាហត្ថិកប្រយោគជាដើម សោយមហន្តទុក្ខនៅក្នុងអបាយទាំង៤នេះគឺក្នុងមហានរក៨ រណ្ដៅក្នុង ឧស្សទនរក១៦ រណ្ដៅក្នុងកំណើតសត្វតិរច្ឆានមានប្រការផ្សេងៗ ក្នុងបេតវិស័យនិងក្នុងអសុរកាយឈ្មោះថារមែងសោក

សៅដោយសេចក្តីសោយសោក ដែលមានការឆេះរោលរាលក្នុងខាងក្នុងជាលក្ខណៈ អស់កាលដ៏យូរ ន័យម្យ៉ាងទៀតសត្វដឹងថាពពែនេះសោយសោកហើយព្រោះមរណភ័យយ៉ាងណា អ្នកមានប្រក្រតីសម្លាប់សត្វ រមែងសោយសោក អស់កាលដ៏យូរដូច្នោះឯងដូច្នេះហើយ មិនគួរសម្លាប់សត្វ អធិប្បាយថានរណាៗក៏មិនគួរធ្វើកម្មគឺបាណាតិបាតឡើយ ក៏បុគ្គលល្ងង់ព្រោះមោហៈ កាលបើអវិជ្ជាធ្វើឲ្យមនុស្សខ្វាក់ងងឹតសូន្យឈឹងហើយ មិនឃើញទោសនេះ រមែងធ្វើបាណាតិបាត ។

ព្រះពោធិសត្វសំដែងធម៌ដោយយកភ័យក្នុងនរកមកបង្ហាញដោយប្រការយ៉ាងនេះ ។ មនុស្សទាំងឡាយស្តាប់ធម្មទេសនានោះហើយភ័យខ្លាចក្នុងនរកក៏នាំគ្នាវៀរចាកបាណាតិបាតចំណែ-ក ព្រះពោធិសត្វកាលដែលសំដែងធម៌ហើយ ញុំាងមហាជនឲ្យតាំងនៅក្នុងបញ្ចសីលហើយទៅតាមយថាកម្ម ចំណែក ឯមហា-ជនដែលតាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ធ្វើបុណ្យមានទានជាដើម ធ្វើទេពនគរឲ្យពេញហើយ ។

ព្រះសាស្តាកាលទ្រង់ នាំយកព្រះធម៌ទេសនា នេះមក

ហើយ ទ្រង់បន្តអនុសន្ធិ ទ្រង់ប្រជុំជាតកថា ម្នាលភិក្ខុទាំងឡាយ សម័យនោះរុក្ខទេវតានោះ គឺតថាគតនេះឯង ។

ចប់មតកភត្តជាតក

## អដ្ឋកថាមេត្តសូត្រ

មេត្តសូត្រផ្ដើមតាំងដោយគាថា ថាករណីយមត្ថកុសលេន ដូច្នេះមានឧបត្តិ ( ការកើតឡើង ) ដូចម្ដេច ? បានឮថា ភិក្ខុទាំងឡាយត្រូវទេវតាទាំងឡាយនាក្នុំហិមពាន្ត បំភ័យឲ្យខ្លាចហើយមកកាន់ក្រុងសាវត្ថី ដែលជាទីគង់ប្រថាប់នៅរបស់ព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះដ៏មានព្រះភាគព្រះអង្គ បានត្រាស់សម្ដែងព្រះសូត្រនេះដើម្បីប្រយោជន៍ដល់ការការពារអន្តរាយ និងដើម្បីប្រយោជន៍ដល់កម្មដ្ឋានសម្រាប់ភិក្ខុទាំងនោះ សំដែងត្រឹមសេចក្ដីសង្ខេបប៉ុណ្ណោះសិន ចំណែកសេចក្ដីពិស្ដារមានសំដែងដូចតទៅនេះ ។

ក្នុងសម័យមួយព្រះដ៏មានព្រះភាគជាម្ចាស់កាលថ្ងៃចូលវស្សាជិតចូលមកដល់ព្រះដ៏មានព្រះអង្គគង់នៅក្នុងក្រុងសាវត្ថី សម័យនោះឯងភិក្ខុនៅកន្លែងផ្សេងៗជាច្រើន បានរៀនកម្មដ្ឋានក្នុងសំណាក់របស់ព្រះដ៏មានព្រះភាគជាម្ចាស់ ហើយមានសេចក្ដីប្រាថ្នាដើម្បីចូលចាំវស្សាក្នុងទីនោះៗ ទើបចូលទៅគាល់ព្រះដ៏មានព្រះ

ភាគជាម្ចាស់ បានព្យុថា ក្នុងទីនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះអង្គសំដែងកម្មដ្ឋាន ជាអនុកូលនៃចរិតមានចំនួនប្រមាណជា ៨៤០០០ ប្រភេទដោយន័យយ៉ាងនេះគឺ អសុភកម្មដ្ឋាន១១យ៉ាង ដោយអំណាចនៃសវិញ្ញាណកៈ និងអវិញ្ញាណកៈសម្រាប់អ្នករាគ-ចរិតទាំងឡាយ កម្មដ្ឋានមានមេត្តាជាដើម៤យ៉ាង សម្រាប់អ្នកទោសចរិតទាំងឡាយ កម្មដ្ឋានទាំងឡាយមានមរណានុស្សតិកម្ម-ដ្ឋាន ជាដើមសម្រាប់អ្នកមោហចរិតទាំងឡាយកម្មដ្ឋានទាំងឡាយមានអានាបានស្សតិនិងបឋវីកសិណជាដើមសម្រាប់អ្នកសទ្ធាចរិតទាំងឡាយ កម្មដ្ឋានទាំងឡាយមានចតុធាតុវវដ្ឋានជាដើមសម្រាប់អ្នកពុទ្ធិចរិតទាំងឡាយ ។

គ្រានោះឯង ភិក្ខុទាំងឡាយប្រមាណ៥០០រូបរៀនកម្មដ្ឋានក្នុងសំណាក់នៃព្រះដ៏មានព្រះភាគហើយស្វែងរកសេនាសនដែលជាសេនាសនសប្បាយនិងគោចរគ្រាម បានឃើញភ្នំតូចមួយដែលត ជាប់គ្នាជាមួយព្រៃហិមពាន្តជាខាងចុង នៃដែនដោយលំដាប់មានផ្ទៃសិលាក្រាលទៅដោយខ្សាច់ និងកែវមណីពណ៌ខៀវ ប្រ-ដាប់ដោយដងព្រៃពណ៌ខៀវ មានម្ងប់ត្រជាក់ត្រឈឹងត្រឈៃនិងក្រាស់ណែនបរិបូណ៌ មានភូមិភាគពាសពេញដោយខ្សាច់ដូចគ្នា

នឹងកម្រងកែវមុក្តា និងផ្កាំងប្រាក់ ព័ទ្ធជុំវិញដោយជលាល័យ (ទន្លេ)ដ៏ស្រស់ស្អាតត្រជាក់ស្និទ្ធល្អិតល្អន់លំដាប់នោះឯងភិក្ខុទាំងឡាយបានបបួលគ្នាទៅនៅសម្រាកភ្នំនោះមួយយប់ កន្លងរាត្រីនោះ ទៅហើយអរុណរះឡើងភិក្ខុទាំងនោះធ្វើបរិកម្មស្រេចបាច់ហើយ ក៏ចូលទៅបិណ្ឌបាតក្នុងស្រុកមួយ ក្នុងទីមិនឆ្ងាយពីភ្នំនោះ ស្រុកនោះប្រកបដោយត្រកូលដែលចូលទៅធ្វើទីតាំង សាងសង់ផ្ទះសំបែងយ៉ាងណែនតាន់តាប់ប្រមាណជា១០០០ត្រកូល ។

ក៏ក្នុងស្រុកនោះ មនុស្សទាំងឡាយមានសទ្ធាជ្រះថ្លាកាលដែលឃើញភិក្ខុទាំងនោះ ហើយក៏កើតសោមនស្សរីករាយព្រោះការបានឃើញបព្វជិតក្នុ ងបច្ចន្តជនបទជាការឃើញដោយកម្រញ៉ាំងភិក្ខុទាំងនោះឲ្យឆាន់ហើយសួរថាបពិត្រលោកម្ចាស់ដ៏ចម្រើ-នសូមលោកម្ចាស់ទាំងឡាយនិមន្តគង់នៅក្នុងស្រុកនេះរហូតបាន ៣ខែ កាលដែលសូមនិមន្តភិក្ខុទាំងនោះហើយ ក៏ចាត់ចែងធ្វើកុដិសម្រាប់បំពេញធ្វើនូវសេចក្តីព្យាយាម ៥០០ ខ្នង ចាត់ចែងគ្រឿង-ឧបករណ៍គ្រប់យ៉ាង មានគ្រែ តាំង ឆ្នាំងទឹកបរិភោគទឹកប្រើប្រាស់ជាដើម ទុកក្នុងស្រុកនោះ ក្នុងថ្ងៃទី២ ភិក្ខុទាំងឡាយចូលទៅកាន់-ស្រុកដទៃដើម្បីបិណ្ឌបាត មនុស្សទាំងឡាយក្នុងស្រុកនោះក៏ទំនុក

បម្រុងភិក្ខុទាំងនោះដូចអ្នកស្រុកមុនដែរ ហើយអង្វរភិក្ខុទាំងនោះ ឲ្យនៅចាំវស្សាភិក្ខុទាំងឡាយឃើញថាមិនមានអន្តរាយទើបទទួល និមន្ត ចូលទៅកាន់ដងព្រៃនោះប្រារព្ធសេចក្តីព្យាយាមរហូតរាល់ យប់និងថ្ងៃទាំងពួង គោះរគាំងប្រាប់អំពីយាម ជាអ្នកច្រើនទៅ ដោយយោនិសោមនសិការ គង់អាស្រ័យនឹងគល់ឈើ ។ ទេវតា ទាំងឡាយប្រាសចាកតេជះរិទ្ធិអំណាច ព្រោះតេជះរបស់ភិក្ខុអ្នក មានសីលទាំងឡាយ រុក្ខទេវតាទាំងនោះក៏ចុះចាកវិមានរៀងៗខ្លួន ហើយនាំកូនទាំងឡាយ(កូនទេវតា)ត្រាច់ទៅខាងនេះផងខាងនោះ ផងហាក់ដូចជាផ្ទះរបស់អ្នកស្រុកទាំងឡាយត្រូវព្រះរាជា ឬមហា-មាត្យរបស់ព្រះរាជារឹបអូសហើយ អ្នកស្រុកទាំងឡាយចេញ អំពី ផ្ទះទៅនៅទីកន្ទែងដទៃរង់ចាំតែមើលថា កាលណាហ្ន៎ នឹងចេញ ទៅ រឿងនោះយ៉ាងណា ទេវតាទាំងឡាយក៏ដូច្នោះ នឹងចោល វិមានរបស់ខ្លួនរៀងៗខ្លួន ហើយត្រាច់ទៅខាងនេះផងខាងនោះ ផង រំពៃគយគន់មើលទៅថា កាលណាហ្ន៎ព្រះគុណម្ចាស់ទាំង ឡាយនិមន្តចេញទៅ បន្ទាប់ពីនោះទៅក៏នាំគ្នាគិតយ៉ាងនេះថា ភិក្ខុទាំងឡាយចូលចាំវស្សាគង់នៅរហូត៣ខែ យ៉ាងពិតប្រាកដ ចំណែកឯពួកយើង មិនគួរនឹងនាំក្មេងទាំងឡាយ ចុះមកនៅយូរ

ត្រឹមនោះទេ ណ្ហើយចុះពួកយើងនឹងសំដែងអារម្មណ៍ដែលគួរឲ្យភ័យខ្លាចដល់ភិក្ខុទាំងឡាយ ទេវតាទាំងនោះក៏បាននិមិត្តរូបយក្ខទាំងដែលគួរភ័យខ្លាចក្នុងពេលដែលភិក្ខុធ្វើសមណធម៌ក្នុងពេលរាត្រី (យ័ក្សទាំងនោះ)ក៏ឈរនៅខាងមុខៗ ហើយបញ្ចេញសំឡេង គួរព្រឺខ្លាច ។ កាលដែលភិក្ខុទាំងឡាយឃើញនូវរូបនិងឮនូវសំ-ឡេងទាំងនោះហើយ បេះដូងញ័រញញើតញញើមព្រឺខ្លាច ភិក្ខុទាំងឡាយ ក៏មានសម្បុរសៅហ្មងកើតជា រោគលឿង ស្ញេកស្ញាំង ដោយហេតុនោះភិក្ខុទាំងនោះទើបមិនដើម្បីនឹងធ្វើចិត្តឲ្យមានអារម្មណ៍តែមួយបាន កាលដែលភិក្ខុទាំងនោះ មានចិត្តរវើរវាយមិនមានអារម្មណ៍តែមួយហើយ និងតក់ស្លុតសង្វេគខ្លាចជារឿយ ៗ ព្រោះការខ្លាចអារម្មណ៍នោះសតិក៏រវើរវាយវង្វេងវង្វាន់បន្តពីនោះទៀតទៅ ទេវតាទាំងឡាយ ក៏ប្រកបអារម្មណ៍ទាំងឡាយ ដែលមានក្លិនស្អុយអាក្រក់ដល់ភិក្ខុអ្នកមានអារម្មណ៍មិននឹងនរដែលរវើរវាយវង្វេងវង្វាន់ទាំងនោះសីសៈរបស់ភិក្ខុទាំងនោះដូចជាត្រូវចាប់ច្របល់ដោយក្លិននោះវេទនាក្នុងសីសដ៏ខ្លាំងក្លាបានកើតឡើងហើ-យភិក្ខុទាំងឡាយក៏មិនបានប្រាប់ព្រឹត្តិការណ៍(ហេតុការណ៍ដែលកើតឡើង)នោះដល់ភិក្ខុផងគ្នាទេ ។ ក្រោយមកនៅថ្ងៃ មួយពេល

ដែលភិក្ខុទាំងអស់ប្រជុំគ្នាក្នុងពេលបម្រើទំនុកបំរុងព្រះសង្ឃត្ថេរ ព្រះសង្ឃត្ថេរ ទើបសួរថាម្នាលអាវុសោទាំងឡាយ កាលបើពួកលោកចូលកាន់ដងព្រៃនេះត្រឹមថ្ងៃតិចតួចដំបូងសម្បុរ ស្បែក ក៏បរិសុទ្ធល្អក្រៃលែង សស្អាតនិងឥន្ទ្រីយ៍ទាំងឡាយក៏ថ្លាផូរផង់ តែក្នុងពេលនេះលោកទាំងឡាយបែរជា មានសម្បុរសៅហ្មង លោកទាំងឡាយ នៅក្នុងព្រៃនោះមានសេចក្តីមិនសប្បាយយ៉ាងណាឬ? ក្នុងពេលនោះភិក្ខុមួយរូបឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងពេលកណ្តាលរាត្រីខ្ញុំព្រះករុណា បានឃើញនិងស្តាប់អារម្មណ៍ដែលគួរឲ្យព្រឺតក់ស្លុតភ័យខ្លាចយ៉ាងនេះ និងយ៉ាងនេះនិងធុំក្លិនដូចនេះដោយហេតុនោះ ចិត្តរបស់ខ្ញុំព្រះករុណាទើបមិន តាំងមាំ ភិក្ខុទាំងអស់ ក៏ប្រាប់ហេតុការណ៍នោះ ដោយឧបាយនោះដូចគ្នា ព្រះសង្ឃត្ថេរពោលថា អាវុសោទាំងឡាយ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់អនុញ្ញាតការចូលចាំវស្សា២ដងឯសេនាសននេះរបស់ពួកយើងមិនសប្បាយល្ហើយចុះពួកយើងនឹងទៅកាន់សំណាក់របស់ព្រះដ៏មានព្រះភាគជាម្ចាស់ហើយទូលសួរសេនាសនៈ ដទៃដែលសប្បាយ ភិក្ខុទាំងនោះឆ្លើយទទួលព្រះសង្ឃត្ថេរថា ព្រះករុណាលោកម្ចាស់ល្អហើយ ភិក្ខុទាំងអស់បានរក្សារៀបចំ ទុកដាក់

សេនាសនៈហើយកាន់យកបាត្រចីវរ មិនបានប្រាប់ មិនបានលាអ្វី ក្នុងត្រកូល ទាំងឡាយនោះទេ ព្រោះជាអ្នកមិនបានសេពគប់ស្និទ្ធ ស្នាលត្រាច់ទៅកាន់ចារិកដល់ក្រុងសាវត្ថីភិក្ខុទាំងនោះទៅកាន់ក្រុ-ងសាវត្ថីដោយលំដាប់ហើយទៅកាន់ទីគង់ប្រថាប់របស់ព្រះដ៏មាន ព្រះភាគជាម្ចាស់ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ឃើញភិក្ខុទាំងនោះហើយ ទើបត្រាស់ព្រះតម្រាស់ថាម្នាលភិក្ខុទាំងឡាយតថាគតបានបញ្ញត្តិ សិក្ខាបទថា ភិក្ខុមិនគប្បីត្រាច់ចារិកក្នុងខាងក្នុងព្រះវស្សា ហើយ ចុះអ្នកទាំងឡាយត្រាច់ចារិកដើម្បីប្រយោជន៍អ្វី ភិក្ខុទាំងនោះ ទូលប្រាប់រឿងទាំងអស់ចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះ ដ៏មានព្រះភាគជាម្ចាស់ព្រះទ្រង់បានពិចារណា (រកទីសេនាសនៈ សប្បាយដល់ភិក្ខុទាំងនោះ) ក៏មិនបានទ្រង់ឃើញសេនាសនៈណា ដែលជាជាទីសប្បាយរបស់ភិក្ខុទាំងនោះទេ ដោយទីបំផុតសូម្បី ត្រឹមតែកន្លែងដាក់តាំង ដែលមានជើងបួនក្នុងជម្ពូទ្វីបទាំងអស់ ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ពិចារណាហើយ ទើបត្រាស់ទៅ នឹងភិក្ខុទាំងនោះថា ម្នាលភិក្ខុទាំងឡាយសេនាសនៈ ដែលជាទី សប្បាយរបស់ពួកអ្នកមិនមាន ពួកអ្នកនៅក្នុងទីនោះឯងគប្បីដល់

នូវសេចក្ដីអស់ទៅនៃអាសវៈបាន ទៅចុះភិក្ខុទាំងឡាយ ពួកអ្នកចូរអាស្រ័យសេនាសនៈនោះចុះបើពួកអ្នកប្រាថ្នាសេចក្ដីមិនមានភ័យអំពីពួកទេវតាទាំងឡាយ ក៏ចូររៀនបរិត្តនេះ ទើបបានទ្រង់ត្រាស់សំដែង ព្រះសូត្រនេះ។ (សំដែងព្រះសូត្រនេះយ៉ាងនេះថា )

(សុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត តតិយភាគ លេខ៥៤ទំព័រ៥០)

ករណីយមត្ថកុសលេន យន្តំ សន្តំ បទំ អភិសមេច្ច
សក្កោ ឧជូ ច សុហុជូ ច សុវចោ ចស្ស មុទុអនតិមានី ។
សន្តុស្សកោ ច សុភរោ ច អប្បកិច្ចោ ច សល្លហុកវុត្តិ
សន្តិន្ទ្រិយោ ច និបកោ ច អប្បគព្ភោ កុលេសុ អននុគិទ្ធោ ។
ន ច ខុទ្ទំ សមាចរេ កិញ្ចិ យេន វិញ្ញូ បរេ ឧបវទេយ្យុំ ។
សុខិនោ វា ខេមិនោ ហោន្តុ សព្វេសត្តា ភវន្តុ សុខិតត្តា
យេកេចិ បាណភូតត្ថិ តសា វា ថាវរា វា អនវសេសា
ទីឃា វា យេ មហន្តា វា មជ្ឈិមា រស្សកា អណុកថូលា
ទិដ្ឋា វា យេ ច អទិដ្ឋា យេ ច ទូរេ វសន្តិ អវិទូរេ
ភូតា វា សម្ភវេសី វា សព្វេសត្តា ភវន្តុ សុខិត្តា ។
ន បរោ បរំ និកុព្វេថ នាតិមញ្ញេថ កត្ថចិ នំ កិញ្ចិ
ព្យារោសនា បដិឃសញ្ញា នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ ។

មាតា យថា និយំ បុត្តំ អាយុសា ឯកបុត្តមនុរក្ខេ

ឯវម្បិ សព្វភូតេសុ មានសម្ភាវយេ អបរិមាណំ ។

មេត្តញ្ច សព្វលោកស្មឹ មានសម្ភាវយេ អបរិមាណំ

ឧទ្ធំ អធោ ច តិរិយញ្ច អសម្ពាធំ អវេរំ អសបត្តំ

តិត្ឋញ្ចរំ និសិន្នោ វា សយានោ វា យាវ តស្ស វិគតមិទ្ធោ ។

ឯតំសតឹ អធិដ្ឋេយ្យ ព្រហ្មមេត្តំ វិហារំ ឥធមាហុ ។

ទិដ្ឋញ្ច អនុបគម្ម សីលវា ទស្សនេន សម្បន្នោ

កាមេសុ វិនេយ គេធំ ន ហិ ជាតុ គព្ភសេយ្យំ បុនរេតីតិ ។

(ប្រែថា) កិច្ចឯណាដែលព្រះអរិយបុគ្គលបានត្រាស់ ដឹងនូវចំណែកនៃធម៌ដ៏ស្ងប់រម្ងាប់ គឺព្រះនិព្វាន (បាន ធ្វើហើយ ) កិច្ចនោះ កុលបុត្រអ្នកឈ្លាសក្នុងប្រយោជន៍ គួរធ្វើ ( កុលបុត្រនោះ ) គួរជាអ្នកអាចហ៊ានផង មាន កាយវាចាត្រង់ផង មានសភាពទន់ភ្លន់ផង មិនមាន មានៈ ដ៏ក្រៃលែងផង ។ជាអ្នកសន្ដោសផង គេចិញ្ចឹម ងាយផង មិនមានកិច្ចកង្វល់ផង ប្រព្រឹត្តស្រាលព្រមផង មានឥន្ទ្រិយស្ងប់ផង មានប្រាជ្ញាចាស់ផង មិនឆ្គាំឆ្គង ផង មិនជាប់ចំពាក់ក្នុងត្រកូលទាំងឡាយផង ។

វិញ្ញូជនទាំងឡាយ គប្បីតិះដៀលនូវជនទាំងឡាយដទៃ ដោយកម្មណា មិនគួរប្រព្រឹត្តធ្វើនូវកម្មនោះ ដែលជាកម្មលាមក សូម្បីតិចតួច ( ហើយគប្បីផ្សាយមេត្តាចិត្តចំពោះពួកសត្វថា ) សូមឲ្យពួកសត្វទាំងពួងមានសេចក្តីសុខ មានសេចក្តីក្សេមក្សាន្ត មានខ្លួនដល់នូវសេចក្តីសុខចុះ ពួកសត្វដែលមានជីវិត ឥតមានសេសសល់ ទោះសត្វជាអ្នកមានសេចក្តីតក់ស្លុត គឺនៅមានតណ្ហាក្តី ជាអ្នកមាំមួន គឺឥតមានតណ្ហាក្តី ពួកសត្វដែលមានកាយវែងក្តី ធំក្តី មានកាយយ៉ាងកណ្តាលក្តី ខ្លីក្តី ស្គមក្តី ធាត់ក្តី ពួកសត្វដែលយើងឃើញក្តី មិនឃើញក្តី ពួកសត្វដែលនៅ ក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី កើតរួចហើយក្តី កំពុងស្វែងរកកំណើតក្តី សូមឲ្យសត្វទាំងអស់ (នោះ) មានខ្លួនដល់នូវសេចក្តីសុខចុះ ។ សត្វដទៃ មិនគួរកំហែងបៀតបៀនសត្វដទៃឡើយ មិនគួរមើលងាយគេតិចតួច ក្នុងទីណាមួយឡើយ មិនគួរប្រាថ្នានូវសេចក្តីទុក្ខ ដល់គ្នានិងគ្នា ដោយសេចក្តីក្រេវក្រោធ ដោយសេចក្តីចង្អៀតចង្អល់ឡើយ ។ មាតាថ្នមរក្សា

បុត្រ ដែលកើតអំពីខ្លួន ជាបុត្រតែមួយដោយអាយុ គឺថាសូម្បីជីវិតក៏ហ៊ានលះបង់ ក្នុងការរក្សានូវបុត្រ បាន យ៉ាងណាមិញ បុគ្គលគួរចំរើនមេត្តាចិត្តមិន មានប្រមាណ ចំពោះពួកសត្វទាំងពួង ក៏យ៉ាងនោះ ឯង បុគ្គលគួរចំរើនមេត្តាចិត្ត មិនមានប្រមាណ ជាធម៌ មិនចង្អៀត មិនមានពៀរ មិនមានសត្រូវ ទៅក្នុង លោកទាំងអស់ ទាំងខាងលើខាងក្រោម ទាំងទទឹង គឺត្រង់កណ្ដាលផង ( បុគ្គលអ្នកចំរើនមេត្តាចិត្តនោះ ) ទោះឈរក្ដី ដើរក្ដី អង្គុយក្ដី ដេកក្ដី ជាអ្នកមានសេចក្ដី ងោកងក់ទៅប្រាសហើយ គឺជាអ្នកមិនដេកលក់អស់ កាលត្រឹមណា គួរតម្កល់នូវមេត្តានុស្សតិនុះ ( អស់ កាលត្រឹមណោះ ) ។ បណ្ឌិតទាំងឡាយ ពោលនូវ ដំណើរនុះ ថាជាព្រហ្មវិហារ ក្នុងសាសនានេះ ។ ( បុគ្គលដែលមានមេត្តាព្រហ្មវិហារ ) មិនអាស្រ័យ នូវទិដ្ឋិ ជាអ្នកមានសីល ប្រកបដោយ ទស្សនសម្បត្តិ គឺសោតាបត្តិមគ្គ បន្ទោបង់នូវសេចក្ដី ត្រេកអរ ក្នុង កាមទាំងឡាយ ដោយសកទាគាមិមគ្គ នឹងអានាគា

មិមគ្គ រមែងមិនមកកាន់គព្ភសេយ្យាសន៍ គឺថា
មិនមកកើតក្នុងគភ៌ទៀតឡើយ ។

( អធិប្បាយក្នុងព្រះពុទ្ធដីកាដោយព្រះអដ្ឋកថា ថា )

អាចារ្យពួកខ្លះពោលថា ក៏ព្រះដ៏មានព្រះភាគជាម្ចាស់ជាម្ចាស់ កាលត្រាស់ព្រះតម្រាស់នេះថា ទៅចុះភិក្ខុទាំងឡាយពួកអ្នកចូរអាស្រ័យសេនាសននោះឯងចុះ ទើបត្រាស់ថាអើ!ឯភិក្ខុអ្នកនៅក្នុងព្រៃគប្បីជ្រាបការឃុំគ្រង គឺមេត្តា២បរិត្ត២អសុភ២មរណាសតិ២និង ការពិចារណាមហាសង្វេគវត្ថុ៨ជាតិ ជរា ព្យាធិមរណ៤អបាយទុក្ខ៤ឈ្មោះថា មហាសង្វេគវត្ថុ៨ ដោយអំណាចនៃការធ្វើក្នុងពេលត្រជាក់ និងពេលព្រឹកព្រហាម ម្យ៉ាងគប្បីជ្រាបមហាសង្វេគវត្ថុ ៨ គឺ ជាតិ ជរា ព្យាធិ មរណ ៤ អបាយទុក្ខទី៥ទុក្ខមានវដ្ដៈ ជាជាមូលក្នុងអតីតៈ ទុក្ខមានវដ្ដជាមូលក្នុងអនាគតទុក្ខមានការស្វែងរកអាហារជាមូលក្នុងបច្ចុប្បន្ន ព្រះដ៏មានព្រះភាគជាម្ចាស់ ពេល ដែលត្រាស់ប្រាប់ពីការឃុំគ្រងយ៉ាងនេះហើយទើបត្រាស់ព្រះសូត្រនេះដល់ភិក្ខុទាំងនោះដើម្បីមេត្តាដើម្បីការពារនិងដើម្បីឈានដែលមានវិបស្សនាជាបាត ដូច្នេះ ។

ក្នុងគាថាទាំងនោះ គាថាទីមួយនេះថា ករណីយមត្ថកុស-

លេន មានការពណ៌នាមុនតាមបទយ៉ាងនេះ ។ បទថា ករណីយ-មត្ថកុសលេនបានដល់ ប្រយោជន៍ដែលគួរធ្វើ។ អធិប្បាយថា គួរដល់ការធ្វើ។ បដិបទា ឈ្មោះថា ប្រយោជន៍ឬប្រយោជន៍អនុគ្រោះរបស់ខ្លួនយ៉ាងណាមួយនោះទាំងអស់ហៅថា ប្រយោជន៍ព្រោះជាប្រយោជន៍ដែលកុលបុត្រគួរបានទទួលព្រោះជា ប្រយោជន៍ដែលកុលបុត្រគប្បីចូលដល់ ឈ្មោះថា ព្រោះជាប្រយោជន៍ ដែលកុល-បុត្របានទទួល ។ អ្នកឆ្លាតក្នុងប្រយោជន៍ឈ្មោះថា អត្ថកុសល អធិប្បាយថាអ្នកឈ្លាសឆ្លាតក្នុងប្រយោជន៍ ។

បទថា **យំ** ជាបឋមាវិភត្តិ អនិយមសព្វនាម។ បទថា តំ ជាទុតិយាវិភត្តិនិយមសព្វនាម ។ បទថា **យន្តំ** សូម្បីទាំងពីរក៏ជាបឋ-មាវិភត្តិ។ បទថា **សន្តំ បទំ** ជាទុតិយាវិភត្តិ ។ ក្នុងបទទាំងពីរនោះឈ្មោះថា **សន្តំ** ក៏ព្រោះដោយលក្ខណៈឈ្មោះថា **បទំ** ព្រោះជាធម៌ដែលកុលបុត្រគប្បីដល់ ។ បទថា **សន្តំ បទំ** នោះជាឈ្មោះរបស់ព្រះនិព្វាន ។

បទថា **អភិសមេច្ច** បានដល់បន្ទុះហើយ ។ ឈ្មោះថាសក្កព្រោះអត្ថវិគ្រោះថា អាចហ៊ាន មានអធិប្បាយថាជាអ្នកអាចជាអ្នកមានកម្លាំងខ្លោះទៅ ។

បទថា **ឧជុ** បានដល់ អ្នកប្រកបដោយសេចក្តីទៀងត្រង់ ។ ឈ្មោះថា សុហុជុ ព្រោះអត្ថថា ដែលត្រង់ល្អ ។ ឈ្មោះថា សុវច ព្រោះអត្ថថា ប្រដៅងាយ ។ បទថា **អស្ស** បានដល់គប្បីមាន ។ បទថា មុទុ បានដល់អ្នកប្រកបដោយសភាពទន់ភ្លន់។អ្នកមិនធ្មើង ក្រអើតកោងកាច ជាអ្នកមិនរឹងត្អឹងឈ្មោះថា អនតិមានី ។

ក៏ក្នុងគាថានេះ មានការពណ៌នាសេចក្តីយ៉ាងនេះក្នុងបាទគាថានេះថា ករណីយមត្ថកុសលេន **យន្តំ សន្តំ បទំ អភិសមេច្ច** កិច្ចដែលគួរធ្វើក៏មាន កិច្ចដែលមិនគួរធ្វើក៏មាន ក្នុងកិច្ច២យ៉ាងនោះ ដោយបំព្រួញ សិក្ខា៣ជាកិច្ច ដែលគួរធ្វើ កិច្ចមានជាដើមយ៉ាងនេះថាសីលវិបត្តិ ទិដ្ឋិវិបត្តិ អាចារវិបត្តិ អាជីវវិបត្តិ ជាកិច្ចមិនគួរធ្វើម្យ៉ាងកុលបុត្រអ្នកឆ្លាតក្នុងប្រយោជន៍ក៏មាន កុលបុត្រអ្នកឆ្លាតក្នុងវត្ថុមិនជាប្រយោជន៍ក៏មាន ។

ក្នុងកុលបុត្រទាំងពីរពួកនោះ កុលបុត្រណាបួសក្នុងសាសនានេះហើយរមែងមិនប្រកបខ្លួនដោយប្រពៃ ជាអ្នកវិនាសចាកសីលសម្រេចការចិញ្ចឹមជីវិតដោយអាស្រ័យអនេសនៈ២១យ៉ាងគឺ ឲ្យឫស្សី ឲ្យស្លឹក ឲ្យផ្កា ឲ្យផ្លែឈើឲ្យឈើស្ទន់ ឲ្យទឹកលុបលាងមុខ ឲ្យគ្រឿងលាប ឲ្យលំអិត (ម្សៅ) ឲ្យដីស្អិតនិយាយយកចិត្តបញ្ចោរ

ដើម្បីឲ្យគេស្រលាញ់ និយាយម្តងលេងម្តងមែន ស្មើដោយ សម្ល សណ្តែក (និយាយឡូកឡំគ្នាដូចគេស្លសម្លកកូរ) ធ្វើជា អ្នកទទួលចិញ្ចឹមក្មេង ការទទួលបម្រើគ្រហស្ថ ការធ្វើវេជ្ជកម្ម ការធ្វើទូតកម្ម ការប្រព្រឹត្តជាអ្នកទន់ទាប ការឲ្យអាហារដើម្បីទាក់លាភ ការទាយផ្ទៃនៃផែនដី ការទាយនក្ខត្តឫក្ស ការមើលអវយវៈនិងត្រាច់ទៅក្នុងអគោចរ៦យ៉ាងគឺ ស្រីពេស្យា ស្រីមេម៉ាយ ស្រីក្រមុំចាស់ ខ្ទើយ ភិក្ខុនី និងតៀមស្រា និងទៅសេពគប់ស្និទ្ធស្នាលជាមួយព្រះរាជា អន្យតិរ្ថិយ៍ សាវ័ករបស់អន្យតិរ្ថិយ៍ការសេពគប់ស្និទ្ធស្នាលជាមួយគ្រហស្ថ ដែលមិនសមគួរ ឬ ក៏សេពគប់ចូលទៅរក ត្រកូលទាំងឡាយដែលមិនមានសទ្ធា មិនជ្រះថ្លា ជេរផ្តន្ទាទោសប្រាថ្នាភាព វិនាសបាត់បង់ ប្រាថ្នាចំពោះវត្ថុដែលមិនមែន ជាប្រយោជន៍ ធ្វើសេចក្តីមិនសប្បាយមិន សុខនិងសេចក្តីមិនក្សេមចាកយោគៈដល់ភិក្ខុទាំងឡាយ ។ល។ ឧបាសិកាទាំងឡាយ កុលបុត្រនេះឈ្មោះថាអ្នកថ្វាតក្នុងវត្ថុដែលមិនមានប្រយោជន៍ ។

ចំណែកកុលបុត្រណា បួសក្នុងសាសនានេះហើយ ប្រកបខ្លួនដោយប្រពៃ លះអនេសនៈ ជាអ្នកប្រាថ្នាដើម្បីតម្រង់ផ្លូវត្រោះ

ទៅក្នុងចតុបរិសុទ្ធិសីល បំពេញបាតិមោក្ខសំវរដោយសទ្ធាជាគ្រឹះ បំពេញ ឥន្ទ្រិយសំវរ ដោយសតិជាគ្រឹះ បំពេញ អាជីវបារិសុទ្ធិ ដោយវិរិយជាគ្រឹះ បំពេញ បច្ចយបដិសេវនា ដោយបញ្ញាជាគ្រឹះ កុលបុត្រនេះឈ្មោះថាអ្នកឆ្លាតក្នុងប្រយោជន៍ ។

ឬកុលបុត្រណាធ្វើឲ្យជ្រះស្អាតក្នុងបាតិមោក្ខសំវរ ដោយអំណាចនៃការជំរះអាបត្តិ៧កង ជំរះឥន្ទ្រិយសំវរៈ ដោយអំណាចនៃសេចក្តីសង្រួមមិនឲ្យកើតឡើងនូវឧបកិលេសទាំងឡាយ មាន **អភិជ្ឈា** ជាដើមក្នុងអារម្មណ៍ដែលមកប៉ះខ្ទប់ក្នុងទ្វារទាំង៦ ជំរះ អាជីវបារិសុទ្ធិ ដោយការគោរពកោតក្រែងស្តាប់តាមឱវាទរបស់ព្រះដ៏មានព្រះភាគជាម្ចាស់ អនុពុទ្ធសាវ័ក និងបុរសបណ្ឌិតដែលអ្នកប្រាជ្ញសរសើរហើយ ដោយអំណាចនៃការវៀរចាក អនេសនៈ ជំរះបច្ចយបដិសេវនៈ ដោយអំណាចនៃការពិចារណាតាមដែលពោលហើយ និងជម្រះសម្បជញ្ញដោយអំណាចនៃការ ពិចារណាវត្ថុដែលមានប្រយោជន៍ក្នុងការផ្លាស់ប្តូរឥរិយាបថទាំង៤កុលបុត្រនេះ ឈ្មោះថា អ្នកឆ្លាតក្នុងប្រយោជន៍ ។ ឬកុលបុត្រណាដឹងថា សីលបរិសុទ្ធបានអាស្រ័យបញ្ញា ដូចសំពត់កខ្វក់ រមែងស្អាតបាន

ព្រោះអាស្រ័យទឹកស្អាត កញ្ចក់ថ្លាស្អាតបាន ព្រោះអាស្រ័យផេះ មាសបរិសុទ្ធបានព្រោះអាស្រ័យការរំលាយក្នុងពុម្ពដូច្នោះ ការលាងសម្អាតហើយដោយទឹកគឺញាណ ឈ្មោះថា ញ៉ាំងសីលឲ្យបរិសុទ្ធ និងជាអ្នកមិនប្រមាទឡើយ រមែងរក្សាសីលក្ខន្ធរបស់ខ្លួន ដូចសត្វត្រដេវរិចរក្សាស៊ុត (ពង) សូម្បីសត្វចាមរីរក្សាកន្ទុយ ស្ត្រីអ្នកមានកូនតូចតែម្នាក់ រក្សាកូនតូចម្នាក់ដែលជាទីស្រលាញ់ និងបុរសមានភ្នែកតែម្ខាងនោះ ដូច្នោះ ពិចារណាហើយទាំងពេលក្តៅទាំងពេលត្រជាក់ (ទាំងយប់ទាំងថ្ងៃ) រមែងមិនឃើញទោសមានប្រមាណតិចតួច ឈ្មោះថា អ្នកឆ្លាតក្នុងប្រយោជន៍ ។

ក៏កុលបុត្រណាចេញពីសមាបត្តិ ពិចារណាសង្ខារទាំងឡាយហើយបន្ទុះព្រះអរហត្ត កុលបុត្រនេះ ជាកុលបុត្រអ្នកឆ្លាតក្រៃលែងលើសលប់នៃកុលបុត្រអ្នកឆ្លាតទាំងឡាយ ។

ក្នុងគាថានោះ ភិក្ខុទាំងនេះសូម្បីឯណាជាអ្នកឆ្លាតក្នុងប្រយោជន៍ដែលពណ៌នាហើយ តាំងតែអំពីការតម្រង់ឲ្យត្រង់នៅក្នុងសីលជាគ្រឿងធ្វើមិនឲ្យក្តៅក្រហាយឬតាំងតែអំពីការផ្គង់ឡើងក្នុងបដិបទា ជាគ្រឿងដុសខាត់កិលេស ភិក្ខុទាំងនោះលោកសង្គ្រោះថា ជាអ្នកឆ្លាតក្នុងប្រយោជន៍ ក្នុងអត្ថនេះ ភិក្ខុទាំងនោះក៏យ៉ាង

នោះ ដោយហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទើបត្រាស់ថា **ករណីយមត្ថកុសលេន** ដោយទេសនា ដែលមានបុគ្គលតែមួយជាទីតាំង ទ្រង់សំដៅដល់ភិក្ខុទាំងនោះ បន្ទាប់ពីនោះទើប ត្រាស់ថា **យន្តំ បទំ អភិសមេច្ច** ដល់ពួកភិក្ខុនោះអ្នកកើតសេចក្ដី សង្ស័យថា ប្រយោជន៍នឹងគប្បីធ្វើដូចម្ដេច អធិប្បាយដូច្នេះ បទណាដែលកុលបុត្រអ្នកត្រូវការដើម្បីនឹងបន្ទុះ **បទ** គឺព្រះនិព្វាន ដ៏ស្ងប់ដោយការចាក់ធ្លុះ គួរធ្វើបទនោះដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ និងព្រះ-អនុពុទ្ធទាំងឡាយសំដែងទុកហើយ ។

ក៏ក្នុងគាថានេះ បទដែលពោលហើយខាងដើមនៃគាថាទាំងនេះថា **យំ** រមែងឃើញដោយ អធិការថា **ករណីយំ** ។

បទថា **តំ សន្តំ បទំ អភិសមេច្ច** គប្បីជ្រាបថា ក៏សេចក្ដីនេះមានបាលីដទៃផ្សេងទៀតព្រោះដូច្នោះលោកទើបពោលថា វិហរិតុកាមេន ។ ម្យ៉ាងទៀតក្នុងបទថា **សន្តំ បទំ អភិសមេច្ច** នេះគប្បីជ្រាបអធិប្បាយថា កុលបុត្រអ្នកឆ្លាតក្នុងប្រយោជន៍ដឹងនិព្វាន ។ បទថា មានអ្នកចង់ដើម្បីនឹងបន្ទុះនិព្វាននោះ គប្បីធ្វើកិច្ចដែលឃើញដោយអធិការថា គប្បីធ្វើ ។

ម្យ៉ាងទៀតត្រាស់សំដែងថា **ករណីយមត្ថកុសលេន** ទើប

ត្រាស់ថា ***យន្តំ សន្តំ បទំ អភិសមេច្ច*** ដល់ភិក្ខុទាំងឡាយអ្នកគិតថា អ្វីហ្ន៎ អ្នកសិក្សាគប្បីអធិប្បាយបទនោះថា កុលបុត្រត្រាស់ដឹងនូវបទដែលស្ងប់ដោយលោកិយបញ្ញាគប្បី ធ្វើប្រយោជន៍ដែលគួរធ្វើ មានអធិប្បាយថា ប្រយោជន៍នោះ គួរធ្វើយ៉ាងពិតប្រាកដ ។

សួរថា ក៏ប្រយោជន៍នោះគឺអ្វី ឆ្លើយថា ក្រៅតែអំពីឧបាយដែលជាគ្រឿងបន្ទុះ សន្តិបទនោះ នឹងគប្បីមានប្រយោជន៍អ្វី ដទៃទៀតហ្ន៎ ក៏សន្តិបទនោះ បានពោលហើយ ដល់បទដើមដែលសម្ដែងដល់ត្រៃសិក្ខា ដោយអត្ថថា សមគួរដល់ការធ្វើ សូម្បីក៏ពិតដល់ការធ្វើនោះ ខ្ញុំបានពោលហើយក្នុងការពណ៌នាសេចក្ដីនៃបទនោះថា ប្រយោជន៍គួរធ្វើក៏មាន ប្រយោជន៍មិនគួរធ្វើក៏មាន ក្នុងប្រយោជន៍២យ៉ាងនោះ ដោយបំព្រួញឲ្យខ្លីទៅថាត្រៃសិក្ខាជាប្រយោជន៍ដែលគួរធ្វើ ទ្រង់ត្រាស់សម្ដែងដោយសេចក្ដី ដ៏ក្រៃលែងជាងនេះពួកភិក្ខុទាំងនោះ ភិក្ខុខ្លះដឹង ភិក្ខុខ្លះមិនដឹង ពេលនោះព្រះដ៏មានព្រះភាគព្រះអង្គទ្រង់សម្ដែងប្រយោជន៍របស់ភិក្ខុដែលជាអ្នកនៅព្រៃជាវត្ត នឹងគប្បីធ្វើដោយពិសេសឲ្យពិស្ដារ ដើម្បីឲ្យភិក្ខុដែលនៅមិនបានដឹងទើបត្រាស់កន្លះគាថានេះមុនថា ជាអ្នកអាចហ៊ាន ជាអ្នកត្រង់ ប្រដៅងាយ ទន់ភ្លន់ មិនកោងកាចដូច្នេះ ។

មានអធិប្បាយដូចម្តេច? កុលបុត្រអ្នកនៅក្នុងព្រៃជាវត្ត ប្រាថ្នានឹងត្រាស់ដឹងសន្តិបទ ឬត្រាស់ដឹងសន្តិបទនោះ ដោយលោកិយបញ្ញាបដិបត្តិដើម្បីបន្ទុះសន្តិបទនោះ មិនអាល័យក្នុងកាយនិងក្នុងជីវិត ដោយការដល់ព្រមដោយសេចក្តីព្យាយាមបំពេញអង្គទី២និងអង្គទី៤គប្បីអាចដើម្បីបដិបត្តិក្នុងការចាក់ធ្លុះសច្ចៈ ម្យ៉ាងទៀតគប្បីជាអ្នកអាចហ៊ានក្នុងករណីយកិច្ចតូចធំ របស់សព្រហ្មចារីទាំងឡាយមានកសិណបរិកម្មនិងការសមាទានវត្តជាដើម ក្នុងកិច្ចទាំងឡាយមានការបិទប៉ះបាត្រដែលធ្លុះនិងដេរចីវររបស់ខ្លួននិងក្នុងកិច្ចដទៃបែបនោះ ជាអ្នកព្យាយាម មិនខ្ជិលច្រអូស ជាអ្នកអាចហ៊ានទោះបីជាអ្នកមិនអាចហ៊ាន ក៏ជាអ្នកត្រង់ត្រឹមត្រូវ ដោយការដល់ព្រមដោយសេចក្តីព្យាយាមបំពេញអង្គទី៣ ទោះបីនឹងជាអ្នកត្រង់ ក៏ត្រង់មិនដល់សេចក្តីពេញចិត្ត ដោយសេចក្តីជាអ្នកត្រង់មួយពេលគប្បីជាអ្នកត្រង់ឲ្យល្អជាង ដោយការធ្វើប្រសើរត្រង់ត្រឹមត្រូវរហូតអស់ជីវិត ឬក៏ថាជាអ្នកត្រង់ព្រោះភាពជាអ្នកមិនមានអំនួតជាអ្នកដែលត្រង់ព្រោះជាអ្នកមិនមានមាយាលាក់ពុត ជាអ្នកត្រង់ដោយការលះបង់ភាពវៀចវេរ ផ្លូវកាយ និងផ្លូវវាចា ជាអ្នកដែលត្រង់ដោយការលះបោលនូវភាពមិនទៀងត្រង់ផ្លូវចិត្ត ឬជាអ្នកត្រង់

ដោយការមិនរោយរាយ ពោលអួតគុណដែលមិនមាន គប្បីជាអ្នកត្រង់ និងជាអ្នកដែលត្រង់ដោយ អារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ដោយសិក្ខា២ជាសេចក្ដីខាងដើម និងសិក្ខាទី៣ព្រមដោយការអាស្រ័យប្រយោគដ៏បរិសុទ្ធ ។

និងគប្បីជាអ្នកត្រង់ ជាអ្នកដែលត្រង់តែម្យ៉ាងក៏នឹងត្រូវជាអ្នកប្រដៅងាយទៀតផង ជាការពិតណាស់ បុគ្គលណា ត្រូវគេពោលថាលោកមិនគួរធ្វើវត្ថុនេះ តែងពោលថាលោកមើលឃើញអ្វី លោកស្ដាប់ឮអ្វីលោកជាអ្វីរបស់ខ្ញុំទើបនិយាយដូចជាឧបជ្ឈាយ៍ជាអាចារ្យ ជាមិត្តតាមមើលជាមិត្តតាមស៊ីឬ ? ឬរមែងបៀតបៀនដោយភាពជាអ្នកនៅស្ងៀម ឬទទួលហើយមិនធ្វើតាមសំដីដែលទទួលព្រមបុគ្គលនោះរមែងនៅក្នុងទីដែលឆ្ងាយនៃការបន្ទុះគុណវិសេស ។

ចំណែកបុគ្គលណាត្រូវបានទទួលពាក្យទូន្មាន រមែងពោលថាល្អហើយលោកដ៏ចម្រើនលោកពោលនេះល្អណាស់គឺល្អក្រៃលែងឈ្មោះថាទោសរបស់ខ្លួនឯង គឺឃើញបានដោយលំបាកណាស់លោកឃើញយ៉ាងនោះហើយគប្បីអាស្រ័យសេចក្ដី (អនុគ្រោះ)

សម្ទឹងមើលពោលដាស់តឿនខ្ញុំទៀត  ខ្ញុំបានទទួលឱវាទអំពី សំណាក់របស់លោកយឺតពេកហើយ ដូច្នេះ និងបដិបត្តិការ ដែលក្រើនរំលឹកប្រៀនប្រដៅ (របស់លោក) បុគ្គលនោះជាអ្នកនៅក្នុងទីជិតនៃការបន្ទុះគុណវិសេស ។ ព្រោះដូច្នោះ បុគ្គលទទួលស្តាប់ពាក្យរបស់អ្នកដទៃ ហើយធ្វើយ៉ាងនេះ គប្បីជាអ្នកប្រដៅផាយ និងគប្បីជាអ្នកទន់ភ្ញន់ដូចជាអ្នកប្រដៅផាយ ។ បទថា មុទុសេចក្តីថា កុលបុត្រត្រូវគ្រហស្ថទាំងឡាយប្រើក្នុងកិច្ចទាំងឡាយមានការជាអ្នកនាំទូត និងការប្រព្រឹត្តទៅដូចជាមនុស្សអាក្រក់ មិនធ្វើសេចក្តីទន់ជ្រាយក្នុងកិច្ចនោះត្រូវជាអ្នកមាំមួនតែគប្បីជាអ្នកទន់ភ្ញន់ក្នុងកិច្ចបដិបត្តិ និង ក្នុងការប្រព្រឹត្តព្រហ្មចរិយទាំងអស់ ជាអ្នកគួរដល់ការណែនាំក្នុងកិច្ចនោះៗឲ្យដូចជាមាសដែលជាងមាសរំលាយល្អហើយដូច្នោះ។ ប្រការមួយទៀត បទថា មុទុ បានដល់ គប្បីជាអ្នកស្រស់បស់ មិនចងចិញ្ចើម គឺជាអ្នកមានមុខរីករាយពោលសំដី ចរចាពីរោះ ប្រព្រឹត្តបដិសណ្ឋារជាអ្នកប្រកាន់ខ្ជាប់ (គឺកាន់យក)សេចក្តីមកឲ្យដូចវត្ថុដែលតាំងល្អហើយដូច្នោះកុលបុត្តនឹងគប្បីជាអ្នកទន់ភ្ញន់តែម្តងដោយកម្រកបាន និងគប្បីជាអ្នក មិនក្រអើតកោងកាចទៀតផង គឺមិនត្រូវមើលផាយអ្នកដទៃទាំងឡាយដោយអតិ-

មានៈវត្ថុមានជាតិនិងគោត្រជាដើម គប្បីជាអ្នកនៅ ដោយចិត្ត (គិតថា) ស្មើដោយក្មេងចណ្ឌាល (ម្នាក់ប៉ុណ្ណោះ) ដូចព្រះសារី-បុត្តត្ថេរដូច្នោះឯង ។

ព្រះដ៏មានព្រះភាគជាម្ចាស់កាលដែលទ្រង់ត្រាស់ប្រយោ-ជន៍ដែលគួរធ្វើសម្រាប់ភិក្ខុអ្នកនៅក្នុងព្រៃជាវត្តដោយពិសេសអ្នកណាដើម្បីនឹងបានត្រាស់ដឹងសន្តិបទហើយ ឬបដិបត្តិដើម្បីបន្ទុះសន្តិបទនោះ យ៉ាងនេះហើយទ្រង់ព្រះប្រាថ្នានឹងត្រាស់ប្រយោជន៍ដែលគួរធ្វើសូម្បីដ៏ក្រៃលែងជាងនោះទៀត ទើបត្រាស់គាថាទី២នេះថា **សន្តុស្សកោ ច** ដូច្នេះ ។

ក្នុងគាថា នោះកុលបុត្រឈ្មោះថាជាអ្នកសន្តោស ព្រោះ-អត្ថវិគ្រោះថា រមែងត្រេកអរដោយការសន្តោស១២យ៉ាងមានប្រ-ភេទដូចដែលពោលហើយក្នុងគាថានេះថា **សន្តុដ្ឋី ច កញ្ញុតា** ។ ន័យម្យ៉ាងទៀត កុលបុត្រឈ្មោះថា ជាអ្នកមានសេចក្ដីពេញចិត្ត ព្រោះអត្ថវិគ្រោះថា រមែងពេញចិត្ត ។ កុលបុត្រអ្នកសន្តោសព្រោះអត្ថថា អ្នកពេញចិត្ត អ្នកពេញចិត្តដោយវត្ថុជារបស់ខ្លួន ពេញចិត្តដោយរបស់ដែលមាន ពេញចិត្តដោយប្រពៃ ។

បណ្ដា(សេចក្ដី)៣យ៉ាងនោះបច្ច័យ៤ដែលខ្លួនឯងទទួលហើយ ដែលយកឡើងក្នុងមណ្ឌលនៃការឧបសម្បទាយ៉ាងនេះថា អាស្រ័យភោជន គឺបាយដែលរកបានមកដោយស្មង ឈ្មោះថា របស់ខ្លួន កុលបុត្រមិនសំដែងអាការខុសប្លែកក្នុងពេលទទួលនិងពេលបរិភោគដោយបច្ច័យ៤នោះ ល្អក៏ដោយ មិនល្អក៏ដោយ ដែលគេឲ្យដោយគោរព ឬមិនគោរពក៏ដោយ ហៅថា អ្នកពេញចិត្តដោយវត្ថុជារបស់ខ្លួន ។

វត្ថុណាដែលខ្លួនបានហើយជារបស់មានហើយសម្រាប់ខ្លួន វត្ថុនោះ ឈ្មោះថា **របស់មាន** កុលបុត្រត្រេកអរដោយរបស់មានហើយនេះឯង គឺមិនប្រាថ្នាវត្ថុដទៃ ក្រៅអំពីវត្ថុដែល មានហើយនោះ លះបង់នូវភាពជាអ្នកប្រាថ្នាលើសលប់ចេញ ហៅថា ពេញ-ចិត្តដោយរបស់ដែលមានហើយ ។

ការលះអនុស័យ និងបដិឃៈក្នុងឥដ្ឋារម្មណ៍និងអនិដ្ឋារម្ម-ណ៍ឈ្មោះថា ល្អប្រពៃ កុលបុត្រពេញចិត្តក្នុងអារម្មណ៍ទាំងពួងដោយប្រពៃនោះ ហៅថាពេញចិត្តដោយប្រពៃ ។

ឈ្មោះថា **អ្នកចិញ្ចឹមងាយ** ព្រោះអត្ថវិគ្រោះថាអ្នកដែលគេចិញ្ចឹមដោយងាយ អធិប្បាយថា អ្នកដែលចិញ្ចឹមមើលថៃដោយ

ងាយ ពិតមែនហើយ ភិក្ខុណាសំដែងសេចក្ដីជាអ្នក មានទឹកមុខស្រពោនស្មេកស្មាំង និងភាពជាអ្នកមិនពេញចិត្តក្នុងបិណ្ឌបាតសូម្បីដែលគេដាក់បាយអង្ករស្រូវសាលីជាដើមពេញបាត្រថ្វាយ ឬរុញច្រានចោលនូវបិណ្ឌបាតនោះចំពោះមុខគេទាំងឡាយថា ពួកលោកឲ្យអ្វី រមែងឲ្យដល់សាមណេរ និងគ្រហស្ថ ភិក្ខុនោះឈ្មោះ-ថា ចិញ្ចឹមលំបាកៗមនុស្សទាំងឡាយឃើញភិក្ខុនោះរមែងគេចចេ-ញអំពីចម្ងាយតែម្ដងថា ភិក្ខុចិញ្ចឹមបានដោយលំបាកមិនអាចនឹងចិញ្ចឹមបម្រុងរក្សាបាន ។ ចំណែកកុលបុត្រណា បានបិណ្ឌបាតយ៉ាងណាម្យ៉ាងសៅហ្មងក៏ដោយ ប្រណីតក៏ដោយ តិចក៏ដោយច្រើនក៏ដោយ មានចិត្តថាជារបស់ខ្លួនមានមុខថ្លាស្អាតញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ កុលបុត្រនោះឈ្មោះថា ចិញ្ចឹមងាយ មនុស្សទាំងឡាយឃើញកុលបុត្រនោះហើយ ជូរចិត្តយ៉ាងក្រៃលែងថា លោកម្ចាស់របស់យើងចិញ្ចឹមងាយ រមែងត្រេកអរសូម្បីដោយរបស់តិចតួចពួកយើងប៉ុណ្ណោះ នឹងទំនុកបម្រុងចិញ្ចឹម លោកម្ចាស់នោះដូច្នេះហើយធ្វើការបេ្ដជ្ញា ទំនុកបម្រុងចិញ្ចឹម ។ កុលបុត្រមានស-ភាព យ៉ាងនេះ ទ្រង់ប្រាថ្នាថាជាអ្នកចិញ្ចឹមងាយក្នុងគាថានេះ ។

ឈ្មោះថា **មានកិច្ចតិច** ព្រោះអត្ថវិគ្រោះថា កុលបុត្រនោះ

មានកិច្ចតិច គឺជាអ្នកមិនខ្វល់ខ្វាយក្នុងកិច្ចច្រើនយ៉ាងមានសភាពជាអ្នកត្រេកអរក្នុងការងារ ត្រេកអរក្នុងការបត់បែន និងត្រេកអរក្នុងសេចក្ដីស្និទ្ធស្នាលជាដើម ។ មួយប្រការទៀត មានពាក្យអធិប្បាយថា កុលបុត្រនោះវៀរចាកកិច្ចមានការធ្វើនវកម្មក្នុងវិហារទាំងអស់ ការប្រៀនប្រដៅក្រុមជំនុំសង្ឃសាមណេរ និងអារាមិកជនជាដើម ធ្វើនូវកិច្ចរបស់ខ្លួនមានការកោរសក់កាត់ក្រចក ដុតបាត្រ ដេរចីវរជាដើម ឈ្មោះថា ជាអ្នកមានកិច្ច គឺសមណធម៌ ជាប្រមុខ ។

ឈ្មោះថា មានសេចក្ដីប្រព្រឹត្តបន្ទោបង់ ព្រោះអត្ថថា កុលបុត្រនោះមានសេចក្ដីប្រព្រឹត្តបន្ទោបង់ ភិក្ខុរូបខ្លះ ជាអ្នកមានវត្ថុរបស់របរច្រើន ក្នុងពេលដែលត្រាច់ទៅកាន់ទិសក៏ឲ្យមហាជន ប៉ះបាត្រ ដេរចីវរ សំពត់ក្រាលដេកប្រេងស្ករអំពៅដ៏ច្រើនដើរទូលនិងសីសៈខ្លះកណ្ដៀតខ្លះយ៉ាងនេះជាដើមត្រាច់ទៅហើយ យ៉ាងណាកុលបុត្រអ្នកមិនដូច្នោះជាអ្នកមានបរិក្ខារតិចប្រើប្រាស់ចំពោះតែសមណបរិក្ខារ៨មានបាត្រនិងចីវរជាដើមប៉ុណ្ណោះ ក្នុងពេលចារិកទៅកាន់ទិស ក៏កាន់យកបរិក្ខារប៉ុណ្ណោះត្រាច់ទៅដូចសត្វមានស្លាបដូច្នោះ ។ កុលបុត្រមានសភាពយ៉ាងនោះ ទ្រង់ប្រាថ្នាសេចក្ដីប្រ-

ព្រឹត្ត បន្ទោបង់ក្នុងគាថានេះ ។

ឈ្មោះថា មានឥន្ទ្រិយដែលស្ងប់ហើយ ព្រោះអត្ថថា កុលបុត្រនោះមានឥន្ទ្រិយទាំងឡាយស្ងប់ហើយ អធិប្បាយថា មានឥន្ទ្រិយមិនរវើរវាយអណ្ដែតអណ្ដូង ដោយអំណាចនៃរាគៈជាដើម ក្នុងអារម្មណ៍ទាំងឡាយមានឥដ្ឋារម្មណ៍ជាដើម ។

បទថា **និបកោ** បានដល់ដឹងច្បាស់ គឺអ្នកមានសេចក្ដីដឹងបានដល់អ្នកមានបញ្ញា អធិប្បាយថាអ្នកដល់ព្រមហើយដោយបញ្ញាជាគ្រឿងតាមទំនុកបម្រុងថែរក្សាសីលដោយបញ្ញាជាគ្រឿងពិចារណាចីវរបច្ច័យជាដើម និងដោយបញ្ញាកំណត់ដឹងសប្បាយ ៧យ៉ាង មានអាវាសជាដើម ។ ឈ្មោះថា **មិនថ្កាំថ្កង** ព្រោះអត្ថថា មិនមានសេចក្ដីថ្កាំថ្កង អធិប្បាយថា វៀរចាកសេចក្ដីថ្កាំថ្កងដោយកាយ ៨ ឋានៈ សេចក្ដីថ្កាំថ្កងដោយ វាចា ៤ ឋានៈ សេចក្ដីថ្កាំថ្កងដោយចិត្តមានច្រើនឋានៈ ។

ការធ្វើមិនសមគួរ ផ្លូវកាយក្នុងការចូលទៅរក ជំនុំសង្ឃគណៈ បុគ្គល រោងឆាន់ រោងភ្លើង កំពង់ទឹក ផ្លូវភិក្ខាចារ និងក្នុងចន្លោះផ្ទះ ឈ្មោះថាសេចក្ដីថ្កាំថ្កងដោយកាយមាន ៨ ឋានៈ គឺភិក្ខុរូបខ្លះក្នុងសាសនានេះអង្គុយឱបក្បាលជង្គង់ឬអង្គុយសណ្ដូកជើង

ក្នុងកណ្ដាលជំនុំសង្ឃ យ៉ាងនេះជាដើម ។ ក្នុងកណ្ដាលនៃគណៈ ក៏យ៉ាងនោះ ពាក្យថា ក្នុងកណ្ដាលគណៈ បានដល់ ក្នុងការប្រជុំ បរិស័ទទាំង ៤ ។ ក្នុងបុគ្គល អ្នកដែលមានវ័យចម្រើនជាង ( ចាស់ជាង) ក៏យ៉ាងនោះ ក្នុងរោងឆាន់ក៏មិនឲ្យអាសនៈដល់ភិក្ខុអ្នកមានវស្សាចាស់ទាំងឡាយ រមែងហាមឃាត់អាសនៈរបស់ភិក្ខុថ្មីទាំងឡាយ ។ ក្នុងផ្ទះជារោងភ្លើងក៏យ៉ាងនោះក៏ក្នុងរោងភ្លើងនោះ មិនសូមអនុញ្ញាតភិក្ខុអ្នកមានវស្សាចាស់ទាំងឡាយ ធ្វើកិច្ចទាំងឡាយមានការបង្កាត់ភ្លើងជាដើម ។

ក៏ក្នុងកំពង់ទឹក លោកពោលថា គប្បីង្ងូតទឹកតាមលំដាប់អ្នកមក ( អ្នកមកមុនមកក្រោយ)ដោយមិនធ្វើកំណត់ថាភិក្ខុចាស់-វស្សា ភិក្ខុថ្មី ភិក្ខុខ្ចះមិនអើពើរឿងសូម្បីនោះមកពេលក្រោយ ចុះង្ងូតទឹកបៀតបៀនភិក្ខុអ្នកចាស់វស្សា និងអ្នកថ្មីដោយវស្សា ។ ចំណែកក្នុងផ្លូវភិក្ខាចារក៏ដើរទៅខាងមុខៗរបស់ភិក្ខុអ្នកចាស់ទាំងឡាយដើម្បីអាសនៈដែលល្អប្រសើរ ទឹកដ៏ល្អប្រសើរ បិណ្ឌបាត្រដ៏ល្អប្រសើរ យកដៃផ្ទប់ដៃចូលទៅមុនថា ភិក្ខុអ្នកចាស់ទាំងឡាយក្នុងការចូលទៅកាន់ចន្លោះផ្ទះរមែងធ្វើនូវការលេងផ្លូវកាយដោយភិក្ខុកំឡោះទាំងឡាយដូច្នេះជាដើម ។

ការបញ្ចេញវាចាដែលមិនសមគួរក្នុង ជំនុំសង្ឃ គណៈបុគ្គល និងក្នុងចន្លោះផ្ទះ ឈ្មោះថា សេចក្តីផ្ចាំផ្ចង់វាចាមាន៤ឋានៈ គឺភិក្ខុរូបខ្លះក្នុងសាសនានេះ មិនសូមអនុញ្ញាតសម្តែងធម៌ក្នុងកណ្តាលជំនុំសង្ឃ ។ ក្នុងគណៈ និងក្នុងបុគ្គលអ្នកចាស់ជាង មានប្រការដូចដែលពោលហើយក្នុងកាលមុន ក៏យ៉ាងនោះដែរ ភិក្ខុរូបខ្លះត្រូវពួកមនុស្សទាំងឡាយ សួរបញ្ហាក្នុងកណ្តាលជំនុំសង្ឃនោះ មិនសូមអនុញ្ញាតពីភិក្ខុដែលមានវស្សាចាស់ជាង ដោះស្រាយបញ្ហា ។ ចំណែកក្នុងចន្លោះផ្ទះពោលពាក្យទាំងនេះថា ក្នុងទីនេះ ក្នុងទីឈ្មោះមានអ្វីមានបបរឬខាទនីយៈរបស់ឆាន់លោកនឹងឲ្យអ្វីដល់អាត្មា ក្នុងថ្ងៃនេះអាត្មានិងបានអ្វីទំពារ ឆាន់អ្វី ផឹកអ្វី ដូច្នេះជាដើម ។

ការមិនដល់អជ្ឈាចារដោយកាយ និងវាចាក្នុងឋានទាំងនោះៗទេ ត្រឹមតែដល់វត្ថុដែលមិនសមគួរផ្សេងៗ មាន កាមវិតក្កជាដើមដោយចិត្តតែម្យ៉ាង ឈ្មោះថាផ្ចាំផ្ចង់ដោយចិត្ត (គឺ) មានច្រើនយ៉ាង ។

បទថា កុលេសុ **អននុគិទ្ធោ** សេចក្តីថា មិនពាក់ព័ន្ធក្នុងត្រកូលទាំងឡាយ ដែលខ្លួនចូលទៅរកដោយសេចក្តីលំបាក ក្នុង

បច្ច័យឬដោយអំណាចនៃសេចក្ដីស្និទ្ធស្នាលជាមួយគ្រហស្ថដោយសេចក្ដីមិនសមគួរ អធិប្បាយថា មិនសោកសៅផង មិនត្រេកត្រអាលផង មិនសុខ ក្នុងត្រកូលដែលមានសេចក្ដីសុខ មិនកើតទុក្ខក្នុងត្រកូលដែលមានសេចក្ដីទុក្ខ មិនដល់ការប្រកបដោយខ្លួនឯងក្នុងកិច្ចទាំងឡាយដែលកើតឡើង ក៏ក្នុងគាថានេះបទថា**អស្ស** បានពោលហើយ ក្នុងបទថា **សុវចោ អស្ស** គប្បីប្រកបពាក្យនោះជាមួយបទទាំងពួងយ៉ាងនេះថា **សន្តុស្សកោ ច អស្ស សុភរោ ច អស្ស** នេះដូច្នេះ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលដែលទ្រង់សំដែងប្រាប់ នូវកិច្ចដែលគួរធ្វើ ដ៏ក្រៃលែងជាងនោះ ដល់ភិក្ខុអ្នកនៅព្រៃដោយពិសេស អ្នកប្រាថ្នា សន្តិបទ ហើយ ឬបានដើម្បីបដិបត្តិ ដើម្បីបន្ទុះសន្តិបទយ៉ាងនេះហើយ បទនេះទ្រង់ព្រះប្រាថ្នាដើម្បីត្រាស់ប្រាប់កិច្ចសូម្បីមិនគួរធ្វើទើបត្រាស់កន្លះគាថានេះថា មិនគប្បីប្រព្រឹត្តទុច្ចរិតអ្វីៗតិចតួច ដែលជាហេតុឲ្យបណ្ឌិតតិះដៀលបាន ។

គាថានោះមានសេចក្ដីថា កាលធ្វើជាប្រយោជន៍ដែលគួរធ្វើនេះយ៉ាងនេះ ដែលមិនគប្បីប្រព្រឹត្តទុច្ចរិតផ្លូវកាយ ផ្លូវវាចានិងផ្លូវចិត្ត ដែលហៅថាតិចតួច គឺ លាមក កាលមិនប្រព្រឹត្តទុច្ចរិតតិច

តួច  គប្បីប្រព្រឹត្តទុច្ចរិតអាក្រក់តែមួយក៏មិនមាន  តែគប្បីប្រព្រឹត្តទុច្ចរិតអ្វីហ្ន មានអធិប្បាយថា  មិនគប្បីប្រព្រឹត្តទុច្ចរិតប្រមាណតូចគឺសូម្បីតិចតួចតែផ្ទុយអំពីនោះគប្បីប្រព្រឹត្ត  គឺសំដែងទោសដែលដឹងសូម្បីខ្លួនឯង  ទុច្ចរិតនោះ ដែលជាហេតុ ឲ្យអ្នកដទៃជាអ្នកដឹងតិះដៀលបាន ។

ក៏ក្នុងគាថានេះព្រោះអ្នកមិនដឹងពួកដទៃ  មិនជាប្រមាណដោយថាអ្នកមិនដឹងទាំងនោះ រមែងធ្វើវត្ថុដែលមិនមានទោស ឲ្យមានទោសខ្លះ  រមែងធ្វើវត្ថុដែលមានទោសតិចឲ្យមានទោសច្រើនខ្លះ ចំណែកលោកអ្នកដឹងទាំងឡាយប៉ុណ្ណោះជាប្រមាណ  ព្រោះលោកអ្នកដឹងទាំងនោះ  បានពិចារណាហើយ   រមែងពោលតិះដៀលដល់អ្នកដែលគួរតិះដៀល   រមែងពោលសរសើរដល់អ្នកដែលគួរសរសើរ  ព្រោះដូច្នោះ  ព្រះដ៏មានព្រះភាគជាម្ចាស់  ទើបត្រាស់ថា **វិញ្ញូ** **បរេ**  ប្រែថា លោកអ្នកដឹងដទៃដូច្នេះ ។

ព្រះដ៏មានព្រះភាគជាម្ចាស់កាលត្រាស់ឧបចារៈនៃកម្មដ្ឋានដែលផ្សេងដោយប្រយោជន៍  ដែលគួរធ្វើនិងមិនគួរធ្វើដល់អ្នកនៅព្រៃជាវត្ត  ដោយពិសេស អ្នកដែលប្រាថ្នាដើម្បីនិងដឹង សន្តិបទ ឬអ្នកប្រាថ្នាដើម្បីបដិបត្តិដើម្បីបន្ទុះ   សន្តិបទ  នឹងដល់ភិក្ខុទាំង

ឡាយអ្នកប្រាថ្នាដើម្បីនិងប្រព្រឹត្តកម្មដ្ឋានទាំងអស់ ដោយមានភិក្ខុអ្នកនៅព្រៃជាវត្តជាប្រធាន ដោយពីរគាថាកន្ទះនេះ យ៉ាងនេះ ហើយឥឡូវនេះដើម្បីបដិបត្តិដោយការ ទម្លាយសេចក្តីខ្លាច អំពីពួកទេវតានោះ នឹងដើម្បីកម្មដ្ឋាន ដោយអំណាចឈានដែលមានវិបស្សនា ជាបាតសម្រាប់ភិក្ខុទាំងនោះ ទើបទ្រង់ផ្តើមត្រាស់ មេត្តកថា ដោយន័យមានអាទិ៍ថា **សុខិនោ វា ខេមិនោ ហោន្តុ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សុខិនោ** បានដល់មានសេចក្តីព្រមព្រៀងដោយសុខបទថា **ខេមិនោ** បានដល់អ្នកមានសេចក្តីក្សេមមានអធិប្បាយថាអ្នកមិនមានភ័យមិនមាន ឧបទ្វវ ។ បទថា **សព្វេ** បានដល់ដែលនៅសល់ (ទាំងពួង) ។

បទថា **សត្តា** បានដល់សត្វមានប្រាណទាំងឡាយ ។

បទថា **សុខិតត្តា** បានដល់អ្នកមានចិត្តជាសុខ ។

ក៏ក្នុងគាថានេះសត្វមានជីវិតទាំងឡាយ អ្នកសិក្សាគប្បីជ្រាបថា មានសុខដោយសុខផ្លូវកាយមានខ្លួនដល់នូវសេចក្តីសុខដោយសុខផ្លូវចិត្ត ឬមានសេចក្តីក្សេមដោយសុខ សូម្បីទាំងពីរ ឬដោយការឃ្លាតចាកភ័យ និងឧបទ្វវហេតុទាំងពួង ។

សួរថា ក៏ព្រោះហេតុអ្វីទើបត្រាស់យ៉ាងនោះឆ្លើយថាព្រោះ

ដើម្បីទ្រទ្រង់សំដែងអាការនៃមេត្តាភាវនាពិតមែនហើយព្រះយោ-
គាវចរគប្បីចម្រើនមេត្តាយ៉ាងនេះថា សូមសត្វទាំងឡាយទាំងពួង
ចូរជាអ្នកមានសេចក្តីសុខចុះ ឬថាចូរមានសេចក្តីក្សេមចុះ ឬថា
ចូរមានខ្លួនដល់នូវសេចក្តីសុខចុះ ។

កាលទ្រង់សំដែងមេត្តាភាវនាដោយបំព្រួញ តាំងអំពី
ឧបចារសមាធិ ដល់ទីបំផុតនៃអប្បនាសមាធិ យ៉ាងនេះហើយ
ឥឡូវដើម្បីទ្រង់សំដែងមេត្តាភាវនានោះ សូម្បីដោយពិស្តារទើប
ត្រាស់ពីរគាថា ថា **យេ កេចិ** ដូច្នេះ ។

ម្យ៉ាងទៀតចិត្តរបស់កុលបុត្រណាវើរវាយរាយមាយហើយ
ក្នុងអារម្មណ៍ផ្សេងៗរមែងមិនតម្រង់ទិសដៅនៅក្នុងឯកគ្គតារម្មណ៍
ដោយអារម្មណ៍ខាងដើមឡើយ តាំងតែពីការស្ទុះទៅតាមប្រភេទ
របស់អារម្មណ៍ ហើយតម្រង់នៅតាមលំដាប់តែម្តង ព្រោះដូច្នោះ
ដើម្បីនឹងទ្រង់ញ៉ាំងចិត្តរបស់កុលបុត្រនោះ ដែលជិតដាមហើយ
ជិតដាមទៀតនូវអារម្មណ៍ទាំងឡាយ ដែលផ្សេងដោយទុកៈ និង
តិកៈ មានការភ្ញាក់រលឹក និងរឹងប៉ឹងជាដើម ឲ្យតម្រង់មាំទាំនៅបាន
ទើបត្រាស់គាថា ថា **យេ កេចិ** ជាដើម ។

មួយប្រការទៀតព្រោះអារម្មណ៍ជាក់ច្បាស់ដល់កុលបុត្រណា ចិត្តរបស់កុលបុត្រនោះរមែងតម្រង់ឆ្ពោះដ៏មាំយ៉ាងសប្បាយក្នុងអារម្មណ៍នោះព្រោះដូច្នោះ ទ្រង់ព្រះប្រាថ្នាដើម្បីញ៉ាំងចិត្តរបស់កុលបុត្រនោះតាំងមាំនៅ ក្នុងអារម្មណ៍ដែលជាក់ច្បាស់នោះ ទើបត្រាស់គាថា ពីរគាថា នេះថា **យេ កេចិ** ដែលសំដែងប្រភេទនៃអារម្មណ៍ដែលជា ទុកៈ និង តិកៈ មានការភ្ញាក់រលឹកនឹងតាំងមាំជាដើម ដល់ភិក្ខុទាំងនោះ ។

ក្នុងគាថានេះ ទ្រង់សំដែងទុកៈ៤គឺពួកពីរនៃសត្វដែលភ្ញាក់រលឹក និងពួកពីរនៃសត្វដែលឃើញនិងមិនឃើញ ពួកពីរនៃសត្វដែលនៅជិតនិងឆ្ងាយពួកពីរនៃ ភូតសត្វ និង សម្ភវេសី និងតិកៈ៣ គឺ ពួកបីនៃសត្វវែង ខ្លី និងកណ្តាល ពួកបីនៃសត្វធំ តូច និងកណ្តាលពួកបីនៃសត្វធាត់ស្គមនិងកណ្តាលព្រោះកើតប្រយោជន៍ក្នុងតិកៈទាំងបីនៃសត្វមានជើងកណ្តាល និងក្នុងតិកៈ ទាំងពីរនៃសត្វមានជើងតិច ដោយបទទាំង៦ មានវែងជាដើមនោះ ។

ឈ្មោះថា **ភូតា** ព្រោះអត្ថថា សត្វទាំងឡាយមានហើយ ទ្រង់ប្រកាន់យកសត្វមាន១និង៦ខន្ធ៤ដោយបទថា **ភូតា**នេះ ។

បទថា **អត្ថិ** គឺមានប្រាកដមែន ។ ព្រះដ៏មានព្រះភាគជា

ម្ចាស់កាលទ្រង់សំដែងសត្វទាំងឡាយទាំងពួង ដែលគប្បីសង្គ្រោះ ដោយទុកៈនិងតិកៈ ដោយព្រះតម្រាស់នេះថា **យេ កេចិ បាណភូ - តត្ថិ** រួមចូលគ្នាយ៉ាងនេះហើយ បទនេះ ទ្រង់សំដែងសត្វទាំង នោះសូម្បីទាំងអស់ សង្គ្រោះចូលដោយទុកៈនេះថា **តសា វា ថាវរា វា អនវសេសា** ដូច្នេះ ។

ក្នុងគាថានោះឈ្មោះថា **តសា** ព្រោះអត្ថថាសត្វទាំងឡាយ រមែងភ្ញាក់រលឹក ។ ក៏ពាក្យថា **តសា** នោះជាឈ្មោះរបស់សត្វទាំង ឡាយ អ្នកមានតណ្ហា និងមានភ័យ ។ ឈ្មោះថា **ថាវរា**ព្រោះអត្ថ- ថា សត្វទាំងឡាយរមែងមាំទាំ ពាក្យថា **ថាវរា** នោះជាឈ្មោះ របស់ព្រះអរហន្តទាំងឡាយ អ្នកលះការធ្វើដំណើរទៅក្នុងតណ្ហា ហើយ ។ ឈ្មោះថា**អនវសេសា** ព្រោះអត្ថថាសត្វទាំងនោះមិនមាន សេសសល់ អធិប្បាយថា សូម្បីទាំងអស់។

ក៏ពាក្យដែលត្រាស់ហើយ ក្នុងទីបំផុតនៃគាថាទី២ ពាក្យ- នោះទាំងអស់ អ្នកសិក្សាគប្បីភ្ជាប់ជាមួយទុកៈ និងតិកៈ ថា សត្វ មានជីវិតឯណាមួយដែលមានហើយ ជាអ្នកភ្ញាក់រលឹក ឬជាអ្នក មុតមាំមិនមានចំណែកខ្វះខាត សូមសត្វទាំងអស់នេះចូរជាអ្នក

មានខ្លួនដល់នូវសេចក្ដីសុខចុះ សត្វទាំងឡាយដែលកើតហើយ ឬស្វែងរកកន្លែងកើត មាននៅត្រឹមណា សូមសត្វទាំងអស់នេះ ចូរជាអ្នកមានខ្លួនដល់នូវសេចក្ដីសុខចុះ ដូច្នេះ ។ ពេលនេះ គប្បីជ្រាបអធិប្បាយក្នុងគាថាទាំង៦ថា **ទីឃា វា** ជាដើម ដែលសំដែងដល់តិក:ទាំង៣មានអាទិ៍ថា វែង ខ្លីកណ្ដាល ។ បទថា **ទីឃា វា** បានដល់មានអត្តភាពវែងមាននាគត្រីនិងទន្សងជាដើមក៏អត្តភាពរបស់សត្វទាំងឡាយមាននាគជាដើម ក្នុងមហាសមុទ្រមានប្រមាណច្រើនរយព្យាមខ្លះ អត្តភាពរបស់សត្វ ទាំងឡាយមានត្រីនិងទន្សងជាដើម មានប្រមាណច្រើនយោជន៍ខ្លះ ។

បទថា **មហន្តា** បានដល់ មានអត្តភាពធំ ក្នុងទន្លេមានអណ្ដើកជាដើមលើដីគោក មានដំរី និងនាគជាដើម ក្នុងអមនុស្សទាំងឡាយមានរាហូជាដើម ដូចដែលលោកពោលថារាហូធំលើសជាងសត្វមានអត្តភាពធំទាំងឡាយ ពិតមែនហើយ តួខ្លួនរបស់រាហូនោះមានកម្ពស់ ៤៨០០យោជន៍ដៃប្រមាណ១២០០យោជន៍ចន្លោះចិញ្ចើម៥០យោជន៍ និងចន្លោះម្រាមប្រមាណ៥០ យោជន៍ដូចគ្នាបាតដៃទំហំ២០០យោជន៍ ។

បទថា **មជ្ឈិមា** បានដល់អត្តភាពរបស់សត្វទាំងឡាយមាន

សត្វសេះ គោ ក្របី ជ្រូក ជាដើម ។ បទថា **រស្សកា** បានដល់សត្វទាំងឡាយដែលមានប្រមាណទាបជាងសត្វវែង និងសត្វកណ្តាល មានមនុស្សតឿជាដើម ក្នុងជាតិនោះៗ ។

បទថា **អណុកា** បានដល់ សត្វទាំងឡាយដែលមានអត្ត-ភាពល្អិត កើតក្នុងទឹកជាដើម មិនជាអារម្មណ៍របស់មំសចក្ខុ តែជាវិស័យរបស់ទិព្វចក្ខុ ឬសត្វទាំងឡាយមានសុចជាដើម។ម្យ៉ាងសត្វពួកណាមានប្រមាណទាបជាងសត្វធំឬសត្វកណ្តាលនិងតូចជាងសត្វធាត់ និងសត្វកណ្តាលក្នុងជាតិនោះគប្បីជ្រាបថា **អណុកា** ។

បទថា **ថូលា** បានដល់សត្វទាំងឡាយដែលមានអត្តភាពមូល មានត្រី អណ្តើក ង៉ាវ និងខ្ចងជាដើម ។

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សំដែងសត្វទាំង-ឡាយដោយមិនមានចំណែកសេសសល់ ដោយតិកៈទាំងឡាយយ៉ាងនេះហើយ ពេលនេះទើបទ្រង់ត្រាស់សំដែង សត្វទាំងនោះដើម្បីសង្គ្រោះសូម្បីដោយទុកៈទាំង៣មានអាទិ៍ថា **ទិដ្ឋា វា យេ ច អទិដ្ឋា** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ទិដ្ឋា**បានដល់ ការដែលឃើញដោយអំណាចទីដែលមកកាន់ក្រសែចក្ខុរបស់ខ្លួន ។បទថា **អទិដ្ឋា**

បានដល់ ដែលស្ថិតនៅក្នុងសមុទ្រដទៃ ភ្នំដទៃ និងចក្រវាឡ ដទៃជាដើម ។

ក៏ទ្រង់សំដែងសត្វទាំងឡាយ ដែលនៅក្នុងទីជិត និងក្នុងទីឆ្ងាយជាមួយអាទិភាពរបស់ខ្លួន ដោយទុកៈនេះថា យេ ច ទូរេ វសន្តិ អវិទូរេ សត្វទាំងនោះគប្បីជ្រាបដោយអំណាចនៃសត្វមិនមានជើង និងសត្វជើងពីរ ក៏សត្វទាំងឡាយនៅក្នុងកាយរបស់ខ្លួន ហៅថា នៅក្នុងទីជិត នៅក្នុងកាយផ្នែកខាងក្រៅហៅថានៅក្នុងទីឆ្ងាយ ម្យ៉ាងនៅក្នុងខាងក្នុង ឧបចារ ហៅថា នៅក្នុងទីជិត នៅខាងក្រៅ ឧបចារ ហៅថា ទីឆ្ងាយ នៅក្នុងវិហារ ស្រុក ជនបទ ទ្វីបចក្រ-វាឡ ហៅថា នៅក្នុងទីជិត នៅក្នុងចក្រវាឡដទៃ ហៅថា នៅក្នុងទីឆ្ងាយ ។

បទថា ភូតា បានដល់កើតហើយ គឺកើតឡើងហើយ ។ សត្វឯណាកើតហើយ រមែងមិនដល់ការរាប់ថា និងមានទៀត ពាក្យ ថា ភូតានោះ ជាឈ្មោះរបស់សត្វទាំងនោះ អ្នកជាព្រះខី-ណាស្រព ។

ឈ្មោះថា សម្ភវេសី ព្រោះអត្ថថា សត្វទាំងឡាយរមែងស្វែងរកទីកើត ពាក្យថា សម្ភវេសី នោះជាឈ្មោះរបស់ព្រះ សេក្ខ និង

បុថុជ្ជនទាំងឡាយអ្នកស្វែងរកទីកើតសូម្បីតទៅ ព្រោះសេចក្តីថា ជាអ្នកលះភវសំយោជនៈមិនបាន ន័យមួយទៀតសត្វទាំងឡាយ ដែលកើតអំពីស៊ុត និងកើតអំពីគភ៌បណ្តាកំណើតទាំង៤ នៅមិន ទាន់ទំលាយសំបកស៊ុតចេញ និងមិនទាន់ទំលាយទងសុកចេញ ដរាបណា ឈ្មោះថា **សម្ភវេសី** ដរាបនោះ ។ សត្វទាំងឡាយដែល ទំលាយសំបកស៊ុត និងទំលាយទងសុកចេញមកខាងក្រៅហើយ ឈ្មោះថា **ភូត** សត្វទាំងឡាយដែលកើតអំពីញើស និងឧបបាតិក សត្វ ឈ្មោះថា**សម្ភវេសី**ក្នុងខណៈនៃបឋមចិត្តចាប់ផ្តើមអំពីខណៈ នៃចិត្តដួងទី២ ឈ្មោះថា**ភូត** ឬរមែងកើតដោយឥរិយាបថណានៅ មិនដល់ឥរិយាបថដទៃ អំពីឥរិយាបថនោះ ដរាបណា ឈ្មោះថា **សម្ភវេសី** ដរាបនោះ បន្តអំពីនោះទៅ ទើបឈ្មោះថា**ភូត**។

ព្រះដ៏មានព្រះភាគជាម្ចាស់កាលទ្រង់ សំដែងមេត្តាភាវនា ក្នុងសត្វទាំងឡាយដោយអំណាចនៃការប្រាថ្នាដើម្បីដល់ហិតសុខ ដល់ភិក្ខុទាំងនោះ ដោយប្រការផ្សេងៗ ដោយសេចក្តី២គាថាកន្លះ ថា **សុខិនោ វា** ជាដើមយ៉ាងនេះហើយ ពេលនេះកាលនឹងទ្រង់សំ- ដែងមេត្តាភាវនានោះសូម្បីដោយអំណាចនៃការប្រាថ្នាដើម្បី មិន ឲ្យជួបហិតទុក្ខ ទើបត្រាស់ថា **ន បរោ បរំ និកុព្វេថ** ។ នោះជាបាលី

ចាស់ពីមុន ។ ឥឡូវនេះនាំគ្នាសូត្រថា **បរញ្ហិ** ដូច្នេះក៏មាន (នេះមិនល្អទេ)។

បណ្តាបទទាំងនោះ បទថា **បរោ** បានដល់ជនដទៃ ។

បទថា បរំ បានដល់នូវជនដទៃ ។ បទថា **ន និកុព្វេថ** គឺមិនគប្បីបំភ័យគំរាមកំហែង បទថា **នាតិមញ្ញេថ** គឺមិនគប្បីមើលងាយ

បទថា **កត្ថចិ** បានដល់ ក្នុងទីទាំងឡាយមានជាដើមថា ឱកាសស្រុក ដែន ពាក់កណ្តាលញាតិ ឬពាក់កណ្តាលបុត្រ ។

បទថា **នំ** បានដល់ ឯតំ ។

បទថា **កិញ្ចិ** បានដល់ នូវបុគ្គលណាម្នាក់នឹងជាក្សត្រ ក៏ដោយជាដើម បទថា **ព្យារោសនា បដិឃសញ្ញា** សេចក្តីថាដោយសេចក្តីមួម៉ៅ ដោយពិការផ្លូវកាយនិងវាចា និង ដោយសេចក្តីចង្អៀតចង្អល់ ដោយពិការផ្លូវចិត្ត ។ ដោយកាលគួរនឹងត្រាស់ថា **ព្យារោសនា បដិឃសញ្ញា** ព្រះអង្គក៏ត្រាស់ថា **ព្យារោសនា បដិឃ-សញ្ញ** ដូចកាលគួរនឹងពោលថា **សម្មទញ្ញាយ វិមុត្តា** ក៏ពោលថា **សម្មទញ្ញា វិមុត្តា** និងកាលគួរពោលថា **អនុបុព្វសិក្ខាអនុបុព្វកិរិយា អនុបុព្វបដិបទា អញ្ញារាធនា** ។

បទថា **នាញ្ញមញ្ញស្ស ទុក្ខមិច្ឆេយ្យ** សេចក្តីថា មិនគប្បីប្រា-

ថ្នាទុក្ខដល់គ្នានិងគ្នា ។ មានអធិប្បាយដូចម្ដេច ?មានអធិប្បាយថា មិនគប្បីចំរើនមេត្តាដោយអំណាចនៃមនសិការជាអាទិ៍ថាចូរមាន សេចក្ដីសុខ មានសេចក្ដីក្សេមចុះ តែម្យ៉ាងប៉ុណ្ណោះ តែគប្បីចំរើន មនសិការសូម្បីយ៉ាងនេះថា ធ្វើយ៉ាងណាហ្ន៎ បុគ្គលដែលជាអ្នក ដទៃខ្លះមិនគប្បីគំរាមកំហែងយ៉ាងណាៗ ដោយពាក្យខឹងក្រោធ ទាំងឡាយមានការលួងលោមបញ្ឆោតជាដើម នឹងមិនគប្បីមើល ងាយបុគ្គលដទៃយ៉ាងណាៗក្នុងប្រទេសណាមួយដោយរឿងមានៈ មានជាតិជាដើម គឺមិនគប្បីប្រាថ្នាសេចក្ដីទុក្ខដល់គ្នានិងគ្នា ព្រោះ សេចក្ដីមួម៉ៅក្ដៅក្រហាយ ឬព្រោះសេចក្ដីខឹងក្រោធ ។

កាលទ្រង់សំដែងមេត្តាភាវនាដោយន័យសេចក្ដី ដោយអំ-ណាចនៃការប្រាថ្នា ដើម្បីសេចក្ដីមិនជួបប្រទះអហិតទុក្ខ យ៉ាង នេះហើយ ពេលនេះកាលនឹងទ្រង់សំដែង មេត្តាភាវនា នោះៗឯង ដោយពាក្យឧបមា ទើបត្រាស់ថា **មាតា យថា និយំ បុត្តំ** ដូច្នេះ ។

គាថានោះមានសេចក្ដីថា មាតាគប្បីចិញ្ចឹមថែរក្សាបុត្រម្នាក់ ដែលកើតពីខ្លួន គឺបុត្រដែលកើត អំពីគភ៌ បានដល់បុត្រម្នាក់ នោះដោយអាយុ គឺលះបង់សូម្បីតែអាយុរបស់ខ្លួន ដើម្បីការពារ សេចក្ដីទុក្ខដែលនឹងចូលមកដល់បុត្រនោះ ថ្នាក់ថ្នមរក្សាបុត្រនោះ

យ៉ាងណា កុលបុត្រគប្បីចំរើនមេត្តាឲ្យមានក្នុងចិត្តយ៉ាងនេះសូម្បីគ្រប់សត្វទាំងពួង គឺគប្បីញ៉ាំងមេត្តាឲ្យកើតឡើង ឲ្យចំរើនរឿយៗ និងគប្បីចំរើនមេត្តានោះដោយអំណាច នៃសត្វមិនមានប្រមាណក្នុងអារម្មណ៍ ឬគប្បីចំរើនមេត្តានោះមិនមានប្រមាណដោយអំ-ណាចនៃការផ្សាយទៅមិនមានសេសសល់សូម្បីក្នុងសត្វតែមួយ។

កាលទ្រង់សំដែងមេត្តាភាវនា ដោយអាការទាំងពួងយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងទ្រង់សំដែងការចំរើនមេត្តាភាវនានោះឯង ទើបត្រាស់ថា **មេត្តញ្ច សព្វលោកស្មឹ** ដូច្នេះ ។

ក្នុងគាថានោះឈ្មោះថា មិត្ត ព្រោះអត្ថវិគ្រោះថា រមែងស្រឡាញ់ អធិប្បាយថា រមែងអាល័យ ព្រោះជាអ្នកមានអធ្យាស្រ័យអនុគ្រោះ និងរមែងរក្សាចាកចេញពីការជួបប្រសព្វវត្ថុដែលមិនអនុគ្រោះ ភាវៈនៃមិត្តឈ្មោះថាមេត្តា ។

បទថា **សព្វំ** បានដល់ មិនមានចំនែកសេសសល់ ។ បទថា **លោកស្មឹ** គឺសត្វក្នុងលោក ។

វត្ថុដែលមានក្នុងចិត្ត ឈ្មោះថា **មានស** ។ ក៏ **មានស**នោះត្រាស់យ៉ាងនេះក៏ព្រោះជាធម៌ដែលសម្បយុត្តដោយចិត្ត ។ បទថា

*ភាវយេ* គឺគប្បីចំរើន ។ ឈ្មោះថាមិនមានប្រមាណព្រោះមេត្តានោះ គឺមិនមានបរិមាណ

មេត្តានោះព្រះអង្គត្រាស់យ៉ាងនេះ ព្រោះមានសត្វមិនមានប្រមា-ណជាអារម្មណ៍ ។

បទថា **ឧទ្ធំ** បានដល់ ខាងលើទ្រង់កាន់យកអរូបភពដោយបទនោះ ។ បទថា **អធោ** បានដល់ខាងក្រោម ទ្រង់កាន់យកកាមភពដោយបទនោះ ។

បទថា **តិរិយំ** បានដល់ត្រង់កណ្ដាល ទ្រង់កាន់យករូបភពដោយបទនោះ ។

បទថា **អសម្ពាធំ** បានដល់វៀរចាកសេចក្ដីចង្អៀតចង្អល់ ។ មានអធិប្បាយថា មានខេត្តដែនទំលាយហើយសត្រូវហៅថាខេត្តដែន អធិប្បាយថា ប្រព្រឹត្តទៅហើយក្នុងខេត្តដែនទាំងឡាយសូម្បីនោះ ។

បទថា **អវេរំ** បានដល់ ប្រាសចាកវេរា ។ មានអធិប្បាយថា វៀរចាកការប្រោកដនៃវេរចេតនា សូម្បីក្នុងចន្លោះៗ ។

បទថា **អសបត្តំ** បានដល់ ប្រាសចាកសត្រូវ ។ ពិតមែនហើយបុគ្គលអ្នកមានមេត្តាជាគ្រឿងនៅ រមែងជាទីស្រឡាញ់របស់

មនុស្សទាំងឡាយ រមែងជាទីស្រឡាញ់របស់អមនុស្សទាំងឡាយ រមែងមិនមានសត្រូវណាៗ ដោយហេតុនោះ **មានស** នោះរបស់បុគ្គលនោះហៅថា មិនមានសត្រូវ ព្រោះសេចក្តីថា ជាអ្នកប្រាសចាកសឹកសត្រូវហើយ ។ ក៏ពាក្យថា សឹកសត្រូវនោះ ជាពាក្យបរិយាយ នេះជាការពណ៌នាសេចក្តីតាមលំដាប់បទ ។ ការពណ៌នាសេចក្តីដែលប្រាថ្នាក្នុងគាថានេះ ដូច្នេះ **មេត្តា** មានក្នុងចិត្តនោះឯណា ដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ថាកុលបុត្រគប្បីចំ-រើនមេត្តាមានក្នុងចិត្ត ដែលមិនមានប្រមាណ ក្នុងសត្វទាំងពួងសូម្បីយ៉ាងនេះ ក៏កុលបុត្រគប្បីចំរើនមេត្តាដែលមិនមានប្រមាណក្នុងសត្វទាំងពួងសូម្បីយ៉ាងនេះ ក៏កុលបុត្រគប្បីចំរើនមេត្តាដែលមិនមានប្រមាណដែលមានក្នុងចិត្តនេះ នោះក្នុងលោកទាំងពួងគឺគប្បីឲ្យចំរើន បានដល់ គឺគប្បីឲ្យដល់សេចក្តីចំរើន ទាំងខាងលើខាងក្រោម និងខាងទទឹង(គឺត្រង់កណ្តាល) បានដល់ខាងលើខ្ពស់រហូតដល់ ភគ្គព្រហ្មខាងក្រោមចូលដល់អវិចីខាងទទឹងរហូតគ្រប់ទិសដទៃ (ទិស៨) ។

ម្យ៉ាងទៀត មេត្តាដែលមានក្នុងចិត្តដែលមិនមានប្រមាណនោះឯណា ដល់ហើយនូវភាវនាសម្បទា មិនចង្អៀតចង្អល់ក្នុង

លោកទាំងពួង ដោយអំណាចនៃឱកាសលោកមិនមានវេរាដោយការកំចាត់សេចក្តីចង្អៀតចង្អល់ដែលខ្លួនមាន ក្នុងសត្វដទៃនិងមិនមានសត្រូវដោយការកំចាត់នូវសេចក្តីចង្អៀតចង្អល់ដែលសត្វដទៃមានក្នុងខ្លួន គប្បីចំរើនគឺគប្បីធ្វើឲ្យច្រើនឡើងដោយមេត្តាដែលមានក្នុងចិត្តដែលមិនមានប្រមាណនោះ មិនចង្អៀត មិនមានពៀរ មិនមានសត្រូវក្នុងលោកទាំងអស់ ដោយការកំណត់៣យ៉ាង គឺ ខាងលើ ខាងក្រោម និងខាងទទឹង ។

កាលទ្រង់សំដែង ការចំរើនមេត្តាភាវនាយ៉ាងនេះ ហើយពេលនេះកាលនឹងសំដែងសេចក្តីមិនមានកំណត់ឥរិយាបថ ដល់កុលបុត្រអ្នកប្រកបភាវនានោះឯងមុន ទើបត្រាស់ថា **តិដ្ឋំ។ បេ។ អបិដ្ឋេយ្យ** ដូច្នេះ ។

គាថានោះមានសេចក្តីថា ក៏កុលបុត្រដែលនឹងចំរើនមេត្តាដែលមានក្នុងចិត្តនោះយ៉ាងនេះហើយ មិនធ្វើការកំណត់ឥរិយា-បថ ដូចក្នុងប្រយោគមានជាដើមថា ភិក្ខុនោះអង្គុយចំរើនសមាធិតាំងកាយឲ្យត្រង់ តំរង់សតិឆ្ពោះទៅ ដូច្នេះ ធ្វើការបន្ទោបង់ភាពនឿយហត់ ឥរិយាបថដទៃៗតាមសប្បាយ ឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី គប្បីជាអ្នកប្រាសចាកការដេកលក់ត្រឹមណាក៏គប្បីតាំងទុក

នូវសតិក្នុងមេត្តាឈាននេះទុក (អស់កាល) ត្រឹមនោះ ។

ម្យ៉ាងទៀត កាលត្រាស់ការចំរើនមេត្តាភាវនាយ៉ាងនេះហើយ ពេលនេះកាលនឹងទ្រង់សំដែងភាពជាអ្នកជំនាញ ឈរក្តី ដើរក្តី រមែងជាអ្នកប្រាថ្នាដើម្បីតាំង សតិក្នុងមេត្តាឈាននោះតាមឥរិយាបថ ។

ម្យ៉ាងទៀត ឥរិយាបថទាំងឡាយ មានការឈរជាដើមថា **តិដ្ឋំ ចរំ និសិន្នោ** ដូច្នេះរមែងមិនធ្វើសេចក្តីអន្តរាយដល់កុលបុត្រនោះដោយឥរិយាបថត្រឹមណា រមែងជាអ្នកប្រាសចាកសេចក្តីងងុយងោកងក់ត្រឹមនោះ ភាពជាអ្នកមានប្រក្រតីប្រព្រឹត្តយឺតយូរក្នុងមេត្តាឈាននោះ រមែងមិនមានដល់កុលបុត្រនោះ ដោយហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ទើបត្រាស់ថា កុលបុត្រឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី គប្បីជាអ្នកប្រាសចាកសេចក្តីដេកលក់ត្រឹមណា ក៏គប្បីតាំងសតិនេះ ទុកត្រឹមនោះ ។

គាថានោះមានអធិប្បាយយ៉ាងនេះថា មេត្តានោះឯណាដែលត្រាស់ថា កុលបុត្រគប្បីចំរើនមេត្តាដែលមានក្នុងចិត្ត ប្រព្រឹត្ត

ទៅក្នុងលោកទាំងអស់ ដូច្នេះកុលបុត្រគប្បីចំរើនមេត្តានោះដោយប្រការដែលមិនប្រកាន់ឥរិយាបថទាំងឡាយ មានការឈរជាដើម ក្នុងឥរិយាបថទាំងឡាយមានការឈរជាដើម តាមឥរិយាបថជាអ្នកប្រាថ្នា ដើម្បីតាំងសតិក្នុងមេត្តាឈាននោះដរាបណាគប្បីតាំងសតិនោះទុកដរាបនោះ ។

កាលទ្រង់សំដែងនូវភាពជាអ្នកជំនាញ ក្នុងការចំរើនមេត្តាយ៉ាងនេះ ទ្រង់ប្រកបកុលបុត្រក្នុងមេត្តាព្រហ្មវិហារនោះថា គប្បីត្រាស់នេះទុក ដូច្នេះហើយ ពេលនេះកាលនឹងទ្រង់ត្រាស់សរសើរវិហារធម៌នោះ ទើបត្រាស់ថា **ព្រហ្មមេត្តំ វិហារំ ឥធមាហុ** ប្រែថា បណ្ឌិតទាំងឡាយពោលវិហារធម៌នេះថា ជាព្រហ្មវិហារក្នុងធម្មវិន័យរបស់ព្រះអរិយជាម្ចាស់នេះ ដូច្នេះ ។

គាថានោះមានសេចក្ដីថា មេត្តាវិហារនេះឯណា ដែលព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សំដែងហើយ ផ្ដើមអំពីពាក្យថា **សុខិនោ វា ខេមិនោ ហោន្តុ** រហូតដល់ពាក្យថា ឯតំ **សតឹ អធិដ្ឋេយ្យ** បណ្ឌិតទាំងឡាយពោលមេត្តាវិហារនោះ ថាជាព្រហ្មវិហារ គឺពោលថាជាធម៌ដែលជា ទីនៅដ៏ប្រសើរបំផុត ក្នុងធម្មវិន័យរបស់ព្រះអរិយជាម្ចាស់នេះ ព្រោះជាធម៌ប្រាសចាកទោស ក្នុងទិវវិហារ

ព្រហ្មវិហារ អរិយវិហារ និងឥរិយាបថវិហារទាំង៤និងព្រោះជាធម៌ធ្វើប្រយោជន៍ដល់ខ្លួនខ្លះ ដល់សត្វដទៃខ្លះ ព្រោះដូច្នោះកុលបុត្រឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ជានិច្ចរឿយៗមិនរវល់រឿងអ្នកដទៃគប្បីជាអ្នកមិនទាន់ដេកលក់អស់ត្រឹមណា ក៏គប្បីតាំងសតិនោះទុកអស់កាលត្រឹមនោះ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ កាលទ្រង់សំដែងមេត្តាភាវនាដោយប្រការផ្សេងៗ ដល់ភិក្ខុទាំងនោះយ៉ាងនេះហើយ ឥឡូវនេះព្រោះមេត្តាជាធម៌ជិតជាប់ចំពោះអត្តទិដ្ឋិ ព្រោះជាធម៌ដែលមានសត្វជាអារម្មណ៍ ព្រោះដូច្នោះកាលនឹងទ្រង់សំដែងការបន្ទុះអរិយភូមិធ្វើមេត្តាឈាននោះៗឯង ឲ្យជាបាតដល់ភិក្ខុទាំងនោះ ដោយមុខ: គឺការទាស់ទែងខ្វែងគំនិតគ្នា (ព្រោះ)សេចក្តីប្រកាន់ទិដ្ឋិ ទើបត្រាស់គឺឲ្យទេសនាចប់ដោយព្រះគាថានេះថា **ទិដ្ឋិញ្ច អនុបគម្ម** និង មិនចូលអាស្រ័យ **ទិដ្ឋិ** ដូច្នេះ ។

គាថានោះ មានសេចក្តីថា មេត្តាឈានវិហារ នេះឯណាដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សំដែងហើយ ថា **ព្រហ្មមេត្តំ វិហារំ ឥធមាហុ** ប្រែថា បណ្ឌិតទាំងឡាយពោល នូវ វិ-

ហារធម៌នេះថាជាព្រហ្មវិហារក្នុងធម្មវិន័យរបស់ព្រះអរិយជាម្ចាស់នេះ កុលបុត្រចេញចាកមេត្តាឈានវិហារនោះហើយ កំណត់រូបធម៌តាមទំនងដែលកំណត់ជាដើមនូវធម៌មានវិតក្កវិចារជាដើមក្នុងមេត្តាឈានវិហារ នោះ និងមិនចូលទៅអាស្រ័យ ទិដ្ឋិក្នុងកងនៃសង្ខារសុទ្ធៗ ដោយការកំណត់នាមនិងរូបនេះយ៉ាងនេះថា បុគ្គលមិនគប្បីបានសត្វក្នុងកងនៃសង្ខារនេះ ជាអ្នកមានសីល ដោយលោកុត្តរសីល ដោយលំដាប់ដល់ព្រមហើយដោយទស្សនៈពោល គឺ **សម្មា ទិដ្ឋិ** ក្នុងសោតាបត្តិមគ្គ ដែលសម្បយុត្តដោយ លោកុត្តរ-សីលបន្តអំពីនោះ សេចក្តីត្រេកអរក្នុងវត្ថុកាមទាំងឡាយនេះ ឯ-ណាដែលជាកិលេសកាមនៅមិនទាន់បានលះ ក៏គប្បីនាំចេញនូវសេចក្តីត្រេកអរក្នុងកាមទាំងឡាយនោះ ដោយ សកទាគាមិមគ្គ និងអានាគាមិមគ្គ និងដោយការលះដែលមិនមានចំណែកសេសសល់ ដោយអានុភាពនៃមគ្គទាំង២នោះ កាលនាំចេញហើយ គឺស្ងប់រម្ងាប់ហើយ រមែងមិនដល់សភាពជាសត្វដែលដេកក្នុងគភ៌ទៀតដោយពិត ដោយពិតប្រាកដតែម្តង គឺកើតក្នុងសុទ្ធាវាសទាំងឡាយហើយបន្ទុះព្រះអរហត្តបរិនិព្វានក្នុង សុទ្ធាវាស នោះ ។

ព្រះដ៏មានព្រះភាគកាលទ្រង់ញ៉ាំងទេសនាឲ្យចប់យ៉ាងនេះ នេះហើយទើបត្រាស់នឹងភិក្ខុទាំងនោះថា(ម្នាលភិក្ខុទាំងឡាយពួកអ្នកចូលទៅ ចូរនៅក្នុងដងព្រៃនោះ និងកាន់យកសូត្រនេះហើយ ចូរគោះរគាំងប្រជុំគ្នាក្នុងថ្ងៃជាទីស្តាប់ព្រះធម៌ទាំង៨នៃខែធ្វើ ធម្មកថា សាកសួរអនុមោទនាសេពចំរើន ធ្វើឲ្យច្រើនឡើងនូវកម្មដ្ឋាននេះនោះឯង អមនុស្សទាំងនោះ នឹងមិនសំដែងអារម្មណ៍ដែលគួរខ្លាចដល់អ្នកទាំងឡាយ និងជាអ្នកប្រាថ្នាប្រយោជន៍ប្រាថ្នាសេចក្តីអនុគ្រោះ ពិតប្រាកដដូច្នេះ )។

ភិក្ខុទាំងនោះទទួលពុទ្ធដីកានៃព្រះសម្មាសម្ពុទ្ធថា សាធុ ក្រោកចាកអាសនៈ ថ្វាយបង្គំ ព្រះដ៏មានព្រះភាគជាម្ចាស់ ធ្វើប្រទក្សិណ ទៅក្នុងដងព្រៃនោះហើយ ធ្វើដូចពុទ្ធដីកាដែលព្រះដ៏មានព្រះភាគជាម្ចាស់ទូន្មានប្រាប់នោះ ទេវតាទាំងឡាយគិតថា ព្រះដ៏មានព្រះភាគជាម្ចាស់ទាំងឡាយ ប្រាថ្នាប្រយោជន៍ ប្រាថ្នាសេចក្តីអនុគ្រោះដល់ពួកយើងកើតមានបីតិនិងសោមនស្សបោសសំអាតសេនាសនៈខ្លួនឯង ចាត់ចែងទឹកក្តៅ ធ្វើការគក់ខ្នងច្របាច់ជើង ត្រៀមថែរក្សាភិក្ខុទាំងនោះចំរើនមេត្តាយ៉ាងនោះឯងធ្វើមេត្តានោះឯងឲ្យប្រព្រឹត្តទៅជាបាត ប្រារព្ធវិបស្សនា គ្រប់រូបក៏សម្រេច

ព្រះអរហត្តដែលមានផលដ៏លើសលប់ប្រសើរក្រៃលែង ក្នុងខាង ក្នុងត្រៃមាសនោះឯងតែម្តង បវារណាវិសុទ្ធិបវារណា ក្នុងថ្ងៃមហាបវារណា ដូច្នេះឯង ។

ក៏កុលបុត្រធ្វើប្រយោជន៍ដែលគួរធ្វើ
ដែលព្រះតថាគតជាម្ចាស់ ព្រះអង្គទ្រង់
ឈ្វាសក្នុងប្រយោជន៍ជាធំដោយធម៌
ត្រាស់ហើយយ៉ាងនេះ គប្បីបានសោយ
សេចក្តីស្ងប់នៃទ្រព្យយ៉ាងក្រៃលែង
ជនដែលមានបញ្ញាដ៏បរិបូណ៌ទាំងឡាយ
រមែងបានត្រាស់ដឹងចំពោះសន្តិបទ (ព្រះនិព្វាន)
ព្រោះដូច្នោះ វិញ្ញូជន អ្នកប្រាថ្នាដើម្បី
ត្រាស់ដឹងនូវសន្តិបទនោះ ដែលជាអមតៈ
គួរឲ្យអស្ចារ្យដែលព្រះអរិយជាម្ចាស់
ប្រាថ្នាហើយ គប្បីធ្វើប្រយោជន៍
ដែលគួរធ្វើ ដែលផ្សេងដោយសីលសមាធិ
និងបញ្ញាដែលអស់មន្ទិលជារឿយៗ ដូច្នេះឯង ។
( ចប់អដ្ឋកថា មេត្តសូត្រ នៃអដ្ឋកថាខុទ្ទកនិកាយ )

## ប្រេត២១ពួក

១- **អដ្ឋិសង្ខលិកប្រេត** ( ប្រេតមានតែរាងឆ្អឹង ) ប្រេតនេះ មាននៅទីងដើងភ្នំគិជ្ឈកូដ ដែលព្រះមហាមោគ្គល្លានត្ថេរ លោកបានឃើញប្រេតនេះ កំពុងតែអណ្តែតឯអាកាស មានពពួកត្មាត ពពួកសត្វខ្លែងប្រមង់ ដេញតាមចោមរោមឆាបចឹក អដ្ឋិសង្ខលិកប្រេត តាមចន្លោះឆ្អឹងជំនីទាំងឡាយ អដ្ឋិសង្ខលិកប្រេតនោះ ក៏ចេះតែស្រែកថ្ងូរ នៅទីងដើងភ្នំគិជ្ឈកូដនោះ។

ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ត្រាស់សម្តែង នូវ បុព្វកម្ម នៃសត្វប្រេតនេះថា ម្នាលភិក្ខុទាំងឡាយ សត្វនុះកាលពីដើម ជាអ្នកពិឃាតគោក្នុងក្រុងរាជគ្រឹះនេះឯង ដោយកម្មវិបាកនោះ អ្នកពិឃាតនោះទៅឆេះនៅក្នុងនរក អស់ជាច្រើនរាប់រយពាន់សែនឆ្នាំ ដោយសេសសល់ នៃកម្មវិបាកនោះ ក៏ត្រឡប់មកទទួលផលក្នុងអត្តភាពជាអដ្ឋិសង្ខលិកប្រេតនេះឯង ។

២-**មំសបេសីប្រេត**(ប្រេតមានរាងកាយដូចជាចម្រៀកសាច់) ប្រេតនេះអណ្តែតនៅឯអាកាសក្បែរដើងភ្នំគិជ្ឈកូដមានពពួកសត្វត្មាតខ្លែង ប្រមង់ ដេញតាមរោមឆាបចឹក មំសបេសីប្រេតនោះឯង ក៏ស្រែកយំទួញថ្ងូរ ។ ព្រះដ៏មានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុ

ទាំងឡាយសត្វនុះកាលពីដើមជាអ្នកពិឃាតគោក្នុង ក្រុងរាជគ្រឹះនេះដែរ។

៣- **មំសបិណ្ឌប្រេត** ( ប្រេតមានរាងកាយដូចជាដុំសាច់ )

ប្រេតនេះអណ្តែតនៅឯអាកាស ក្បែរដើងភ្នំគិជ្ឈកូដ មានពពួកសត្វត្មាត ខ្លែងប្រមង់ដេញតាមរោមឆាបចឹកមំសបិណ្ឌប្រេតនោះឯង ក៏ស្រែកយំទួញថ្ងូរ ។ ព្រះដ៏មានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វនុះកាលពីដើមជាព្រានសត្វស្វាប ក្នុងក្រុងរាជគ្រឹះនេះឯង ។

៤- **និច្ឆវីបុរិសប្រេត** ( ប្រេតមានរាងកាយរអាលឥតមានស្បែក) ប្រេតនេះអណ្តែតនៅឯអាកាស ក្បែរដើងភ្នំគិជ្ឈកូដ មានពពួកសត្វត្មាត ខ្លែងប្រមង់ ដេញតាមរោមឆាបចឹក **និច្ឆវីបុរិស**ប្រេតនោះឯង ក៏ស្រែកយំទួញថ្ងូរ ។

ព្រះដ៏មានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយសត្វនុះកាលពីដើមជាអ្នកសម្លាប់សត្វចៀមក្នុងក្រុងរាជគ្រឹះនេះឯង ។

៥- **អសិលោមប្រេត**(ប្រេតមានដាវដោតជាប់នឹងរាងកាយដូចជារោម ) ប្រេតនេះអណ្តែតនៅឯអាកាសក្បែរដើងភ្នំគិជ្ឈកូដ

រោមដាវទាំងឡាយរបស់ប្រេតនោះអណ្តែតខ្ពស់ឡើងៗហើយធ្លាក់មកវិញ ដាវនោះបានដោតជាប់រាងកាយនៃប្រេតនោះឯង អសិ-លោមប្រេតនោះ ក៏ចេះតែស្រែកថ្ងូរ ។

ព្រះដ៏មានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយសត្វនុះកាលពីដើមជាអ្នកពិឃាត សត្វជ្រូកដើម្បីចិញ្ចឹមជីវិត ក្នុងក្រុងរាជគ្រឹះនេះឯង។

៦-សត្តិលោមប្រេត ( ប្រេតមានលំពែងដោតនឹងរាងកាយដូចជារោម ) ប្រេតនោះតែងអណ្តែតនៅឰដ៏អាកាស ក្បែរដើងភ្នំគិជ្ឈកូដ រោមលំពែងទាំងឡាយរបស់ប្រេតនោះ ក៏អណ្តែតខ្ពស់ឡើងៗហើយធ្លាក់មកវិញ លំពែងនោះបានដោតជាប់រាងកាយនៃប្រេតនោះឯង សត្តិលោមប្រេតនោះ ក៏ស្រែកយំទួញថ្ងូរ ។

ព្រះដ៏មានព្រះភាគ បានត្រាស់ថា ម្នាលភិក្ខុទាំងឡាយសត្វនុះកាលពីដើមជាព្រានម្រឹគក្នុងក្រុងរាជគ្រឹះនេះឯង ។

៧- ឧសុលោមប្រេត ( ប្រេតមានព្រួញដោតជាប់ នឹងរាងកាយដូចជារោម ) ព្រួញទាំងឡាយរបស់ប្រេតនោះ អណ្តែតខ្ពស់ឡើងៗ ហើយធ្លាក់មកដោតជាប់ ឰដ៏រាងកាយនៃប្រេត នោះឯងឧសុលោមប្រេតនោះក៏ចេះតែស្រែកថ្ងូរ ។

ព្រះដ៏មានព្រះភាគបានត្រាស់ថាម្នាលភិក្ខុទាំងឡាយសត្វនោះកាលពីដើមជាពេជ្ឈឃាតក្នុងក្រុងរាជគ្រឹះនេះឯង។

៨- **សូចិលោមប្រេត** (ប្រេតមានមម្ចុលជាប់នឹងរាងកាយដូចជារោម) មម្ចុលទាំងឡាយរបស់ប្រេតនោះ អណ្តែតខ្ពស់ឡើងៗ ហើយធ្លាក់មកដោតជាប់ឰដ៏រាងកាយនៃប្រេតនោះឯងសូចិលោមប្រេតនោះក៏ចេះតែស្រែកថ្ងូរ ។

ព្រះដ៏មានព្រះភាគបានត្រាស់ថាម្នាលភិក្ខុទាំងឡាយសត្វនោះកាលពីដើមជាជានាយសារថីក្នុងក្រុងរាជគ្រឹះនេះឯង។

៩- **ទុតិយសូចិលោមប្រេត** (ប្រេតមានដែកស្រួចចាក់ខ្លាស់ច្រូងច្រាងដូចជារោម) កំពុងតែអណ្តែតទៅឯអាកាស ដែកស្រួចទាំងឡាយរបស់ប្រេតនោះ ដោតចូលទៅតាមក្បាលហើយធ្លាយចេញមកខាងមាត់ ដោតចូលទៅតាមមាត់ ហើយធ្លាយចេញមកខាងទ្រូង ដោតចូលទៅតាមទ្រូង ហើយធ្លាយចេញមកខាងពោះ ដោតចូលមកតាមពោះ ហើយធ្លាយចេញមកខាងភ្លៅ (ទាំងពីរ) ដោតចូលទៅតាមភ្លៅ(ទាំងពីរ) ហើយធ្លាយចេញមកខាងស្មង (ទាំងពីរ) សូចិលោមប្រេតនោះក៏ចេះតែស្រែកថ្ងូរ ។

ព្រះដ៏មានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយសត្វ

*នោះកាលពីដើមជាអ្នកញុះញង់គេក្នុងក្រុងរាជគ្រឹះនេះឯង ។*

*១០- **កុម្ភណ្ឌប្រេត** (ប្រេតមានពងប៉ុនក្អមយ៉ាងធំ) កំពុងតែអណ្ដែតទៅឯអាកាស ប្រេតនោះកាលបើដើរ លុះតែលើកអណ្ឌ(ពង) ទាំងនោះលី(ដាក់លើស្មា) ទើបដើរទៅបាន កាលបើអង្គុយក៏បេះតែអង្គុយសង្កត់លើ អណ្ឌទាំងនោះឯង ពពួកសត្វត្មាត ខ្លែង ប្រមង់ ដេញតាមចោមឆាបចឹក កុម្ភណ្ឌប្រេតនោះបេះក៏តែស្រែកថ្ងូរ ។*

*ព្រះដ៏មានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយសត្វនុះកាលពីដើមជាអាមាត្យអ្នកវិនិច្ឆ័យក្ដី នៃអ្នកស្រុក ដោយអំពើវៀចវេមិនទៀងត្រង់ ក្នុងក្រុងរាជគ្រឹះនេះឯង ។*

*១១- **គូថខាទិប្រេត** (ប្រេតលិចចុះក្នុងរណ្ដៅលាមក) ប្រេតនេះលិចចុះក្នុងរណ្ដៅលាមកក្បែរភ្នំគិជ្ឈកូដ ។*

*ព្រះដ៏មានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយសត្វនោះកាលពីដើមជាអ្នកធ្វើបរទារកម្ម (ប្រព្រឹត្តខុសក្នុងកាម) ក្នុងក្រុងរាជគ្រឹះនេះឯង ។*

*១២- **ទុតិយខាទិប្រេត** (ប្រេតស៊ីលាមក) ប្រេតនេះលិចចុះក្នុងរណ្ដៅលាមកកំពង់តែចាប់លាមកដោយដៃទាំងពីរ ហើយ*

ស៊ីលាមកនោះ ។

ព្រះដ៏មានព្រះភាគបានត្រាស់ថាម្នាលភិក្ខុទាំងឡាយសត្វនុះ កាលពីដើមជាព្រាហ្មណ៍កំណាច ក្នុងក្រុងរាជគ្រឹះ នេះឯង ព្រាហ្មណ៍នោះកាលក្នុងសាសនាព្រះសម្មាសម្ពុទ្ធព្រះនាមកស្សប បាននិមន្តភិក្ខុសង្ឃដោយពាក្យថា និមន្តឆាន់ភត្តាហារ ក៏ចាក់លាមកពេញក្នុងស្នូក រួចហើយប្រើគេឲ្យប្រាប់ភត្តកាលថា បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកម្ចាស់និមន្តឆាន់ឲ្យឆ្អែតដោយកម្មវិបាកនោះ ព្រាហ្មណ៍កំណាចនោះ ក៏ឆេះនៅក្នុងនរក អស់រយពាន់សែនឆ្នាំដ៏ច្រើន ដោយសំណល់នៃកម្មវិបាកនោះឯង ក៏បានមកសោយនូវផលកម្មដែលត្រឡប់បាននូវអត្តភាពបែបនេះ។

១៣- **និច្ឆវិឥត្ថីប្រេត** (ប្រេតស្រីមានរាងកាយរង៉ោលឥតស្បែក)កំពុងតែអណ្តែតទៅឯអាកាសពពួកសត្វត្មាត ខ្លែង ប្រមង់ដេញតាមចោមឆាបចឹក និច្ឆវិឥត្ថីប្រេតនោះក៏ចេះតែស្រែកថ្ងូរ ។

ព្រះដ៏មានព្រះភាគបានត្រាស់ថា ស្រីនុះកាលពីដើម ជាស្រីប្រព្រឹត្តកន្លងចិត្តប្តី ក្នុងក្រុងរាជគ្រឹះនេះឯង ។

១៤- **មង្គុលីប្រេត** ( ប្រេតមានរាងកាយអាក្រក់ គួរខ្ពើមឆ្អើម) ប្រេតនេះមានរូបកាយអាក្រក់ មានក្លិនស្អុយ កំពុងតែ

អណ្តែតទៅឯអាកាស ពពួកសត្វត្មាត ខ្លែង ប្រមង់ដេញតាមចោម ឆាបចឹកមន្តុលីនោះ ក៏ប្រេតចេះតែស្រែកថ្ងូរ ។

ព្រះដ៏មានព្រះភាគបានត្រាស់ថា ស្រីនុះកាលពីដើម ជាស្រីជាស្រីមេមត់ ក្នុងក្រុងរាជគ្រឹះនេះឯង ។

១៥- ឱកិលិប្រេត ( ប្រេតមានរាងកាយឆេះរោលដោយរងើកភ្លើង )ប្រេតមានរងើកភ្លើងធ្លាក់ស្រោចលើខ្លួន(ក្តៅអន្ទះសា ) កំពុងតែអណ្តែតទៅនី ឯអាកាសឱកិលិនីប្រេតនោះ ក៏ចេះតែស្រែកថ្ងូរ ។

ព្រះដ៏មានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ស្រីនុះកាលពីដើមជាអគ្គមហេសីនៃស្តេចក្នុងដែនកាលិង្គ ជាស្រីមានចិត្តឫស្យាបានចាក់រងើកភ្លើងមួយអំបែង លើស្រីជាសត្រូវ ដោយអំពើកម្មនោះឯង ទើបនាងទទួលសេចក្តីទុក្ខបែបនេះ ។

១៦- **អសីសកពន្ធប្រេត** (ប្រេតឥតមានក្បាលមានតែខ្លួន) ប្រេតនេះកំពុងតែអណ្តែតទៅឯអាកាស ប្រេតនោះមានភ្នែកនៅនឹងទ្រូង ពពួកសត្វត្មាត ខ្លែង ប្រមង់ដេញតាមចោមឆាបចឹកប្រេតនោះ ក៏ចេះតែស្រែកថ្ងូរ ។

ព្រះដ៏មានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយសត្វ

នុះកាលពីដើមជាអ្នកពិឃាតចោរក្នុងក្រុងរាជគ្រឹះនេះឯង ។

១៧- **ភិក្ខុប្រេត** (  ប្រេតមានភេទដូចជាភិក្ខុ) ប្រេតនេះ កំពុងតែអណ្តែតទៅ ឯអាកាសសង្ឃាដីរបស់ភិក្ខុប្រេតនោះក្តីក៏មានភ្លើងឆេះសន្ធោសន្ធៅ បាត្រក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ វត្ថពន្ធ-ចង្កេះក្តីក៏មានភ្លើងឆេះ សន្ធោសន្ធៅ ភិក្ខុប្រេតនោះ ក៏បេះ តែស្រែកថ្ងូរ ។

ព្រះដ៏មានព្រះភាគ បានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្រេតនោះកាលពីដើមជាភិក្ខុ ប្រព្រឹត្តអាក្រក់ក្នុងសាសនានៃ ព្រះសម្មាសម្ពុទ្ធទ្រង់ ព្រះនាមកស្សបៈ ។

១៨- **ភិក្ខុនីប្រេត** (ប្រេតមានភេទដូចភិក្ខុនី) ប្រេតនេះ កំពុងតែអណ្តែតទៅ ឯអាកាស សង្ឃាដិរបស់ភិក្ខុនីប្រេតនោះក្តី ក៏មានភ្លើងឆេះ សន្ធោសន្ធៅ បាត្រក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ វត្ថពន្ធចង្កេះក្តីក៏មានភ្លើងឆេះសន្ធោសន្ធៅ ភិក្ខុនីប្រេតនោះក៏បេះតែស្រែកថ្ងូរ ។

ព្រះដ៏មានព្រះភាគបានត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្រេតនោះកាលពីដើមជាភិក្ខុនីប្រព្រឹត្តអាក្រក់ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈ ។

១៩- **សិក្ខមានាប្រេត** (ប្រេតមានភេទដូចសិក្ខមានា) (សាមណេរីអ្នកប្រព្រឹត្តធម៌ដើម្បីឧបសម្បទា) ប្រេតនេះមានសេចក្ដីទុក្ខដូចភិក្ខុនីប្រេតដែរ ។

២០- **សាមណេរប្រេត** (ប្រេតមានភេទដូចជាសាមណេរ) ប្រេតនេះមានសេចក្ដីទុក្ខដូចភិក្ខុប្រេតដែរ ។

២១- **សាមណេរីប្រេត** (ប្រេតមានភេទដូចសាមណេរី) ប្រេតនេះមានសេចក្ដីទុក្ខដូចភិក្ខុនីប្រេតដែរ ។ ប្រេតទាំងអស់នេះជាប្រេតដែលព្រះមហាមោគ្គល្លានត្ថេរលោកបានឃើញនា ជើងភ្នំគិជ្ឈកូដ ហើយបានប្រាប់ដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយខ្លះមិនជឿជាក់ចំពោះព្រះមហាមោគ្គល្លានត្ថេរដោយគិតថា ព្រះ-មហាមោគ្គល្លានត្ថេរនេះពោលអួតគុណវិសេសដែលជា ឧត្តរិមនុ-ស្សធម៌ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនោះ ចំពោះព្រះដ៏មាន-ព្រះភាគ ព្រះអង្គក៏ទ្រង់សម្ដែង ពីបុព្វកម្មនិងវិបាករបស់សត្វប្រេតទាំងឡាយនោះ ដោយសេចក្ដីជាដើមថា សត្វទាំងឡាយនោះទៅសោយផលវិបាករងទុក្ខវេទនាក្នុងនរក អស់កាលដ៏យូរអង្វែងរាប់រយពាន់សែនឆ្នាំ សេសសល់ផលកម្ម ទើបមកកើតជាកំណើតប្រេតនេះឯង ។ (ដកស្រង់អំពី វិន័យបិដក មហាវិភង្គ)

គប្បីជ្រាបថា ប្រេតមិនមែនមានតែប៉ុណ្ណោះទេ គឺមានច្រើនទៀតដែលមានសំដែងហើយ ក្នុងគម្ពីរ បេត្តវត្ថុ ជាដើម ។

**ពោធិបក្ខិយធម៌៣៧**

ពោធិបក្ខិយធម៌ មានវចនត្ថថា

**ចត្តារិ សច្ចានិ ពុជ្ឈតីតិ = ពោធិ** ប្រែថា ធម្មជាតិត្រាស់ដឹងនូវអរិយសច្ច៤ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **ពោធិ** ។

ពោធិបក្ខិយធម៌៣៧នោះគឺ សតិប្បដ្ឋាន៤ សម្មប្បធាន ៤ ឥទ្ធិបាទ៤ ឥន្ទ្រិយ៥ ពល៥ ពោជ្ឈង្គ៧ និងមគ្គមានអង្គ៨ ។

**សតិប្បដ្ឋាន៤**

សតិបដ្ឋាន មានវចនត្ថថា **សម្បយុត្តធម្មេសុ បមុខា បធានា ហុត្វា កាយាទីសុ អារម្មណេសុ តិត្ថតីតិ = បដ្ឋានំ**

ប្រែថា ធម៌ណា ជាប្រធាន គឺជាប្រធានក្នុងសម្បយុត្តធម៌ទាំងឡាយ ហើយតាំងនៅក្នុងអារម្មណ៍ទាំងឡាយ មានកាយជាដើម ដូច្នោះធម៌នោះ ទើបឈ្មោះថា បដ្ឋានំ ។

វចនត្ថ ម្យ៉ាងទៀតថា

**សតិ ឯវ បដ្ឋានន្តិ = ន្តិសតិបដ្ឋានំ** សតិនោះឯងជាប្រធានក្នុងសម្បយុត្តធម៌ ហើយតាំងមាំក្នុងអារម្មណ៍

មានកាយជាដើម ដូច្នោះទើបឈ្មោះថា សតិប្បដ្ឋាន ។

១ **កាយានុបស្សនាសតិប្បដ្ឋាន** សតិតាំងមាំក្នុងការរលឹក ពិចារណាឃើញរឿយៗនូវកាយក្នុងកាយ អង្គធម៌បានដល់សតិ ចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦ (រូបាវចរជវន១០ អរូបាវចរជវន៨ លោកុត្តរជវន៨ )

២ **វេទនានុបស្សនាសតិប្បដ្ឋាន** សតិតាំងមាំក្នុងការរលឹក ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាអង្គធម៌បានដល់សតិ ចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦

៣ **ចិត្តានុបស្សនាសតិប្បដ្ឋាន** សតិតាំងមាំក្នុងការរលឹក ពិចារណាឃើញរឿយៗនូវចិត្តក្នុងចិត្ត អង្គធម៌បានដល់ សតិចេត-សិក ក្នុងមហាកុសល ៨ មហាកិរិយា ៨ អប្បនាជវន ២៦ ។

៤ **ធម្មានុបស្សនាសតិប្បដ្ឋាន**

សតិតាំងមាំក្នុងការរលឹក

ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ អង្គធម៌បានដល់ សតិ-ចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦ ។

## សម្មប្បធាន៤

សម្មប្បធាន មានវចនត្ថថា

**សម្មា បទហន្តិ ឯតេនាតិ** = សម្មប្បធានំ ប្រែថា សម្បយុត្តធម៌ទាំងឡាយ មានសេចក្តីព្យាយាមដោយប្រពៃ ដោយការអាស្រ័យធម្មជាតិនោះដូ-ច្នោះធម្មជាតិដែលជាហេតុ នៃសេចក្តីព្យាយាមនោះទើបឈ្មោះថា សម្មប្បធាន(បានដល់វិរិយចេតសិក)។

១ **ឧប្បន្នានំ បាបកានំ បហានាយ វាយាមោ** ព្យាយាមដើម្បីលះអកុសលដែលកើតឡើងហើយមិនឲ្យកើតឡើងទៀត អង្គធម៌បានដល់វិរិយចេតសិក ក្នុងកុសលចិត្ត២១ (មហាកុសល៨ រូបាវចរកុសល៥ អរូបាវចរកុសល៤ លោកុត្តរមគ្គ៤ )

២ **អនុប្បន្នានំ បាបកានំ អនុបាទាយ វាយាមោ** អកុសលធម៌ដែលមិនទាន់កើត ព្យាយាមទប់ស្កាត់មិនឲ្យកើតឡើង អង្គធម៌បានដល់វិរិយចេតសិក ក្នុងកុសលចិត្ត២១ (មហាកុសល៨រូបាវចរកុសល៥ អរូបាវចរកុសល៤ លោកុត្តរមគ្គ៤ )

៣ **ឧប្បន្នានំ កុសលានំ ឧបាទាយ វាយាមោ** កុសលធម៌ដែលមិនទាន់កើតឡើង ព្យាយាមចម្រើនឲ្យកើតឡើង អង្គធម៌បានដល់វិរិយចេតសិក ក្នុងកុសលចិត្ត២១ (មហាកុសល៨រូបាវចរកុសល៥ អរូបាវចរកុសល៤ លោកុត្តរមគ្គ៤ )

៤ **ឧប្បន្នានំ កុសលានំ ភិយ្យោភាវាយ វាយាមោ** កុសលធម៌ដែលកើតឡើងហើយព្យាយាមចម្រើន ឲ្យកើតឡើងជាភិយ្យោភាពអង្គធម៌បានដល់វិរិយចេតសិក ក្នុងកុសលចិត្ត២១(មហាកុសល៨ រូបាវចរកុសល៥ អរូបាវចរកុសល៤ លោកុត្តរមគ្គ៤ )

**ឥទ្ធិបាទ៤**

ឥទ្ធិបាទ មានវចនត្ថថា

**ឥជ្ឈនំ = ឥទ្ធិ** ប្រែថា សេចក្តីសម្រេចដោយបរិបូណ៌ ឈ្មោះថា **ឥទ្ធិ** (បានដល់ឈាន អភិញ្ញា មគ្គ ផល )

វចនត្ថ ម្យ៉ាងទៀតថា

**ឥទ្ធិយា បាទោ = ឥទ្ធិបាទោ** ប្រែថា ធម៌ដែលជាហេតុសម្រេច ឈាន មគ្គ ផល ឈ្មោះថា **ឥទ្ធិបាទ** ។

១ **ឆន្ទិទ្ធិបាទ** សេចក្តីពេញចិត្តយ៉ាងខ្លាំងជាបាទជាគ្រឿងទ្រនៃការសម្រេចឈាន មគ្គ ផល អង្គធម៌បានដល់ឆន្ទចេតសិកក្នុងកុសលចិត្ត២១ ( មហាកុសល៨ រូបាវចរកុសល៥អរូបាវចរកុសល៤ លោកុត្តរមគ្គ៤ )

២ **វិរិយិទ្ធិបាទ** សេចក្តីព្យាយាមយ៉ាងខ្លាំងជាបាទជាគ្រឿងទ្រនៃការសម្រេចឈាន មគ្គ ផល អង្គធម៌បានដល់វិរិយចេតសិក

ក្នុងកុសលចិត្ត២១ ( មហាកុសល៨ រូបាវចរកុសល៥អរូបាវចរកុ-សល៤លោកុត្តរមគ្គ៤ )

៣ **ចិត្តិទ្ធិបាទ** សេចក្តីតាំងចិត្តយ៉ាងខ្ជាំងជាបាទជាគ្រឿងទ្រនៃការសម្រេចឈាន មគ្គ ផល អង្គធម៌បានដល់កុសលចិត្ត២១ ( មហាកុសល៨ រូបាវចរកុសល៥ អរូបាវចរកុសល៤ លោកុត្តរមគ្គ៤ )

៤ **វិមំសិទ្ធិបាទ** បញ្ញាពិចារណាយ៉ាងខ្ជាំងជាបាទជាគ្រឿងទ្រនៃការសម្រេចឈាន មគ្គ ផល អង្គធម៌បានដល់បញ្ញាចេតសិកក្នុងកុសលញាណសម្បយុត្ត១៧ ( មហាកុសលញាណសម្បយុត្ត ៤ រូបាវចរកុសល៥ អរូបាវចរកុសល៤ លោកុត្តរមគ្គ៤ )

## ឥន្ទ្រិយ៥

ឥន្ទ្រិយ មានវចនត្ថថា

**ឥន្ទន្តិ បរមឥស្សរិយំ ករោន្តីតិ = ឥន្ទ្រិយានិ** ប្រែថា ធម៌ណា ជាអ្នកគ្រប់គ្រង គឺរមែងធ្វើខ្លួន ជាឥស្សរ ក្រៃលែង ដូច្នោះ ធម៌នោះ ទើបឈ្មោះថា ឥន្ទ្រិយ ។

១ **សទ្ធិន្ទ្រិយ** សទ្ធាមានសភាពជាធំ នៃការជ្រះថ្លាក្នុងវត្ថុដែលសមគួរដល់ការជ្រះថ្លា មានព្រះពុទ្ធជាដើម)អង្គធម៌បានដល់

សទ្ធាចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦

២ **វិរិយិន្ទ្រិយ** វិរិយមានសភាពជាធំនៃសេចក្ដីព្យាយាមក្នុងវត្ថុដែលសមគួរដល់ការព្យាយាម អង្គធម៌បានដល់ វិរិយចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦

៣ **សតិន្ទ្រិយ** សតិមានសភាពជាធំ ក្នុងការរលឹក អង្គធម៌បានដល់សតិចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦

៤ **សមាធិន្ទ្រិយ** សមាធិមានសភាពជាធំក្នុងការឃុំគ្រងចិត្តឲ្យតាំងនៅក្នុងអារម្មណ៍តែមួយ អង្គធម៌ បានដល់ ឯកគ្គតាចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦

៥ **បញ្ញិន្ទ្រិយ** បញ្ញាមានសភាពជាធំក្នុងការដឹងច្បាស់ នូវសភាវធម៌ពិត អង្គធម៌បានដល់ បញ្ញាចេតសិក ក្នុងមហាកុសលញាណសម្បយុត្ត៤ មហាកិរិយាញាណសម្បយុត្ត៤ អប្បនាជវន២៦

## ពលៈ៥

ពលៈមានវចនត្ថថា

**ពលីយន្តិ ឧប្បន្នេ បដិបក្ខធម្មេ សហន្តិ មទ្ទន្តីតិ=ពលានិ**

ប្រែថា ធម៌ណាមែងមានកម្លាំងសង្កត់នូវបដិបក្ខធម៌ដែលកើតឡើងហើយ និងមានសេចក្តីអត់ធន់ តស៊ូ ទម្លាយនូវធម៌ជាបដិបក្ខទាំងនោះដូច្នោះ ធម៌នោះទើបឈ្មោះថា **ពលៈ** ។ ម្យ៉ាងទៀត ដែលឈ្មោះថា **ពលៈ** ដោយអត្ថថា មិនញាប់ញ័រ

១ **សទ្ធាពល** កម្លាំងគឺសទ្ធាជាគ្រឿងជ្រះថ្លាក្នុងវត្ថុដែលគួរជ្រះថ្លា អង្គធម៌បានដល់ សទ្ធាចេតសិក ក្នុងមហាកុសល៨ មហា - កិរិយា ៨ អប្បនាជវន២៦

២ **វិរិយពល** កម្លាំងគឺសេចក្តីព្យាយាមជាគ្រឿងព្យាយាមក្នុងវត្ថុដែលគួរព្យាយាម អង្គធម៌បានដល់ វិរិយចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦

៣ **សតិពល** កម្លាំងគឺសតិជាគ្រឿងរលឹកនូវសភាវធម៌ទាំងឡាយ អង្គធម៌បានដល់ សតិចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦

៤ **សមាធិពល** កម្លាំងគឺសមាធិជាគ្រឿងតម្កល់ចិត្តឲ្យតាំងនៅក្នុងអារម្មណ៍តែមួយ អង្គធម៌បានដល់ ឯកគ្គតាចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦

៥ **បញ្ញាពល** កម្លាំងគឺបញ្ញាជាគ្រឿងដឹងនូវសភាវធម៌ពិត

*អង្គធម៌បានដល់ **បញ្ញាចេតសិក** ក្នុងមហាកុសលញាណសម្បយុត្ត៤ មហាកិរិយាញាណសម្បយុត្ត៤ អប្បនាជវន២៦*

## *ពោជ្ឈង្គ៧*

*ពោជ្ឈង្គ មានវចនត្ថថា ពោធិយា អង្គោ =ពោជ្ឈង្គោ ប្រែថា ធម៌ដែលជាគ្រឿងប្រកប ជាហេតុត្រាស់ដឹង នូវអរិយសច្ចៈ៤ ឈ្មោះថា ពោជ្ឈង្គ ។*

*១ **សតិសម្ពោជ្ឈង្គ** សេចក្តីរលឹក ជាអង្គនៃការត្រាស់ដឹងនូវអរិយសច្ចធម៌៤ អង្គធម៌បានដល់សតិចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦*

*២ **ធម្មវិចយសម្ពោជ្ឈង្គ** ការពិនិត្យពិចារណាក្នុងធម៌ ទាំងខាងក្នុងទាំងខាងក្រៅ ជាអង្គនៃការត្រាស់ដឹងនូវ អរិយសច្ចធម៌៤ អង្គធម៌បានដល់ បញ្ញាចេតសិក ក្នុងមហាកុសលញាណសម្បយុត្ត៤ មហាកិរិយាញាណសម្បយុត្ត៤ អប្បនាជវន២៦*

*៣ វិរិយសម្ពោជ្ឈង្គ សេចក្តីព្យាយាម ជាអង្គនៃការត្រាស់ដឹងនូវអរិយសច្ចធម៌៤ អង្គធម៌បានដល់ វិរិយចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦*

៤ **បីតិសម្ពោជ្ឈង្គ** សភាពឆ្អែតចិត្ត ជាអង្គនៃការត្រាស់ដឹងនូវអរិយសច្ចធម៌៤ អង្គធម៌បានដល់បីតិចេតសិក ក្នុងមហាកុសលសោមនស្ស៤ មហាកិរិយាសោមនស្ស៤ សប្បីតិកអប្បនាជវន៣០ ឬរូបាវចរកុសល៣ រូបាវចរកិរិយា៣ លោកុត្តរចិត្ត៨

៥ **បស្សទ្ធិសម្ពោជ្ឈង្គ** សេចក្តីស្ងប់កាយស្ងប់ចិត្តជាអង្គនៃការត្រាស់ដឹងនូវអរិយសច្ចធម៌៤ អង្គធម៌បានដល់ កាយបស្សទ្ធិ-ចេតសិក ចិត្តបស្សទ្ធិចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦

៦ **សមាធិសម្ពោជ្ឈង្គ** សភាពតាំងមាំក្នុងអារម្មណ៍តែមួយជាអង្គនៃការត្រាស់ដឹងនូវអរិយសច្ចធម៌៤ អង្គធម៌បានដល់ ឯកគ្គ-តាចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦

៧ **ឧបេក្ខាសម្ពោជ្ឈង្គ** ឧបេក្ខាជាគ្រឿងធ្វើឲ្យសម្បយុត្តធម៌មានសភាពស្មើក្នុងតួនាទីរបស់ខ្លួន ជាអង្គនៃការត្រាស់ដឹងនូវអរិ-យសច្ចធម៌៤ អង្គធម៌បានដល់ តត្រមជ្ឈត្តតាចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦

## មគ្គមានអង្គ៨

**មគ្គង្គ** មានវចនត្ថថា

**កិលេសេ មារេន្តា និព្វានំ គច្ឆន្តិ ឯតេនាតិ = មគ្គោ**

ប្រែថា ព្រះយោគីបុគ្គលទាំងឡាយ រមែងសម្លាប់កិលេស និង រមែងចូលដល់ព្រះនិព្វាន ដោយធម៌នោះដូច្នោះធម៌ដែលជាហេតុនៃការសម្លាប់កិលេសនិង ចូលដល់ព្រះនិព្វានរបស់ព្រះយោគីបុគ្គលពួកនោះ ឈ្មោះថា មគ្គ ។

១ **សម្មាទិដ្ឋិ** សេចក្តីយល់ឃើញត្រូវ ជាផ្លូវឲ្យដល់មគ្គ ផល ព្រះនិព្វាន អង្គធម៌បានដល់បញ្ញាចេតសិក ក្នុងមហាកុសលញាណសម្បយុត្ត៤ មហាកិរិយាញាណសម្បយុត្ត៤ អប្បនាជវន២៦

២ **សម្មាសង្កប្ប** សេចក្តីត្រិះរិះត្រូវ ជាផ្លូវឲ្យដល់មគ្គ ផល ព្រះនិព្វាន អង្គធម៌បានដល់ វិតក្កចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ បឋមជ្ឈានជវន១០ ឬរូបាវចរកុសល១ រូបាវចរកិរិយា១ លោកុត្តរ៨

៣ **សម្មាវាចា** ការពោលពាក្យត្រូវ ជាផ្លូវឲ្យដល់មគ្គ ផល ព្រះនិព្វាន អង្គធម៌បានដល់សម្មាវាចាចេតសិកក្នុងមហាកុសល៨

លោកុត្តរ៨

៤ **សម្មាកម្មន្ត** ការងារត្រូវជាផ្លូវឲ្យដល់មគ្គ ផលព្រះនិព្វាន អង្គធម៌បានដល់ សម្មាកម្មន្តចេតសិក ក្នុងមហាកុសល៨ លោកុត្តរ៨

៥ **សម្មាអាជីវ** ការចិញ្ចឹមជីវិតត្រូវ ជាផ្លូវឲ្យដល់មគ្គ ផល ព្រះនិព្វានអង្គធម៌បានដល់សម្មាអាជីវចេតសិកក្នុងមហាកុសល៨ លោកុត្តរ៨

៦ **សម្មាវាយាម** សេចក្ដីព្យាយាមត្រូវជាផ្លូវឲ្យដល់មគ្គ ផល ព្រះនិព្វាន អង្គធម៌បានដល់ វិរិយចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦

៧ **សម្មាសតិ** សេចក្ដីរលឹកត្រូវ ជាផ្លូវឲ្យដល់មគ្គផលព្រះ និព្វាន អង្គធម៌បានដល់សតិចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦

៨ **សម្មាសមាធិ** ការតម្កល់ចិត្តត្រូវ ជាផ្លូវឲ្យដល់ មគ្គ ផល ព្រះនិព្វាន អង្គធម៌បានដល់ ឯកគ្គតាចេតសិក ក្នុងមហាកុសល៨ មហាកិរិយា៨ អប្បនាជវន២៦

**ពោធិបក្ខិយធម៌៣៧ចប់**

### អកុសល៩កង

### អាសវៈ៤ ឱឃៈ៤ យោគៈ៤ គន្ថៈ៤ ឧបាទាន៤

### នីវរណៈ៥ អនុស័យ៧ សំយោជនៈ១០ កិលេស១០

### អាសវៈ៤

ធម៌ដែលឈ្មោះថា **អាសវ** ព្រោះអត្ថថាហូរទៅ ឬជាគ្រឿងត្រាំទុកយ៉ាងយូរ អាសវនោះ មាន៤គឺ

១ **កាមាសវ** ធម្មជាតិដែលជាគ្រឿងត្រាំ គឺ កាម បានដល់កាមភព

